# ទានបញ្ញា និង ទានានិសង្ស



រៀបរៀងដោយ
សច្ចសីលោ **ស្ងួន ចំរើន**

**ចែកជាធម្មទានទូទៅ**

**ព.ស.២៥៥៧**

# នាមអ្នកមានឧបការៈក្នុងការចេញធម្មទាន

-ព្រះធម្មវង្សាធិបតី **បណ្ឌិតធម្មោ សុខ ថាន** ព្រះមេគណខេត្ត
-ព្រះបាឡាត់គណខេត្ត **វិនយធរោ ទេព ធឺន**
-ព្រះសមុហ៍គណខេត្ត **សង្ឃមនាបោ ហែម ឡុត**
-ព្រះវិន័យធរគណ និង អនុគណក្រុង **ធម្មកោសលោ ខុន ថុន**

-សមណនិស្សិត **ចេង ម៉េង**
-សមណនិស្សិត **ហេង សុគិន**
-សមណនិស្សិត **ទី ច័ន្ទ**
-សមណនិស្សិត **ផន សុឡា**
-សមណនិស្សិត **ហួន វ៉ាន់**
-សមណនិស្សិត **ប៉ក់ សុពុំ**
-សមណសិស្ស **យឿន រ៉ាក់**
-ឧបាសិកា **ស៊ិន ស៊ីថា**
-ឧបាសក **ជា យាន**
-ឧបាសិកា **ឆូ សាឡឿន**
-ឧបាសិកា **សោម សុបុត្រ**
-ឧបាសិកា **ដោ យ៉េត**

-សមណនិស្សិត **ផល ទារាក់**
-សមណនិស្សិត **សៅ វណ្ណដេត**
-សមណនិស្សិត **សូ ចាន់ស៊ីម**
-សមណនិស្សិត **យាន សុខឿន**
-សមណនិស្សិត **សោម សុភា**
-សមណនិស្សិត **រ័ត្ន នីម**
-សមណសិស្ស **សុខ អានផល្លី**
-ឧបាសក **ឆន**
-ឧបាសិកា **ជួប ចន្ធី**
-ឧបាសិកា **យ៉ាន**
-ឧបាសិកា **ចាន សុម៉ុន**
-ឧបាសិកា **ឡេង និង ដេត**

និង ក្រុមសមាជិកផ្សព្វផ្សាយព្រះធម៌នៃកម្មវិធីព្រះពុទ្ធសាសនា និង សង្គមខ្មែរ ប្រចាំនៅខេត្តកំពង់ឆ្នាំង ទាំងអស់អង្គ ។

# **អារម្ភបទ**

មូលហេតុដែលនាំឲ្យខ្ញុំរៀបរៀងសៀវភៅនេះឡើង ដោយសេចក្ដីយល់ឃើញថាពួកពុទ្ធបរិស័ទទូទៅ ភាគច្រើននិយមក្នុងការធ្វើទានដែលជាកិច្ចនឿយហត់លំបាកជាងធ្វើការកុសលដទៃទៀតទាំងអស់ ព្រោះហេតុនោះបានជាខ្ញុំខំប្រឹងស្រាវជ្រាវរក និង ប្រមូលចងក្រងនូវគម្ពីរនានាដែលទាក់ទងពីរឿងទាន និង អានិសង្សផ្សេងៗដែលមានក្នុងសូត្រនានា ដកស្រង់មករៀបរៀងជាសៀវភៅនេះឡើង ហើយសន្មតឲ្យឈ្មោះថា " **ទានបញ្ញា និង ទានានិសង្ស** " ដែលនិយាយពីសំណួរ ចម្លើយនៃការធ្វើទាន និង កម្រៃអានិសង្សនៃការធ្វើទាន របស់ទាយក ទាយិកា ដើម្បីត្រិះរិះពិចារណាដោយការអាន ពិនិត្យ សង្កេតក្នុងបញ្ហានីមួយៗឲ្យបានយល់សេចក្ដីច្បាស់លាស់ និង ពេញចិត្តចំពោះទាន ព្រមទាំងអាចយកជាវត្តប្រតិបត្តិបាន ។

ជាធម្មតាកិច្ចការអ្វីនីមួយក្នុងលោក អាចឲ្យសម្រេចប្រយោជន៍ តាមចំណង់របស់មនុស្សអ្នកត្រូវការដោយស្រួលទៅបាន លុះតែអាស្រ័យដោយពួកអ្នកធ្វើនោះចេះច្បាប់ និង មានភាពប៉ិនប្រសប់លៃលករចនាឲ្យដឹងថាសម ឬ មិនសមផង ទើបកិច្ចការនោះៗ កើតឡើងហើយជាទីគាប់ចិត្តនៃអ្នកដទៃ ទាំងអាចឲ្យសម្រេចផលប្រយោជន៍ដល់អ្នកធ្វើនោះ ច្រើនថែមទៀតផង យ៉ាងណាមិញ,ពួកពុទ្ធបរិស័ទ អ្នកធ្វើទានគួរតែសិក្សាច្បាប់របស់ទានឲ្យបានចេះដឹងសព្វគ្រប់ជាមុន ដើម្បីចៀសវាងកុំឲ្យមានការទាស់ខុសឆ្គងពីពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាតក្នុងវេលាដែលបរិច្ចាគទានម្ដងៗទើបទាននោះឯងអាចឲ្យសម្រេចប្រយោជន៍គឺ ផលានិសង្សដល់ម្ចាស់ទានច្រើន ។

# សេចក្ដីថ្លែងអំណរព្រះគុណ និងអរគុណ

ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុសច្ចសីលោ ស្ងួន ចំរើន សូមថ្លែងអំណរព្រះគុណ និង អរគុណយ៉ាងជ្រាលជ្រៅ ចំពោះ ៖

-មាតាបិតា បង្កើត និង មាតាបិតាចិញ្ចឹមទាំងអស់ បងប្រុស បងស្រីដែលជាសាលោហិតអ្នកដទៃសោះ តែអ្នកទាំងអស់គ្នាស្រឡាញ់ខ្ញុំដូចកូន និង ប្អូនបង្កើត ទោះអ្នកមិនបានឲ្យកំណើត តែពួកអ្នកបានធ្វើប្រយោជន៍ជាច្រើនសម្រាប់រូបខ្ញុំ ដែលមិនអាចគ្រាគណនាបាន ប្រមាណពុំអស់ ។

-ព្រះគ្រូឧបជ្ឈាយ៍ខ្ញុំពីសាមណេរព្រះនាម "**ប៉ែន ឡេង**" អនុគណស្រុកទឹកផុស កាលខ្ញុំឧបសម្បទាជាភិក្ខុ ឧបជ្ឈាយ៍ព្រះនាម **បណីតធម្មោ** "**សុខ ថាន** " ព្រះមេគណខេត្តសព្វថ្ងៃ និង ឧសម្បទាចារ្យ **សុវណ្ណជោតោ ជា ពេជ្ជ** និង ឧបសម្បទាចារ្យ **សារធម្មោ ភេង សុផល** ។

-លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ដែលបង្រៀនខ្ញុំតាំងពីកម្រិតបឋមសិក្សា រហូតដល់បញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ។

-ក្រុមសមណមិត្តផ្សព្វផ្សាយព្រះធម៌ក្នុងកម្មវិធីព្រះពុទ្ធសាសនា និងសង្គមខ្មែរ ខេត្តកំពង់ឆ្នាំងទាំងអស់អង្គ ។

-ពុទ្ធបរិស័ទទូទៅដែលបានចូលរួមឧបត្ថម្ភសៀវភៅព្រះធម៌នេះ ។

សូមជូនបុណ្យដែលកើតពីធម្មទាននេះជូនដល់មាតាបិតា និងបងប្អូនរបស់ខ្ញុំ ប្រគេនកុសលនេះដល់ព្រះឧបជ្ឈាយាចារ្យរបស់ខ្ញុំ ព្រមទាំងជូនចំណែកបុណ្យទាំងនេះ ដល់ពុទ្ធបរិស័ទទាំងអស់ ឲ្យបានប្រកបជួបទៅនឹងពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ គ្រប់ៗគ្នាកុំបីខាន ។

# ឧទ្ទិសកថា

ខ្ញុំព្រះករុណា អាត្មាភាពសូមឧទ្ទិសបុណ្យកុសល ដែលកើតឡើងអំពីសេចក្តីព្យាយាមអត់ធន់ ដកស្រង់ ប្រមូលរៀបរៀងសៀវភៅនេះ ជូនចំពោះមាតាបិតា គុណគ្រូឧបជ្ឈាយាចារ្យ ញាតិការ ៧ សន្តាន ដែលមានជីវិតរស់នៅសព្វថ្ងៃនេះក្តី ដែលបានចែកស្ថានទៅហើយក្តី សូមអនុមោទនាកុសលផលបុណ្យ នៃធម្មទាននេះដោយចិត្តជ្រះថ្លា ហើយសូមឲ្យបានសម្រេចនូវសម្បត្តិទាំងឡាយ ៣ ប្រការគឺ សម្បត្តិមនុស្ស សម្បត្តិទេវតា និង សម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណា អាត្មាភាពសូមឲ្យ អស់លោកមិត្តអ្នកអានបានជួបប្រទះនូវពុទ្ធពរទាំងឡាយ បួន ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសាសនាព្រះសមណគោតមព្រះបរមគ្រូ មានអាយុកាលយឺនយូរគ្រប់កំណត់ ៥០០០ ព្រះវស្សា ដើម្បីជាម្លប់សាខាដ៏ត្រជាក់ត្រជុំ ដល់សត្វលោកទាំងឡាយក្នុងត្រៃភព ។

សូមឲ្យសេចក្តីបរិសុទ្ធិ ស្ថិតនៅក្នុងសន្តានចិត្តសត្តនិករជានិច្ចនិរន្តរ៍!

សូមសុខសន្តិភាព កើតមានដល់ប្រជាជនកម្ពុជា!

សូមឲ្យព្រះពុទ្ធសាសនា រីកចម្រើនរុងរឿង!

សូមសុខសន្តិភាព រីកចម្រើនក្នុងកម្ពុជរដ្ឋ!

*វត្តអារញ្ញិការាម,ថ្ងៃ ១៥ កើត ខែ ភទ្របទ*

*ឆ្នាំម្សាញ់ បញ្ចស័ក ព.ស ២៥៥៧*

# មាតិកា

**សារបញ្ញ័** **ទំព័រ**


អារម្ភបទ ........................................................ II
សេចក្ដីថ្លែងអំណរគុណ ........................................................ III
ឧទ្ទិសកថា ........................................................ IV
មាតិកា ........................................................ V
ប្រវត្តិទាន ........................................................ ១
ជីវិតសត្វលោកពិតត្រូវការអាហារ ........................................................ ៣
ទានក្នុងព្រះវិន័យបិដកមាន ៤ យ៉ាង ........................................................ ៥
១- ចីវរប្បច្ច័យ ........................................................ ៥
២- បិណ្ឌបាតប្បច្ច័យ ........................................................ ៦
៣- សេនាសនប្បច្ច័យ ........................................................ ៨
៤- គិលានភេសជ្ជប្បច្ច័យ ........................................................ ១០
ធ្វើទានបច្ច័យ ៤ ចំពោះសង្ឃ ........................................................ ១៣
ទានក្នុងសុត្តន្តបិដក (ព្រះសូត្រ) មាន ១០ យ៉ាង ........................................................ ១៤
ទានក្នុងព្រះអភិធម្មមាន ៦ យ៉ាង ........................................................ ១៥
ទានប្បញ្ហា ........................................................ ១៧-៨៨
ទានានិសង្ស ........................................................ ៩០
-អានិសង្សទឹកឃ្មុំ ........................................................ ៩១
-អានិសង្សឱសថព្យាបាលជំងឺ ........................................................ ៩១

-អានិសង្សថ្វាយទឹក ........................................................ ៩២
-អានិសង្សភេសជ្ជៈ ........................................................ ៩២
-អានិសង្សសប្បិ (ទឹកដោះថ្លា) ........................................ ៩៣
-អានិសង្សបាយ និង ទឹក ................................................ ៩៣
-អានិសង្សទឹកដោះរាវ ................................................... ៩៤
-អានិសង្សទឹកដោះជូរ .................................................... ៩៤
-អានិសង្សស្បែកជើង (ស្បែកសុទ្ធ)...................................... ៩៤
-អានិសង្សបោសសម្អាត ................................................... ៩៥
-អានិសង្សកសាងព្រះចេតិយខ្សាច់ ...................................... ៩៥
-អានិសង្សជម្រះស្មៅ ឈើ វល្លិ៍ លើព្រះចេតិយ ........................ ៩៦
-អានិសង្សដាំសួនច្បារ ..................................................... ៩៦
-អានិសង្សកសាងខឿននៃដើមពោធិព្រឹក្ស.................................. ៩៧
-អានិសង្សបូជាសរីរៈព្រះពុទ្ធ ............................................. ៩៧
-អានិសង្សថ្វាយបង្គំព្រះពុទ្ធ................................................ ៩៧
-អានិសង្សបូជាប្រទីបចំពោះព្រះពុទ្ធ ..................................... ៩៨
-អានិសង្សប្រទីប.............................................................. ៩៨
-អានិសង្សផ្កាឈូក ........................................................... ៩៩
-អានិសង្សយកទឹកអប់ក្រអូបបូជាព្រះសម្ពុទ្ធ ............................ ៩៩
-អានិសង្សលោកិយសរណគមន៍ ១០ យ៉ាង ............................. ១០០
-អានិសង្សដល់នូវត្រៃសរណគមន៍......................................... ១០០
-អានិសង្សថ្វាយបង្គំព្រះរតនត្រៃ ១០ យ៉ាង ............................ ១០១

-អានិសង្សសីល ៥ ..................................................... ១០២
-អានិសង្សឧបោសថ ..................................................... ១០២
-អានិសង្សអ្នកបួស ៧ ថ្ងៃ ..................................................... ១០៣
-អានិសង្សនៃបព្វជ្ជា និង ឧបសម្បទា ..................................................... ១០៣
-អានិសង្សបូជាផ្កាម្លិះ ..................................................... ១០៤
-អានិសង្សថ្វាយផ្កាជាវិការៈនៃមាស ..................................................... ១០៤
-អានិសង្សថ្វាយផ្កាឈូក ..................................................... ១០៥
-អានិសង្សអ្នកទំនុកបម្រុងអារាម ..................................................... ១០៥
-អានិសង្សឧបដ្ឋាក ..................................................... ១០៥
-អានិសង្សវេយ្យាវច្ច ..................................................... ១០៥
-អានិសង្សសំពត់ ..................................................... ១០៦
-អានិសង្សធ្វើផ្លូវ ..................................................... ១០៦
-អានិសង្សធ្វើស្ពាន ..................................................... ១០៦
-អានិសង្សផលរបស់ទាន ..................................................... ១០៧
-អានិសង្សផលរបស់បុណ្យ ..................................................... ១០៨
-អានិសង្សបុណ្យ ៥ យ៉ាង ..................................................... ១១០
-កម្មឲ្យផលផ្សេងគ្នា ៧ យ៉ាង ..................................................... ១១០
-កឋិនានិសង្ស ..................................................... ១១១
-អានិសង្សម្ចាស់កឋិនទាន ..................................................... ១១៥
-កឋិនជាសង្ឃកម្មពិសេស ..................................................... ១១៩
-បាលីវេរកឋិន ..................................................... ១២១

**នមត្ថុ រតនត្តយស្ស** សូមនមស្សការចំពោះព្រះរតនៈត្រៃ !

# ប្រវត្តិនៃទាន

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់ដឹងឡើងក្នុងលោក ព្រះអង្គបានសម្ដែងពន្យល់ពុទ្ធបរិស័ទពីការឲ្យទាន ដោយន័យច្រើនជាអនេក បានទាំងទ្រង់ប្រដៅវិធីក្នុងការបរិច្ចាគទាន ដោយសព្វគ្រប់សឹងមានប្រាកដមកក្នុងគម្ពីរដោយច្រើន ព្រះអង្គទ្រង់យល់ឃើញគុណគឺការបរិច្ចាគទាន ឬ ការបំពេញទាននេះ ជាកល្យាណវត្តមួយដ៏វិសេស ដែលប្រកាន់ជាប់ជាបវេណីមកតាំងពីមុនពុទ្ធកាល ហើយចាត់ជាមង្គលមួយដ៏ប្រសើរ របស់សប្បុរសទាំងឡាយ និង ជាទានបារមីនៃព្រះពុទ្ធគ្រប់អង្គត្រូវបំពេញផងដែរ ។

ចំណែកខាងភោគសម្បទទាំងអស់ក្នុងលោកនេះ រមែងកើតទៅជាទោសក៏មានទៅជាគុណក៏មាន ។ ភោគសម្បទណាដែលនៅក្នុងកណ្ដាប់ដៃរបស់មនុស្សល្ងង់ខ្លៅ ជាអ្នកមិនយល់ប្រយោជន៍ដ៏ធំទូលាយក្នុងកាលឥឡូវនេះ និងកាលខាងមុខ ភោគសម្បទនោះនឹងត្រឡប់ទៅជាទោសដល់ខ្លួនជាម្ចាស់វិញដោយពិត ជួនកាលគ្រាន់តែជាកណ្ដាលៗ មិនសម្រេចប្រយោជន៍ដ៏ធំទូលាយតទៅទៀតក៏មាន ដូចអ្នកមានប្រទីបសម្រាប់អុជបំភ្លឺ តែបើម្ចាស់មិនបានអុជបំភ្លឺទេ ក៏មិនមានប្រយោជន៍អ្វីអំពីប្រទីបនោះឡើយ ។

ភោគសម្បទណា ដែលស្ថិតនៅក្នុងដៃរបស់មនុស្សអ្នកចេះដឹង ជាអ្នកយល់ប្រយោជន៍ដ៏ធំទូលាយ ភោគសម្បទនោះនឹងត្រឡប់ទៅជាគុណដល់ខ្លួនជាម្ចាស់វិញជាប្រាកដ ។ ឯទ្រព្យសម្បត្តិដែលជាគុណ ឬប្រយោជន៍នោះ គឺសម្រាប់ចាយវាយចិញ្ចឹមជីវិត (ខ្លួន) ទំនុកបម្រុងមាតាបិតាគ្រូអាចារ្យ និង អន្តោជន ពាហិរជន គឺ បុត្រភរិយា ទាសកម្មករ ធ្វើទក្ខិណាទានចំពោះ

បព្វជិតក្នុងព្រះពុទ្ធសាសនា ដើម្បីជាបុញ្ញនិធិរបស់ខ្លួន ធ្វើពលី ៥ យ៉ាង មានញាតិពលី ជាដើម ។ ការប្រើប្រាស់ទ្រព្យសម្បត្តិបែបនេះ ឈ្មោះថា ពង្រីក ឬ បណ្ដុះទ្រព្យសម្បត្តិ ឲ្យបានទៅជាគុណ ជាប្រយោជន៍ចម្រើនទូលាយទាំងឥធលោក (លោកនេះ) និង បរលោក (លោកខាងមុខ) ។

មួយទៀតជនណាជាគ្រហស្ថ មានប្រាជ្ញានៅគ្រប់គ្រងផ្ទះ កាលបើបានលៃលកធនធានឲ្យទានទុកជាកំណប់ ជននោះឈ្មោះថាបានជញ្ជូនទ្រព្យសម្បត្តិទុកដាក់ឲ្យផុតចាកសេចក្ដីអន្តរាយ ដើម្បីជាប្រយោជន៍តទៅ សមដូចពុទ្ធភាសិតថាៈ *«កាលបើផ្ទះត្រូវភ្លើងឆាបឆេះជនម្ចាស់ផ្ទះតែងជញ្ជូនទ្រព្យសម្បត្តិ មានភាជនៈ ជាដើម ចេញអំពីផ្ទះ ទ្រព្យណាដែលគេប្រញាប់ជញ្ជូនចេញផុត ភ្លើងឆេះមិនបាន ទ្រព្យសម្បត្តិនោះ រមែងបានទៅជាប្រយោជន៍របស់គេតទៅទៀត យ៉ាងណាមិញ សត្វលោកដែលត្រូវភ្លើងគឺជរា និង មរណៈឆាបឆេះ គួរប្រញាប់ជញ្ជូនចេញឲ្យផុតអំពីផ្ទះ គឺ រាងកាយដោយការឲ្យទាន ព្រោះថា ទាន ដែលគេឲ្យហើយនោះឯង ឈ្មោះថាបានជញ្ជូនទ្រព្យទុកដោយល្អ មិនឲ្យភ្លើងឆេះបាន ក៏យ៉ាងនោះដែរ »* ។

សេចក្ដីនេះបំភ្លឺឲ្យឃើញថា កាលបើផ្ទះ គឺ រាងកាយត្រូវភ្លើង គឺ ជរា និង មរណៈ ឆាបឆេះ ទ្រព្យសម្បត្តិដែលនៅក្នុងកំណាន់របស់ជនមច្ឆរិយៈ ដែលគេមិនប្រញាប់ជញ្ជូនយកចេញ ដោយការបំពេញទានទេ ក៏មុខជានឹងត្រូវភ្លើងជរា និង ភ្លើងមរណៈ ឆាបឆេះខ្ទេចខ្ទី ជាមួយនឹងរាងកាយទៅជារបស់ឥតមានសារប្រយោជន៍ខ្លឹមសារមិនខាន ព្រោះហេតុនោះបានជាព្រះសម្ពុទ្ធទ្រង់សម្ដែងពន្យល់ អំពីគុណសម្បត្តិ គឺការឲ្យទានជារឿយៗ ដើម្បីឲ្យកើតប្រយោជន៍ដ៏ធំទូលាយអំពីទ្រព្យសម្បត្តិនោះៗ ក៏យ៉ាងដូច្នោះដែរ ។

# ជីវិតសត្វលោកពិតត្រូវការអាហារ

ជីវិតរបស់សព្វសត្វក្នុងលោកនេះ ដែលនឹងអាចរស់តាំងនៅបាន អាស្រ័យដោយរាងកាយ រាងកាយដែលនឹងប្រព្រឹត្តទៅបាន ក៏ត្រូវអាស្រ័យដោយអាហារ ទើបជីវិតរបស់សត្វនោះៗអាចរស់នៅបាន ការរក្សាជីវិតរបស់សត្វលោកទាំងអស់ជាភារៈយ៉ាងធ្ងន់បំផុត សាច់ឈាម ស្បែកសរសៃ ពណ៌សម្បុរ ដែលចម្រើនស្រស់បស់ឡើងបាន ក៏ព្រោះអាស្រ័យអាហារ កាលបើប្រាសចាកអាហារហើយ សន្តតិរូប គឺរូបដែលចម្រើនជាប់តទៅនោះក៏ឈប់ចម្រើន រាងកាយទាំងមូលក៏ស្វិតស្រពោនថយចុះទៅជាលំដាប់ ទាំងជីវិតទៀតសោតក៏តាំងនៅបានដោយក្រ ។

អាហារជារបស់សំខាន់សម្រាប់ឧបត្ថម្ភជីវិតឲ្យប្រព្រឹត្តទៅ សមដូចព្រះពុទ្ធដីកាថា " **សព្វេ សត្តា អាហារដ្ឋិតិកា** " ពួកសត្វរាល់រូបមានជីវិតតាំងនៅបានក៏ព្រោះអាហារ ។ វត្ថុដទៃក្រៅពីអាហារនោះទៀត ជនជាតិជាមនុស្ស ត្រូវមានលំនៅសម្រាប់ជ្រកកោន, សំពត់សម្រាប់ស្លៀកដណ្ដប់,ថ្នាំសម្រាប់កែរោគក្នុងគ្រាដែលត្រូវការ វត្ថុទាំងអម្បាលនេះ សុទ្ធតែជារបស់សម្រាប់ឧបត្ថម្ភទប់ទល់ជីវិតដោយពិត ព្រោះហេតុនោះមនុស្ស សត្វក្នុងលោក បើប្រាសចាករបស់ណាមួយ ជីវិតរមែងតាំងនៅបានដោយលំបាក ឬតាំងនៅពុំបានសោះឡើយ ។

ជនជាតិមនុស្សនីមួយៗលុះតែមានចំណេះវិជ្ជា ឬ កម្លាំងកាយ កម្លាំងប្រាជ្ញាបរិបូណ៌ ទើបអាចស្វែងរកអាហារបរិភោគបាន រកទីអាស្រ័យនៅ និងគ្រឿងប្រើប្រាស់សម្រាប់ជួយជីវិតបានគ្រប់គ្រាន់ល្អ ។ ចំណែកខាងមនុស្ស

ដែលគ្មានចំណេះវិជ្ជា និងខ្សោយកម្លាំង ឬ ឥតគុណសម្បត្តិណាមួយក្នុងខ្លួន ក៏មិនអាចនឹងរក្សាជីវិត រាងកាយឲ្យរស់នៅតាមទំនើងខ្លួនឯងបានឡើយ ។ មនុស្សបែបនេះត្រូវអាស្រ័យពឹងផ្អែកនឹងអ្នកដទៃ ឲ្យគេជួយចិញ្ចឹមជីវិតខ្លួនជាដរាប ព្រោះមនុស្សទាំងអស់ក្នុងលោករមែងមានវាសនា ឬ គុណសម្បត្តិកម្លាំងផ្សេងៗគ្នា ។ ចំណែកខាងមនុស្សដែលខ្សត់ខ្សោយវាសនា និងគុណសម្បត្តិ ឬ ខ្សោយកម្លាំងកាយនឹងសម្ងំនៅតាមទំនើងខ្លួនឯងមិនបាន ត្រូវធ្វើសមាគមគប់រកមនុស្សដែលបរិបូណ៌វាសនា និង គុណសម្បត្តិ ឬ កម្លាំងកាយ ឲ្យជួយណែនាំបង្ហាត់បង្រៀន ជួយជ្រោមជ្រែងដោយទ្រព្យរបស់ ឬ ភោជនាហារសម្រាប់ចិញ្ចឹមជីវិត ។ មនុស្សដែលមានវាសនា និងគុណសម្បត្តិខ្ពង់ខ្ពស់ ក៏ត្រូវតែទទួលអភិបាលរក្សាមនុស្សដែលខ្សត់ខ្សោយវាសនានៅទន់ខ្សោ ឬ ថោកទាបជាងខ្លួនដោយកិច្ចប្រៀនប្រដៅ និង ទ្រព្យ-សម្បត្តិជាដើមទុន ឬ អាហារសម្រាប់បរិភោគរាល់ថ្ងៃជាដរាប ដូចមាតាបិតាជាប្រធាននៃបុត្រធីតា ។ ព្រោះហេតុនោះ ការឲ្យអាហារ ឬ គ្រឿងប្រើប្រាស់គ្រប់យ៉ាងនេះ ជាកល្យាណប្បវេណី ជាទំនៀមមួយ ដ៏វិសេសជាប់មកតាំងអំពីមុនពុទ្ធកាល តាមភាសាបាលីលោកហៅថា " **ទាន** " ប្រែថា អំណោយ, ការឲ្យ, អ្វីៗដែលគួរឲ្យ ។

*តើពាក្យថា ទាន នេះនៅក្នុងព្រះពុទ្ធសាសនា មានអត្ថន័យ អត្ថរស និង ខ្លឹមសារយ៉ាងណា ? មានប៉ុន្មានយ៉ាង ? ការធ្វើទាននេះ ទទួលបានផលានិសង្សយ៉ាងដូចម្តេច ? ហើយវាមានសារប្រយោជន៍យ៉ាងណាខ្លះដល់សង្គមមនុស្សយើង ? តើមនុស្សយើងអាចរស់នៅក្នុងលោកនេះ ដោយមិនចាំបាច់ត្រូវការទានពីអ្នកដទៃបានដែរឬទេ ? សូមតាមដាន សិក្សាទាំងអស់គ្នាស្តីអំពី " ទាន " ដូចតទៅ...!*

# ទានក្នុងព្រះវិន័យបិដកមាន ៤ យ៉ាងគឺៈ

១-**ចីវរទាន** ជាគ្រឿងអាស្រ័យ គឺចីវរមានសំពត់សម្រាប់ងូតទឹកភ្លៀងរបស់ភិក្ខុ សាមណេរ ជាដើម ។

២-**បិណ្ឌបាតទាន** ជាគ្រឿងអាស្រ័យ គឺ ចង្ហាន់បិណ្ឌបាតដែលមាន ខាទនីយភោជនីយាហារ ( បង្អែម និងចម្អាប ) ជាដើម ។

៣-**សេនាសនទាន** ជាគ្រឿងអាស្រ័យ គឺ ទីជ្រកកោន ទីស្នាក់អាស្រ័យ ទីដេក ទីអង្គុយ មានកុដិ សាលា ព្រះវិហារ គ្រែ តុ ទូ ជាដើម ។

៤-**គិលានភេសជ្ជទាន** ជាគ្រឿងអាស្រ័យ គឺ ថ្នាំកែរោគគ្រប់ប្រភេទ មានទឹកដោះគោ តែ ស្ករ កាហ្វេ ទឹកឃ្មុំ ទឹកអំពៅ ទឹកត្នោត និងឱសថសម្រាប់ព្យាបាលរោគផ្សេងៗ ទៀត ជាដើម ។

***សេចក្ដីអត្ថាធិប្បាយ***

**១-ចីវរប្បច្ច័យ** ជាគ្រឿងអាស្រ័យ គឺ **ចីវរ** ប្រែថា សំពត់ដែលភិក្ខុគប្បីសន្សំ ឬ សំលៀកបំពាក់ សម្រាប់បិទបាំងអត្តភាព ។

ចីវរ ឬ ចីពរនេះ ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់អនុញ្ញាតឲ្យភិក្ខុសាមណេរប្រើប្រាស់បាន ។ ភិក្ខុ សាមណេរដែលមកបួសនៅក្នុងព្រះពុទ្ធសាសនានេះ សុទ្ធតែអាស្រ័យដោយសំពត់ចីវរនេះទាំងអស់គ្នា ដើម្បីជាគ្រឿងការពាររារាំងនូវត្រជាក់ផង នូវកម្ដៅថ្ងៃផង នូវសម្ផស្សផង នូវរបោមមូស ខ្យល់ ពស់តូចពស់ធំទាំងឡាយផង និងដើម្បីបិទបាំងនូវអវយវៈដែលធ្វើសេចក្ដីអៀនខ្មាសឲ្យកើតឡើងផង ។ម្យ៉ាងទៀតសំពត់ចីវរនេះអាចញ៉ាំងសម្បុរកាយរបស់ភិក្ខុ សាមណេរជាអ្នកប្រើប្រាស់ឲ្យមានសភាពភ្លឺថ្លាស្រស់ល្អ ។ ដូច្នេះហើយ ទាយក ទាយិកាដែលមានសទ្ធាជ្រះថ្លា បានចាត់ចែងឲ្យ

សំពត់ជាទាន ទើបបានឈ្មោះថា ឲ្យពណ៌សម្បុរល្អ ដល់អ្នកទទួលប្រើប្រាស់នោះ ។ សមដូចនៅក្នុងគម្ពីរសំយុត្តនិកាយត្រង់ទេវតាសំយុត្ត បានសម្តែងថា ក្នុងសម័យមួយព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់មានព្រះជន្មនៅឡើយ មានទេវតាមួយអង្គ ក៏បានចូលមកទូលសួរចំពោះព្រះអង្គថាៈ **កឹំទទោ វណ្ណទោ ហោតិ** *បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលឲ្យរបស់អ្វីជាទាន ទើបបានឈ្មោះថា ឲ្យពណ៌សម្បុរ ?*

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់តបទៅនឹងពាក្យទេវតានោះថា **វត្ថទោ ហោតិ វណ្ណទោ** បុគ្គលឲ្យនូវសំពត់ជាទាន ទើបបានឈ្មោះថា ឲ្យពណ៌សម្បុរ គឺបានឈ្មោះថា ឲ្យវណ្ណទាន ដល់អ្នកទទួលប្រើប្រាស់ក្នុងបច្ចុប្បន្នជាតិនេះ ហើយយើងជាម្ចាស់ទាននោះ តែងបានជាអ្នកមានពណ៌សម្បុរល្អ សម្បូរគ្រឿងស្លៀកពាក់ និង ទ្រព្យសម្បត្តិក្នុងអនាគតជាតិមិនខានឡើយ ។ ព្រោះហេតុនោះបានជាបុគ្គលដែលមានសទ្ធាជ្រះថ្លា បានឲ្យនូវសំពត់ចីវរជាទាន ដល់អ្នកមានសីល រមែងមានផលានិសង្សច្រើន ។

**២-បិណ្ឌបាតប្បច្ច័យ** ជាគ្រឿងអាស្រ័យ គឺចង្ហាន់បិណ្ឌបាត ។ ពាក្យថា **បិណ្ឌបាត** បានសេចក្តីថា ដុំនៃអាមិស មានបាយទឹក នំ ចំណី និងផ្លែឈើជាដើម ដែលជារបស់គួរដល់ការទំពារស៊ី (បរិភោគ) គួរដល់ការលេបទៅក្នុងបំពង់កបាន សរុបឲ្យខ្លីមកលោកហៅថា បិណ្ឌបាតទាំងអស់ ។ ពាក្យថាអាហារ លោកសំដៅយកខាទនីយៈ និង ភោជនីយាហារទាំងឡាយដែលត្រូវបរិភោគដើម្បីញ៉ាំងនូវជីវិតនេះ ឲ្យរស់បានដោយងាយស្រួល ។ ភិក្ខុ សាមណេរ ដែលជាអ្នកបួសនៅក្នុងព្រះពុទ្ធសាសនា ត្រូវអាស្រ័យនូវអាហារបិណ្ឌបាតទាំងនេះ ទើបអាចមានកម្លាំងប្រព្រឹត្តនូវព្រហ្មចរិយធម៌ ឬអាចញ៉ាំងជីវិតិន្ទ្រីយ៍ ពោលគឺរាងកាយទាំងមូលនេះឲ្យប្រព្រឹត្តទៅបាន ។

បើអត់អាហារបិណ្ឌបាតនេះហើយ អ្នកបួសគ្រប់រូបទាំងអស់ មិនអាចនឹងទ្រទ្រង់ផ្នួសតទៅទៀតបានឡើយ ព្រោះថាអាហារបិណ្ឌបាតនេះជារបស់សំខាន់ខ្លាំងណាស់សម្រាប់ភិក្ខុ សាមណេរទាំងអស់នោះ ហើយក៏ជាអាហារសប្បាយរបស់អ្នកបួសផងដែរ ។

មិនត្រឹមតែអ្នកបួសម្យ៉ាងប៉ុណ្ណោះទេ តែថាអាហារបិណ្ឌបាតនេះ ក៏ជាតម្រូវការដ៏ចាំបាច់បំផុតសម្រាប់មនុស្សសត្វ ក្នុងលោកគ្រប់រូបហើយមនុស្សសត្វគ្រប់រូបទាំងអស់នោះ ដែលមានជីវិតរស់នៅបានសុទ្ធតែ អាស្រ័យដោយសារតែអាហារនេះទាំងអស់ ។ អ្នកដែលបានឲ្យនូវអាហារបិណ្ឌបាតទាំងនេះ ឈ្មោះថាបានឲ្យនូវកម្លាំង ដល់ភិក្ខុសាមណេរដែលជាអ្នកទទួលឆាន់ចង្ហាន់នោះៗ ឯង ។ ដូចនៅក្នុងគម្ពីរសំយុត្តនិកាយ ត្រង់ទេវតាសំយុត្តបានសម្តែងថា សម័យមួយព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់មានព្រះជន្មនៅឡើយ មានទេវតាមួយអង្គចូលមកទូលសួរ ចំពោះព្រះអង្គថា **កឹ ទទោ ពលទោ ហោតិ** *បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលឲ្យរបស់អ្វី ជាទានទើបបានឈ្មោះថា ឲ្យនូវកម្លាំង ?*

ព្រះដ៏មានព្រះភាគ ទើបទ្រង់ត្រាស់ឆ្លើយទៅនឹងពាក្យរបស់ទេវតានោះថា **អន្នទោ ពលទោ ហោតិ** បុគ្គលឲ្យបាយជាទាន ទើបបានឈ្មោះថាឲ្យនូវកម្លាំង ហើយក៏ឲ្យឈ្មោះថា ឲ្យពលទានដល់អ្នកប្រើប្រាស់ក្នុងពេលបច្ចុប្បន្នជាតិនេះ ហើយយើងជាម្ចាស់ទាននោះ តែងតែបានជាអ្នកសម្បូរដោយកម្លាំង និងមានទ្រព្យសម្បត្តិច្រើនក្នុងអនាគតជាតិ មិនខានឡើយ ។ ព្រោះហេតុនោះ បានជាបុគ្គលអ្នកមានសទ្ធាជ្រះថ្លា ទើបបានឲ្យនូវចង្ហាន់បិណ្ឌបាតជាទាន ដល់បុគ្គលអ្នកមានសីលនោះៗ រមែងបាននូវផលានិសង្សច្រើន ។

**៣-សេនាសនប្បច្ច័យ** ជាគ្រឿងអាស្រ័យ គឺសេនាសនៈ មានន័យ ថា ទីកន្លែងសម្រាប់ដេក និង សម្រាប់អង្គុយ ។ ចំណែកព្រះសង្ឃនៅក្នុង ព្រះពុទ្ធសាសនាវិញ ក៏ត្រូវតែមានទីកន្លែងសម្រាប់ស្នាក់អាស្រ័យ ដូចជា កុដិ សាលា ព្រះវិហារ គ្រែ តុ តាំង កៅអី ទូ និង ប្រដាប់ប្រដាផ្សេងៗ ជាដើម ។ សម្រាប់សិង សម្រាប់អង្គុយ និង សម្រាប់ស្នាក់អាស្រ័យ ដើម្បី ការពាររាំងនូវអន្តរាយទាំងឡាយមានភ្លៀង ខ្យល់ កម្តៅថ្ងៃ និង សត្វកាច សាហាវជាដើម ដើម្បីជាគ្រឿងញ៉ាំងឥរិយាបថទាំង ៤ មានដេក ដើរ ឈរ និង អង្គុយឲ្យប្រព្រឹត្តទៅទើបស្វែងរកសេចក្តីសុខបាន ប្រសិនបើប្រាសចាក ទីសេនាសនៈ ជាគ្រឿងញ៉ាំងឥរិយាបថ ឲ្យប្រព្រឹត្តទៅយ៉ាងនេះ តើឈ្មោះ ថាបាននូវសេចក្តីសុខមកពីណាកើត ? អ្នកណាបានឲ្យនូវ សេនាសនទាន នេះ ទើបបានឈ្មោះថាឲ្យនូវសេចក្តីសុខដល់អ្នកទទួលប្រើប្រាស់ ឬ ទាយកអ្នកថ្វាយ រមែងបាននូវសេចក្តីសុខគ្រប់យ៉ាង ថែមទាំងបាននូវបុណ្យ ទាំងយប់ ទាំងថ្ងៃ ទៀតផង ។ សមដូចសេចក្តី ដែលមានមក នៅក្នុងគម្ពីរ សំយុត្តនិកាយ នៅត្រង់ទេវតាសំយុត្តសម្តែងថា ៖

សម័យមួយព្រះបរមសាស្តា ស្តេចទ្រង់គង់ព្រះធរមាននៅឡើយ ក៏ មានទេវតាមួយអង្គ បានចូលមកទូលសួរ ចំពោះព្រះអង្គថា **យោ ច សព្វទទោ ហោតិ** *បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលឲ្យនូវរបស់អ្វីជាទាន ទើប បានឈ្មោះថា ឲ្យរបស់គ្រប់មុខ ?* ព្រះអង្គទ្រង់ត្រាស់ឆ្លើយតប ទៅនឹង ទេវតានោះថា **សោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ** *បុគ្គលណាបានឲ្យទីស្នាក់អាស្រ័យ ជាទាន បុគ្គលនោះឈ្មោះថា បានឲ្យ របស់គ្រប់មុខ ។*

ក្នុងគម្ពីរសំយុត្តនិកាយនេះដែរ មានសម្តែងតទៅទៀត ថា៖

មានទេវតាមួយអង្គ បានចូលទៅទូលសួរព្រះអង្គថា **គេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ** *បពិត្រព្រះអង្គដ៏ចម្រើន បុណ្យរមែងចម្រើនទាំងយប់ទាំងថ្ងៃសព្វៗកាលទាំងពួង តើដល់បុគ្គលពួកណាខ្លះ ?* ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា: **អារាមរោបា វនរោបា យេ ។ បេ ។ បុញ្ញំ បវឌ្ឍតិ ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។**

*ប្រែជាខេមរភាសា កាព្យថា:*

ជនណាដាំសួនផ្កាច្បារដើមឈើ
ធ្វើស្ពានសាងរោងរានឲ្យទានទឹក
ជីកស្រះអណ្តូងសម្រាប់ងូតផឹក
ទាំងថ្ងៃយប់ព្រឹកដល់ជននានា ។
ជនណាឲ្យទីសំណាក់អាស្រ័យ
ដល់អ្នកដទៃដោយចិត្តសទ្ធា
បុណ្យតែងចម្រើនកើនវឌ្ឍនា
គ្រប់ទិនទិវាដល់ជននោះៗ ។
ជននោះឈ្មោះថា តាំងនៅក្នុងធម៌
និងបរិបូណ៌ដោយសីលខ្ពង់ខ្ពស់
រមែងទៅកាន់សួគ៌ាសោឡស
ថ្កុំថ្កើងស្រួចស្រស់សុខសាន្តរីករាយ ។

ម្យ៉ាងទៀត សេនាសនទាននេះ ជាទានដែលមានអាយុកាលវែងជាងទានផ្សេងៗ ទៀត អាចប្រើប្រាស់បានយូរ មិនងាយខូចខាត ពេលខ្លះម្ចាស់អ្នកកសាងស្លាប់ទៅមុនហើយ ទីសេនាសនទាននោះនៅមិនទាន់ខូចក៏មានដែរ ។ ផលានិសង្សនៃការកសាង នូវទីសេនាសនទាននេះ បើនៅក្នុង

លោកីយ៍ រមែងធ្វើឲ្យបាននូវត្រកូលដ៏ខ្ពង់ខ្ពស់ ។ ព្រោះហេតុនោះ បានជាបុគ្គលដែលមានសទ្ធាជ្រះថ្លា បានឲ្យនូវទីសេនាសនៈជាទាន ដល់បុគ្គលអ្នកមានសីល រមែងបាននូវផលានិសង្សច្រើន ។

**៤-គិលានភេសជ្ជប្បច្ច័យ** គ្រឿងអាស្រ័យ គឺថ្នាំកែរោគ ។ ពាក្យថា គិលានភេសជ្ជៈ មានន័យថា ថ្នាំសម្រាប់ព្យាបាលជំងឺផ្សេងៗ ។ សព្វថ្ងៃនេះមានជំងឺ ជាច្រើនយ៉ាង ច្រើនបែបណាស់ មានធ្ងន់ មានស្រាល ជំងឺខ្លះអាចព្យាបាលឲ្យជាសះស្បើយបាន ជំងឺខ្លះទៀតក៏មិនអាចព្យាបាល ឲ្យជាសះស្បើយបានដែរ ។ មនុស្សយើងម្នាក់ៗ កាលណាបើបានដឹងថាខ្លួនមានជំងឺហើយ រមែងនៅមិនសុខឡើយ មានចិត្តរន្ធត់តក់ស្លុត មានសេចក្តីភ័យខ្លាច ដោយប្រការផ្សេងៗ ដូចជាភ័យខ្លាចអំពីការស្លាប់ជាដើម ហើយក៏ប្រឹងប្រែងស្វះស្វែង ព្យាយាមរកថ្នាំមក សម្រាប់ព្យាបាលជំងឺនោះ ។ ពេលខ្លះទៀត សូម្បីតែបានដឹងយ៉ាងប្រាកដហើយថា ជំងឺរបស់ខ្លួននោះ មិនអាចព្យាបាលបានក៏ដោយ ក៏មិនអាចសម្ងំនៅស្ងៀម រង់ចាំតែសេចក្តីស្លាប់នោះបានទេ ។ ដូច្នោះហើយមនុស្សយើងម្នាក់ៗ សុទ្ធតែត្រូវការថ្នាំព្យាបាលរោគនេះដូចគ្នាទាំងអស់ ដោយមិនអាចខ្វះបានឡើយ យ៉ាងណាមិញ ភិក្ខុសាមណេរ ដែលជាអ្នកបួសនៅក្នុងព្រះពុទ្ធសាសនានេះ ក៏ដូចគ្នាដែរ ។ លោកចេញមកអំពីត្រកូលផ្សេងៗ គ្នា មានខ្លះ ក្រខ្លះ ទៅតាមវង្សត្រកូលរៀងៗ ខ្លួន ។ ប៉ុន្តែនៅពេលចូលមកបួសជាព្រះសង្ឃ នៅជ្រកក្រោមដំបូលព្រះពុទ្ធសាសនាតែមួយ ដោយមានពុទ្ធបរិស័ទជាអ្នកទំនុកបម្រុង ព្រះពុទ្ធ-សាសនា ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ព្រះអង្គទ្រង់ត្រាស់សម្តែងថា: **អរោគា បរមា លាភា** *ការមិនមានរោគ គឺ ជាលាភដ៏ឧត្តមក្រៃលែង ។* ជាការពិតណាស់ ប្រការដែលមិនមានរោគទៅបាននោះ លុះត្រាតែដល់

ព្រមដោយបុណ្យ ដែលបានកសាងមកហើយផង ដល់ព្រមដោយការរក្សា ព្យាបាល នោះផង ។ មនុស្សដែលមានជំងឺរមែងមានអាយុខ្លី មានសេចក្ដីទុក្ខច្រើន ចង់ធ្វើអ្វីក៏មិនបានដូចបំណង ទៅទីណាក៏មិនកើត ទោះបីជាជំងឺនោះតិចតួចក៏ដោយ ឲ្យតែពាក្យថា មានជំងឺហើយ គឺមិនដែលចេះស្រួល និង មានសេចក្ដីសុខឡើយ ។ បុគ្គលដែលបានឲ្យថ្នាំសម្រាប់ព្យាបាលរោគ ឈ្មោះថា ឲ្យអាយុ គឺការរស់នៅយឺនយូរដល់អ្នកដទៃ ។ ព្រោះហេតុនោះហើយ បានជាបុគ្គលដែលមាននូវសទ្ធាជ្រះថ្លា បានឲ្យនូវគិលានភេសជ្ជៈជាទាន គឺថ្នាំកែរោគ ដល់បុគ្គលអ្នកមានសីល រមែងទទួលបាននូវផលានិសង្សច្រើន ។

បច្ច័យទាំង ៤ នេះ ជាទាន ដែលមានមកនៅក្នុងព្រះវិន័យ ដូច្នេះលុះត្រាតែបុគ្គលអ្នកឲ្យនោះ មានបញ្ញា ឆ្លាតឈ្លាស វាងវៃ ក្នុងការចាត់ចែងឲ្យត្រឹមត្រូវទៅតាមកិច្ចរបស់ព្រះវិន័យ ទើបបាននូវផលានិសង្សច្រើន ។ ឯកិច្ចព្រះវិន័យនោះ បានចាត់ចែងបច្ច័យទាំង ៤ នេះជាពីរក្រុម គឺ ចីវរប្បច្ច័យ និង សេនាសនប្បច្ច័យ ចាត់ជាក្រុមទី ១ បិណ្ឌបាតប្បច្ច័យ និង គិលាន-ភេសជ្ជប្បច្ច័យ ចាត់ជាក្រុមទី ២ ។

សម្រាប់ក្រុមទី ១ គឺ ចីវរប្បច្ច័យ និង សេនាសនប្បច្ច័យ ឲ្យឈ្មោះថា **ពាហិរបរិភោគ** មានន័យថា របស់ដែលមិនគួរដល់ការឆាន់ ឬ លេបកន្លងនូវបំពង់ ក បាន ។ បច្ច័យក្រុមទី ១ នេះ ពុទ្ធបរិស័ទគប្បី ធ្វើការចាត់ចែងយ៉ាងនេះ គឺ យើងគ្រាន់តែបវារណាលោក ដោយវាចាក៏បាន មិនចាំបាច់ប្រគេន ឲ្យត្រឹមត្រូវក៏បានឈ្មោះថាគួរដែរ ។ ឧទាហរណ៍ដូចជា ស្បង់ ចីវរ ចាន ស្លាបព្រា កន្ទេល ពូក ខ្នើយ ភួយ មុង កុដិ សាលា និង ព្រះវិហារ ជាដើម យើងមិនចាំបាច់ប្រគេនលោកទេ គ្រាន់តែពិតទូលលោក ដោយ

ពាក្យសម្ដី លោកក៏អាចទទួលប្រើប្រាស់បានដែរ គឺគ្មានត្រូវទោស ឬ ត្រូវអាបត្តិ លោកឡើយ ។ ព្រោះហេតុអ្វី ? ព្រោះតែបច្ច័យនៅក្នុងក្រុមទី ១ នេះ មិនមែនជារបស់ដែលត្រូវបរិភោគ ឬ លេបកន្លងចូលបំពង់ ក ទេ ។

ក្រុមទី ២ គឺ បិណ្ឌបាតប្បច្ច័យ និង គិលានភេសជ្ជប្បច្ច័យ ឲ្យឈ្មោះថា **មជ្ឈត្តិកបរិភោគ** មានន័យថា របស់ដែលគួរដល់ការឆាន់ ដែលត្រូវបរិភោគ ឬ ដែលលេបកន្លងទៅតាមបំពង់ ក បាន ។ បច្ច័យក្រុមទី ២ នេះ ពុទ្ធបរិស័ទគប្បីចាត់ចែងយ៉ាងនេះ គឺយើងត្រូវតែប្រគេនលោកឆាន់ ឲ្យបានត្រឹមត្រូវទៅតាមកិច្ចរបស់ព្រះវិន័យ ដែលព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តិទុកមក ។ វត្ថុទាំងនោះមាន បាយ ទឹក នំ ចំណី សាច់ កាហ្វេ ទឹកដោះគោ និង វត្ថុផ្សេងៗ ទៀតជាដើម ។ ដែលគួរលេបកន្លងបំពង់កបាន (សំដៅយករបស់ដែលឆ្អិនទើបគួរ) គឺយើងត្រូវប្រគេនឲ្យបានត្រឹមត្រូវទៅតាមអង្គនៃការប្រគេន ទើបព្រះសង្ឃអាចទទួលយកមកឆាន់បាន ដោយមិនត្រូវទោស ឬ មិនត្រូវអាបត្តិ ហើយយើងជាអ្នកធ្វើ នឹងទទួលបានអានិសង្សច្រើន ។

### *បិណ្ឌបាតពីរយ៉ាងដែលមានអានិសង្សច្រើនជាងគេ*

*១.បិណ្ឌបាតរបស់**នាងសុជាតា** ( ឆង្ហាន់ ឆាន់មុនបានត្រាស់ដឹង)*

*២.បិណ្ឌបាតរបស់**នាយចុន្ទ** ( ឆង្ហាន់ ឆាន់ហើយបរិនិព្វាន )*

-**ចីវរំ រូបំ ហោតិ** *ការឲ្យចីវរ ឈ្មោះថាឲ្យរូបល្អ*

-**បិណ្ឌបាតំ ពលំ ហោតិ** *ឲ្យអាហារ ឈ្មោះថាឲ្យកម្លាំង*

-**សេនាសនំ សុខំ ហោតិ** *ឲ្យទីសម្នាក់អាស្រ័យ ឈ្មោះថាឲ្យក្តីសុខ*

-**គិលានភេសជ្ជំ អរោគោ ហោតិ** *ឲ្យថ្នាំព្យាបាល ឈ្មោះថាមិនមានរោគ*

# ធ្វើទានបច្ច័យ ៤ ចំពោះសង្ឃ

អ្នកធ្វើបច្ច័យ ៤ បើកាលណាចាត់ចែងទេយ្យធម្មទាន បានសព្វគ្រប់បច្ច័យទាំង ៤ ហើយ ទោះបីលទ្ធភាពបានត្រឹមតែ ១ ប្រដាប់ក្ដី ២-៣-៤ ឬលើសចំនួនពីនេះទៅទៀតក្ដី រួចហើយចូលទៅវត្តអារាមណាមួយ ពិតទូលប្រធានសង្ឃថា " *សូមព្រះសង្ឃ មេត្តាចាត់ភិក្ខុ ១ រូប ២-៣-៤ ឬ លើសតាមតែអង្គណាក៏បាន និមន្តទៅទទួល* ***សង្ឃទាន*** *ឯផ្ទះខ្ញុំព្រះករុណាវេលាព្រឹកនេះ ឬ ស្អែកម៉ោងប៉ុណ្ណោះ* "។ បើការនិមន្តមានវិធីដូច្នេះ ទោះបីធ្វើតែនឹងភិក្ខុ ១ អង្គ ដែលសង្ឃចាត់មកនោះ ក៏ឈ្មោះថា **សង្ឃទាន** គឺបានធ្វើចំពោះសង្ឃពេញទី ស្រេចតែម្ដង ។

ចំពោះទាយកម្ចាស់ទាន កាលណាបើភិក្ខុដែលសង្ឃចាត់ និមន្តមកដល់ផ្ទះហើយ ត្រូវតាំងចិត្តថា **សង្ឃ** ទទួលបដិសណ្ឋារៈជា**សង្ឃ** តែម្យ៉ាង ទោះបីអ្នកនិមន្តមកនោះជា **សាមណេរ** ក៏ដោយ ។

**ការវេរបច្ច័យ ៤ ត្រូវគិតតាមចំនួនបដិគ្គាហក គឺចំនួនភិក្ខុអ្នកទទួល**

- បើភិក្ខុលើសពី ៤ អង្គឡើងទៅ ត្រូវវេរជាសង្ឃ, បើមានតែ ២-៣ អង្គ ត្រូវវេរជាគណៈ និង បើមានតែ ១ អង្គ ត្រូវវេរ ជាបុគ្គល ។

**ន័យនេះ សមនឹងអង្គសង្ឃទានមាន ២ យ៉ាងគឺ**

-ទាយក បានសុំនិមន្តលោក ដែលជាបដិគ្គាហក អំពីសំណាក់សង្ឃ

-កាលណា លោកដែលជាបដិគ្គាហក និមន្តមកដល់ផ្ទះខ្លួនហើយ ខ្លួនបានតាំងចិត្តចំពោះលើសង្ឃ តែម្យ៉ាង ។

*បើធ្វើត្រឹមត្រូវតាមកិច្ចយ៉ាងនេះបាន ឈ្មោះថា កើតជា* ***សង្ឃទាន*** *ពេញទី ហើយទទួលបានផលានិសង្សច្រើនទៀតផង ។*

## ទានក្នុងសុត្តន្តបិដក (ព្រះសូត្រ) មាន ១០ យ៉ាងគឺ:

**១-អន្នំ** បាយ សំដៅយកគ្រឿងបរិភោគបាន គឺ បង្អែម និងចំអាប ទាំងអស់បានដល់បាយ នំ ចំណី ត្រីសាច់ គ្រប់ប្រភេទដែលអាចហូបបាន។

**២-បានំ** ទឹក សំដៅយកទឹកបានទាំង ៨ យ៉ាង ធ្វើពីផ្លែចេកជាដើម

**៣-វត្ថំ** សំពត់ សំដៅយកសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្តប់ មាន ខោ អាវ សារ៉ុងស្បៃ មុង ភួយ កន្សែង ជាដើម ។

**៤-យានំ** យានជំនិះ សំដៅយកវត្ថុដែលជាគ្រឿងញ៉ាំងដំណើរឲ្យសម្រេច មានរថយន្ត ឡាន ម៉ូតូ ស៊ីក្លូ កង់ និងស្បែកជើងជាដើម ។

**៥-មាលា** ផ្កាកម្រង បានដល់ផ្កាម្លិះរួត ម្លិះលា ក្តាំងងា នួនស្រី ចំប៉ា ចំប៉ី លំចង់ ស្បង់ក្ដជ ដែលគេដោតក្រងជាកម្រងភួង ជាដើម ។

**៦-គន្ធំ** គ្រឿងក្រអូប សំដៅយកគន្ធជាតិទាំងអស់ និង គ្រឿងឧបករណ៍បានដល់គ្រឿងក្រអូប ដែលគេកិនហើយក្តី មិនទាន់បានកិនក្តី ។

**៧-វិលេបនំ** គ្រឿងលាប សំដៅយកវត្ថុធ្វើឲ្យស្បែកខាងក្រៅជាទីត្រេកអរ រលើបរលោង ភ្លឺថ្លា និងកំចាត់បង់នូវញើស ក្អែលមានសាប៊ូ ឡេ ។

**៨-សេយ្យំ** ទីដេក សំដៅវត្ថុជាទីដេក ទីអង្គុយបាន មានគ្រែ តាំងកន្ទេល ក្នល់ខ្នើយ ពូក ព្រំ ចៀមធំ និង កម្រាលផ្សេងៗ ទៀត ជាដើម ។

**៩-អាវសថំ** ទីលំនៅ សំដៅយកផ្ទះស្បូវ ផ្ទះក្បឿង ផ្ទះថ្ម តូប សាលាដំណាក់ កុដិ សាលា ព្រះវិហារ និងប្រាសាទ នានា ជាដើម ។

**១០-បទីបេយ្យំ** គ្រឿងបំភ្លឺ មានចង្កៀងគោម ចង្កៀងម៉ុងសុង ម៉ាស៊ីនភ្លើង អំពូលអគ្គីសនី ទៀនតូច ធំ ប្រេងប្រឆេះ និងប្រទីបជ្វាលាដទៃទៀត ជាដើម ។ *(ទានទាំង ១០ នេះសម្រាប់លះឲ្យជនទូទៅ មិនរើសមុខ)*

# ទានក្នុងព្រះអភិធម្មមាន ៦ យ៉ាងគឺ:

**១-រូបទាន** ការឲ្យរូបជាទាន
**២-សទ្ទទាន** ការឲ្យសម្លេងជាទាន
**៣-គន្ធទាន** ការឲ្យក្លិនជាទាន
**៤-រសទាន** ការឲ្យរសជាទាន
**៥-ផោដ្ឋព្វទាន** ការឲ្យសម្ផស្សជាទាន
**៦-ធម្មារម្មណទាន** ការឲ្យអារម្មណ៍តាមមនោទ្វារជាទាន ។

• ការឲ្យទានជារូបនោះ ពុំមែនឲ្យរូបមែនៗនោះទេ គឺកាមាវចរកុសល [១]ប្រារព្ធយករូបនៃបច្ច័យទាំង ៤ មានចីវរប្បច្ច័យជាដើម ការឃើញនូវបូជ-នីយវត្ថុ មានព្រះពុទ្ធបដិមា ព្រះចេតិយ ព្រះសង្ឃជាដើម ឬ ឃើញវត្ថុដែលគួរបរិច្ចាគ មានត្រៃចីវរជាដើមនោះមកជាអារម្មណ៍ ហើយឲ្យទៅជាទាន យ៉ាងនេះហៅថា **រូបទាន "ឲ្យទានរូប"** ។

• ការឲ្យសម្លេងជាទាននោះដូច្នេះ គឺប្រារព្ធយកការស្តាប់ធម៌ទេសនា ឬបានស្តាប់ព្រះសង្ឃចម្រើនព្រះបរិត្ត និង ថ្នាំកែសម្លេងក្តី សម្លេងឃោសនាឲ្យគេដឹងក្តី សម្លេងព្មពីឃោសនាមកក្តី សម្លេងជួងរគាំង ស្គរវាយឲ្យគេមកធ្វើបុណ្យកុសលមានការឲ្យទាន រក្សាសីលជាដើម យកសម្លេងទាំងអស់នេះមកជាអារម្មណ៍ ហើយឲ្យទានទៅ ឈ្មោះថា **សទ្ទទាន "ឲ្យទានសម្លេង"**

• ការឲ្យក្លិនជាទាននោះ គឺប្រារព្ធយកក្លិនផ្កាឈើ និង គ្រឿងក្រអូបមានទឹកអប់ជាដើមមកជាអារម្មណ៍ ហើយមានចិត្តនឹកបង្អោនចូលទៅ ដើម្បី

---

១ កាមាវចរកុសល៨ អាចឲ្យសម្រេចផលក្នុងកាមភពទាំង៧ គឺមនុស្សលោក១,សួគ៌៦ ជាន់

បូជាចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឬក៏បានខាងក្លិនស្អុយហើយតម្កល់ចិត្តជាកម្មដ្ឋាន គឺ អនិច្ចំ ទុក្ខំ អនត្តា ជាអារម្មណ៍ដោយខ្លួនឯង ។

- ការឲ្យរសជាទាននោះ គឺប្រារព្ធយកវត្ថុដែលមានរសឆ្ងាញ់មកជាអារម្មណ៍ ហើយនឹកដល់គុណព្រះរតនត្រ័យនាំយកទៅបូជា ។ និងបានខាងទទួលរសប្រៃ សាប ល្វីង ជូ ចត់ ខា ហឹរ ជាដើម ដែលជាទីពេញចិត្ត ហើយមានចិត្តជ្រះថ្លា គិតបរិច្ចាគទានដល់ស្មូមយាចក សមណព្រាហ្មណ៍ មាតាបិតា ឬ គ្រូឧបជ្ឈាយាចារ្យ លោកអ្នកមានសីល ។
- ការឲ្យសម្ផស្សជាទាននោះ គឺប្រារព្ធយកសម្ផស្សជាទីពេញចិត្តមានពូកគ្រែខ្នល់ខ្នើយ ឬ អាសនៈដ៏វិចិត្រជាដើម ហើយមានចិត្តជាកុសលកើតឡើងប្រាថ្នាបំពេញទានក៏នឹកដល់គុណព្រះរតនត្រ័យ នាំយកទៅបូជា ។
- ការឲ្យអារម្មណ៍ជាទាននោះ សំដៅយកចិត្តដែលនឹកដល់ឱវាទព្រះជិនស្រីដែលសម្តែងអំពីទាន ៣ យ៉ាងគឺៈ **ឱជទាន** (ភេសជ្ជៈ ៥ យ៉ាង), **បានទាន** (ទឹកទាំង ៨ យ៉ាង), **ជីវិតទាន** (សំដៅយកភត្តទាំង ១៤ មានសលាកភត្ត និង សង្ឃភត្តជាដើម ព្រោះថា ភិក្ខុសង្ឃដែលនឹងរស់នោះក៏អាស្រ័យនឹងភត្ត ១៤ ណាមួយ), ទានទាំង ៣ ដែលបានពោលមកនេះឈ្មោះថា ធម្មារម្មណ៍, បានជាឲ្យទៅជាទានកើត ព្រោះចិត្តនឹកទៅរកត្រង់ឱវាទដែលព្រះអង្គសម្តែងនោះមកជាអារម្មណ៍ ហើយឲ្យជាទាន ឈ្មោះថា (ហៅថា) **ធម្មារម្មណទាន** ។

# ទានបញ្ញា

(ខ្លឹមសារដើមឈ្មោះ ទានវិនិច្ឆ័យ)

*១.សំណួរ៖ ដូចម្តេច ដែលហៅថា **ទានប្បញ្ញា** ?*

ចម្លើយ៖ ដែលហៅថា ***ទានប្បញ្ញា*** គឺជាចំណោទ សំណួរ ឬ ប្រស្នាដែលរៀបរៀងឡើងដើម្បីដោះស្រាយអំពីបញ្ហាទាននានា ។

*២.សំណួរ៖ ពាក្យថា **ទាន** នេះប្រែបាន យ៉ាងដូចម្តេចខ្លះ ?*

ចម្លើយ៖ ពាក្យថា ទាន នេះប្រែថា ការឲ្យ ឬ អំណោយ ។

*៣.សំណួរ៖ **ទាន** ប្រែថា ការឲ្យ, អំណោយ តើគួរឲ្យដោយអាការៈយ៉ាងណាខ្លះ ? បើឲ្យដូច្នោះ ទាននោះហៅថាទានអ្វី ?*

ចម្លើយ៖ គួរឲ្យដោយអាការៈ ដូចខាងក្រោមនេះគឺៈ

- បុគ្គលមានចិត្តអាណិតអាសូរទន់ទោទៅរកមនុស្សសត្វដទៃ ហើយបានឲ្យគ្រឿងបរិភោគប្រើប្រាស់ដោយសេចក្តីអាណិតតែម្យ៉ាង មិនអាស្រ័យយកបំណាច់ ឬកម្លាំងប្រើប្រាស់ ការឲ្យទានបែបនេះ ហៅថា **ករុណាទាន**
- បុគ្គលយល់ច្បាស់នូវ គុណូបការៈ ឬ គុណសម្បត្តិណាមួយរបស់លោកអ្នកមានគុណ មានមាតាបិតា គ្រូអាចារ្យ ឬ លោកអ្នកទ្រទ្រង់នូវគុណមានសីលគុណជាដើម ក៏ធ្វើទានចំពោះអ្នកមានគុណនោះ ការឲ្យទានបែបនេះហៅថា **បូជាទាន** ឬ **បដិការទាន** ក៏បាន ។
- បុគ្គលមានចិត្តធូរទូលាយ ចង់ឲ្យប្រយោជន៍ ឲ្យសេចក្តីសុខ សេចក្តីចម្រើនដល់អ្នកដទៃដែលជាញាតិសាលោហិត ឬ មិត្តសម្លាញ់ ឬក៏មនុស្សរួមជាតិជាមួយគ្នា ដែលល្មមទទួលអំណោយការសង្គ្រោះបាន ហើយចែកទ្រព្យសម្បត្តិជាដើមទុនក្តី គ្រឿងបរិភោគគ្រឿងប្រើប្រាស់ក្តី ដើម្បីទុកបម្រុងជួយជាកម្លាំងសង្គ្រោះឲ្យកើតប្រយោជន៍ស្មើមុខគ្នាឡើង ការឲ្យទានដូច្នេះហៅថា **អនុគ្គហទាន** ឬ នឹងហៅថា **សង្គហទាន** វិញក៏បាន ។

*៤.សំណួរ៖ពាក្យ ទាន និង ចាគ មានសេចក្ដីដូចគ្នា ឬផ្សេងគ្នាយ៉ាងណាខ្លះ?*
ចម្លើយ៖ ពាក្យ **ទាន** និង **ចាគ** ទាំងពីរនេះបើពោលសំដៅយកសេចក្ដីឃើញប្រាកដថាផ្សេងគ្នាបើពោលតាមលក្ខណៈក៏ឃើញថាស្រដៀងៗគ្នា ។

***ទាន មានន័យ ៤ យ៉ាងដូចមានសេចក្ដីអធិប្បាយតទៅនេះគឺ:***

១- **ទាន** ការឲ្យវត្ថុណាមួយដែលនៅជាប់ជំពាក់ដោយមច្ឆរិយៈ ឬឲ្យដោយស្ទាក់ស្ទើរ មិនជ្រះស្រឡះចាកមច្ឆរិយៈ ឬ ឲ្យតាមទំនៀមទម្លាប់ត្រកូលរបស់គេ មិនមែនជាកិច្ចអស្ចារ្យ ចំឡែកជាងត្រកូលដែលធ្លាប់ធ្វើមកប៉ុន្មាន ។

២- **ទាន** ការឲ្យដោយជាប់ជំពាក់ដោយតណ្ហាគឺបុគ្គលអ្នកឲ្យទានមានប្រាថ្នាយកសិរីសួស្ដី និងផលប្រយោជន៍មកខ្លួនវិញចំពោះសាមិសសុខក្នុងជាតិនេះ ឬ ជាតិខាងមុខ ។

៣- **ទាន** ការឲ្យមិនសមគួរគឺបុគ្គលណាមានទ្រព្យសម្បត្តិច្រើនមានវត្ថុថ្លៃថ្លាច្រើនលុះត្រូវការចាត់ចែងទានក៏ចាត់ចែងធ្វើដោយរលីបរលោបស្ដួចស្ដើងនឹងវត្ថុដ៏ថោកទាបតាមធម្មតា ទានរបស់បុគ្គលនោះឈ្មោះថាជាទានមិនសមតាមសក្តិ តាមកម្លាំងនៃទ្រព្យសម្បត្តិដែលខ្លួនមាន ។

៤- **ទាន** ការឲ្យចំពោះមុខបដិគ្គាហក អ្នកទទួលផ្ទាល់ដែលជាបុគ្គលខ្សត់ខ្សោយដោយគុណធម៌ និងទ្រព្យសម្បត្តិ ឬ ខ្ពង់ខ្ពស់ដោយគុណធម៌ ជាដើម ទាំងនេះជាសេចក្ដីនៃពាក្យថា **ទាន** ។

***ចាគៈ មានសេចក្ដីអធិប្បាយ ៤ យ៉ាង ដែរគឺ:***

១- **ចាគៈ** លះវត្ថុណាមួយចំពោះបដិគ្គាហក ដើម្បីលះបង់ ឬសង្កត់សង្កិននូវលោភៈ និង មច្ឆរិយៈឲ្យស្រាលស្ដើងចាកសន្ដានគឺចំណាយ

ទ្រព្យធនដើម្បីទុកជាអលង្ការ ឬ ជាកល្យាណវត្តរបស់ចិត្ត មិនបណ្តោយឲ្យចិត្តឈ្លក់វង្វេងជាប់នូវក្នុងកិលេសផ្សេងៗ ។

២- **ចាគៈ** ការលះឲ្យដែលមិនជាប់ជំពាក់ដោយតណ្ហា គឺឲ្យដោយបំណងចំពោះនិរាមិសសុខ ដើម្បីធ្វើឲ្យចិត្តបរិសុទ្ធ បើកឱកាសឲ្យបញ្ញារបស់ខ្លួនមានកម្លាំងលូតលាស់ចម្រើនឡើងផង ដើម្បីប្រយោជន៍និងសេចក្តីសុខថ្កុំថ្កើង ជាតម្រាប់ដល់យុវជនជាន់ក្រោយផង តួយ៉ាងដូចជាការចំណាយទ្រព្យសម្បត្តិទំនុកបម្រុង ក្នុងព្រះពុទ្ធសាសនាកសាងសេនាសនៈលើកថ្នល់ សង់ស្ពាន ជីកអណ្តូងទឹក ស្រះទឹក សង់សាលាបម្រុងការសិក្សា ឬ សាលាដំណាក់ទុកសម្រាប់សាធារណៈមិនបានចំពោះបដិគ្គាហក ។

៣- **ចាគៈ** ការលះឲ្យវត្ថុដ៏ច្រើនក្រៃលែង ឬ ខ្ពង់ខ្ពស់លើសវិស័យរបស់មនុស្សសាមញ្ញ ក្នុងលោកគួរឲ្យស្ញើច ដែលរាប់ថាជាការបរិច្ចាគយ៉ាងខ្ពង់ខ្ពស់បំផុតកម្រអ្នកផងយកតម្រាប់តាមបាន តួយ៉ាងដូច មហាបរិច្ចាគ[២] ទាំង ៥ របស់ព្រះពោធិសត្វ ។

៤- **ចាគៈ** ការលះកាត់អាល័យក្នុងជីវិត និង សេចក្តីសុខក្នុងទ្រព្យសម្បត្តិរបស់ខ្លួនម្នាក់ឯង ដើម្បីស្វែងរកឧបាយជួយជ្រោមជ្រែងប្រជាជនក្នុងលោក ឬ លះបង់ទ្រព្យសម្បត្តិ ដើម្បីរោយរាយ ចែកចាយឲ្យទៅជាប្រយោជន៍ ផ្តល់សេចក្តីសុខ សេចក្តីចម្រើន រុងរឿង ដល់មហាជនទុកជាកេរ្តិ៍ដំណែលតទៅ ។ ពាក្យថា **ទាន** និង **ចាគៈ** មានសេចក្តីផ្សេងគ្នាដូចពណ៌នានេះឯង ។

---

២ មហាបរិច្ចាគទាំង ៥ មានៈ ១.លះទ្រព្យ ២.លះបុត្រ ៣. ភរិយា ៤. អវយវៈ ៥. និងជីវិត

*៥.សំណួរ៖ ទាន និង ចាគៈ ទាំងពីរនេះ ណាមួយមានកម្លាំងជាង ? ណាមួយជាហេតុ និង ណាមួយជាផល ?*

ចម្លើយ៖ **ចាគៈ** មានកម្លាំង មានអានុភាពខ្ពង់ខ្ពស់ ផ្សាយរស្មីរុងរឿងលេចទូលាយសេចក្តីល្អជាង **ទាន** ។ មួយទៀត **ទាន** និង **ចាគៈ** នេះបើពោលតាមលក្ខណៈរួបរួមក៏គឺការឲ្យ ការបែងចែករំលែក ទ្រព្យសម្បត្តិ ចំពោះសត្វបុគ្គលដទៃប៉ុណ្ណោះឯង តែបើពោលតាម ហេតុផលវិញ **ទាន** ជាឈ្មោះបរិក្ខារវត្ថុដែលត្រូវឲ្យ, **ចាគៈ** ជាឈ្មោះចេតនា ដែលជាតួចេតសិកសម្រាប់លះ, **ទាន** ចាត់ជាផល, **ចាគៈ** ចាត់ជាហេតុ អាស្រ័យគ្នាដូចដួងព្រះអាទិត្យ និងពន្លឺរស្មីនៃព្រះអាទិត្យ ។ មួយវិញទៀត **ទាន** ដូចជាផ្លែផ្កាដែលលេចចេញចាកដើម ឬ ទង, **ចាគៈ** ដូចជាដើម ឬ ទងនៃរុក្ខជាតិ និងវល្លិជាតិ ជាបច្ច័យឲ្យកើតផ្លែផ្កា ឬថា **ចាគៈ** ទុកដូចជាដើមពូជមុនដំបូង, **ទាន** ទុកដូចជាផ្លែផ្កា ដែលកើតអំពីពូជខាងដើម ដូច្នេះវិញក៏បាន ។

*សម្គាល់:* ទាន និងចាគៈ មានសេចក្តីផ្សេងគ្នាខ្លះ ត្រូវគ្នាខ្លះ ។ ដែលថាផ្សេងគ្នានោះ ផ្សេងត្រង់ **ចាគៈ** ចែកជា ពីរ យ៉ាងគឺៈ

- *អាមិសចាគៈ ការលះបង់អាមិស* (របស់ជាគ្រឿងទាក់ចិត្ត)
- *កិលេសចាគៈ ការលះបង់កិលេស* (សេចក្តីសៅហ្មងចិត្ត)

ដែលថាត្រូវគ្នានោះ គឺអាមិសចាត់ចូលក្នុងទានដូចគ្នា ទានក៏គង់ឲ្យអាមិស, ចាគលះបង់អាមិស ទានក៏គង់មាន ចាគចេតនា នៅខាងក្នុងនោះដែរ បានទៅជាទានកើត ឯទាននេះប្រកបដោយបដិគ្គាហកអ្នកទទួលទៀត ចំណែក ចាគៈ បើគ្មានអ្នកទទួលទេ ក៏គង់តែគេធ្វើវាឲ្យកើតឡើងបាន ដូចយ៉ាងកិលេសចាគៈ ការលះកិលេសជាដើម ពុំមានអ្នកណាគេទទួលទេ ។

*៦.សំណួរ៖ ការឲ្យទាន មានកម្រៃនាំឲ្យសម្រេចប្រយោជន៍ ដូចម្តេចខ្លះ ?*

ចម្លើយ៖ មានកម្រៃនាំឲ្យសម្រេចប្រយោជន៍គឺសេចក្តីល្អ សេចក្តីសុខ និង សេចក្តីចម្រើន ទាំងក្នុងបច្ចុប្បន្ន និង ក្នុងបរលោក ដល់បុគ្គលអ្នកធ្វើនោះជាច្រើនប្រការ ។

*៧.សំណួរ៖ ទាន មានច្រើនជាអនេក មិនអាចនឹងពណ៌នាឲ្យសព្វគ្រប់បាន តែបើកំណត់ឈ្មោះទាន តាមប្រភេទដែលផ្សេងគ្នា ដោយចេតនា និង ទេយ្យវត្ថុ មាន ប៉ុន្មានយ៉ាង ?*

ចម្លើយ៖ មាន ៣ យ៉ាងគឺៈ

១-**ចាគចេតនា ទានំ** ចេតនាដែលលះទេយ្យវត្ថុដល់បុគ្គលដទៃ ឈ្មោះថា **ទាន** ។

២-**វិរតិ ទានំ** ចេតនាដែលវៀរចាកអំពើអាក្រក់ មានវៀរចាកបាណាតិបាត ជាដើម ហៅថា **ទាន** ។

៣-**ទេយ្យធម្មោ ទានំ** ទេយ្យធម៌ គឺវត្ថុដែលគេត្រូវលះ ឲ្យដល់បុគ្គលដទៃ ឈ្មោះថា **ទាន** ។

*៨.សំណួរ៖ មាតិកាដែលរាប់ឈ្មោះទានទាំង ៣ យ៉ាងមកនេះ គ្រាន់តែប្រែតាមរូបព្យញ្ជនៈខ្លីៗ ស្តាប់សេចក្តីមិនទាន់បាន តើមានសេចក្តីផ្សេងគ្នា ឬ ជាប់ទាក់ទងគ្នាយ៉ាងណា ? ចូរអធិប្បាយ !*

ចម្លើយ៖ ផ្សេងគ្នាខ្លះ ជាប់ទាក់ទងគ្នាខ្លះ បណ្តាទានទាំង ៣ យ៉ាងនេះ លើក **វិរតិទាន** ចេញមិនអធិប្បាយក្នុងទីនេះទេ ព្រោះបានដល់ការកាន់សីល ៥ ឯណោះដោយឡែក, ឯ **ចាគចេតនាទាន** និង **ទេយ្យធម្មទាន** ទាំង ២ នេះពិតជាមានឈ្មោះផ្សេងគ្នាតាមប្រភេទមែន ប៉ុន្តែជាធម្មជាតិដាច់ឃ្លាតចេញពីគ្នាមិនបាន ទាំងមិនអាចនឹងញុំាងកុសលឲ្យសម្រេចបាន ដោយ

ទៀកពីគ្នាឡើយ ព្រោះថា បុគ្គលមានតែចេតនាបម្រុងលះឲ្យ តែគ្មានទេយ្យវត្ថុនឹងឲ្យ ក៏ធ្វើទានមិនកើត ឬ មានទេយ្យវត្ថុល្មមនឹងលះឲ្យដែរ តែគ្មានចេតនាសម្រាប់លះឲ្យ ក៏ធ្វើឲ្យកើតជាទានមិនបាន លុះតែមានចេតនា និងទេយ្យវត្ថុព្រមគ្នាទាំងពីរទើបបុគ្គលធ្វើឲ្យសម្រេចកើតទៅជាទានបាន ។

*៩.សំណួរ៖ ទាន បើចែកតាមគោលដើម មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?*

ចម្លើយ៖ មាន ពីរ យ៉ាងគឺ **អាមិសទាន ១** និង **ធម្មទាន ១** ។

*១០.សំណួរ៖ ទានទាំងពីរយ៉ាងនេះ លើកធម្មទានទុកសិន សូមសួរចំពោះតែអាមិសទាន បានដល់លះវត្ថុ អ្វីខ្លះ ?*

ចម្លើយ៖បានដល់ការលះឲ្យទេយ្យវត្ថុគឺ**បច្ច័យ៤**យ៉ាងនិង**ទានវត្ថុ១០**យ៉ាង។

*១១.សំណួរ៖ ពាក្យថា **បច្ច័យ** ប្រែ ដូចម្តេច ? បានសេចក្តី យ៉ាងណា ?*

ចម្លើយ៖ **បច្ច័យ** ប្រែថា វត្ថុជាគ្រឿងអាស្រ័យ ប្រព្រឹត្តទៅរបស់សត្វ បានសេចក្តីថា គ្រឿងដែលសត្វត្រូវអាស្រ័យបរិភោគប្រើប្រាស់ហើយប្រព្រឹត្តទៅបាន ឬ ថាសត្វទាំងឡាយក្នុងលោក សុទ្ធតែត្រូវពឹងពាក់អាស្រ័យនូវបច្ច័យបើយ៉ាងហោចទៅត្រឹមតែបច្ច័យណាមួយ ទើបអាចញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបាន បើមិនបានអាស្រ័យសោះទេ ក៏នឹងមិនអាចញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅបានឡើយ ព្រោះហេតុនោះ ទើបមានឈ្មោះថា **បច្ច័យ** ។

## ពាក្យថា បច្ច័យ នោះមាន ៤ យ៉ាងគឺ:

១-**ចីវរ** គឺសំពត់សម្រាប់ស្លៀកដណ្តប់របស់បព្វជិត មានស្បង់ ចីពរ សង្ឃាដី ជាដើម ហៅថា **ចីវរប្បច្ច័យ** ។

២-**បិណ្ឌបាត** គឺអាហារសម្រាប់បរិភោគ (ឆាន់) របស់បព្វជិត មានខាទនីយៈ និង ភោជនីយាហារ ជាដើម ដែលគួរទទួលទុកឆាន់បានតាំងពីវេលាអរុណរះ ទៅដល់ថ្ងៃត្រង់ ហៅថា **បិណ្ឌបាតប្បច្ច័យ** ។

៣-**សេនាសនៈ** គឺវត្ថុជាទីដេក និង វត្ថុជាទីអង្គុយរបស់បព្វជិតមាន កុដិ សាលា គ្រែ និង តាំង ជាដើម ហៅថា **សេនាសនប្បច្ច័យ** ។

៤-**គិលានភេសជ្ជៈ** គឺថ្នាំសម្រាប់ព្យាបាល កែបំបាត់ជំងឺផ្សេង ៗ របស់បព្វជិតមានទឹកបាន ៨ យ៉ាង (អដ្ឋបាន) ថ្នាំត្រាំដោយទឹកមូត្រ និងថ្នាំពេទ្យសម័យទំនើប ឬ ថ្នាំឱសថបុរាណជាដើម ដែលគួរទទួលទុកឆាន់បានតាមកំណត់កាល ហៅថា **គិលានភេសជ្ជប្បច្ច័យ** ។

***១២.សំណួរៈ ទានវត្ថុ ប្រែដូចម្ដេច ? មាន ១០ យ៉ាងនោះ គឺអ្វីខ្លះ ?***

ចម្លើយ៖ **ទានវត្ថុ** ប្រែថា វត្ថុសម្រាប់ឲ្យ ឬ របស់ដែលគេគប្បីឲ្យ មាន១០គឺៈ

១-**អន្នំ** បាយ សំដៅយកគ្រឿងបរិភោគបាន គឺ បង្អែម និងចំអាប ទាំងអស់បានដល់បាយ នំ ចំណី ត្រីសាច់ គ្រប់ប្រភេទដែលអាចហូបបាន។

២-**បានំ** ទឹក សំដៅយកទឹក (អដ្ឋបាន) ទាំង ៨ យ៉ាងគឺៈ

- ទឹកដែលគេធ្វើដោយផ្លែស្វាយ
- ទឹកដែលគេធ្វើដោយផ្លែព្រីង
- ទឹកដែលគេធ្វើដោយចេកមានគ្រាប់
- ទឹកដែលគេធ្វើដោយចេកគ្មានគ្រាប់
- ទឹកដែលគេធ្វើដោយផ្លែស្រគំ
- ទឹកដែលគេធ្វើដោយផ្លែច័ន្ទ
- ទឹកដែលគេធ្វើដោយមើមនៃផលជាតិ មានព្រលឹតក្រហមជាដើម
- និង ទឹកដែលគេធ្វើដោយផ្លែម៉ាក់ប្រាង ។

៣-**វត្ថំ** សំពត់ សំដៅយកសំពត់សម្រាប់ស្លៀក និង សំពត់សម្រាប់ដណ្ដប់ មាន ខោ អាវ ភួយ កន្សែង ជាដើម ។

៤-**យានំ** យានជំនិះ សំដៅយកវត្ថុដែលជាគ្រឿងញ៉ាំងដំណើរឲ្យសម្រេច មានរថយន្ត ឡាន ម៉ូតូ ស៊ីក្លូ កង់ និង ស្បែកជើង ជាដើម ។

៥-**មាលា** ផ្កាកម្រង សំដៅយកផ្កាឈើទាំងអស់ ដែលគ្រាន់តែផ្សេងគ្នាដោយពណ៌ និង ក្លិន បានដល់ផ្កាម្លិះរួត ម្លិះលា ក្ដាំងងា នួនស្រីជាដើម ។

៦-**គន្ធំ** គ្រឿងក្រអូប សំដៅយកគន្ធជាតិទាំងអស់ និង គ្រឿងឧបករណ៍បានដល់គ្រឿងក្រអូប ដែលគេកិនហើយក្ដី មិនទាន់បានកិនក្ដី ។

៧-**វិលេបនំ** គ្រឿងលាប សំដៅយកវត្ថុ ធ្វើឲ្យស្បែកខាងក្រៅជាទីត្រេកអរ មានសាប៊ូ ដុំ សាប៊ូ ទឹក និង ឡេ លាបខ្លួន ជាដើម ។

៨-**សេយ្យំ** ទីដេក សំដៅយកវត្ថុជាទីដេក ទីអង្គុយបាន មាន គ្រែតាំង កន្ទេល ខ្នល់ខ្នើយ ពូក ព្រំ ចៀមធំ ជាដើម ។

៩-**អាវសថំ** ទីលំនៅ សំដៅយកផ្ទះស្បូវ ផ្ទះក្បឿង ផ្ទះថ្ម តូបសាលាដំណាក់ សាលាបុណ្យ ជាទីសំណាក់អាស្រ័យ សម្រាប់បន្ទោបង់នូវសេចក្ដីអន្តរាយ សេចក្ដីលំបាក មានខ្យល់ និង កំដៅថ្ងៃ ជាដើម ។

១០-**បទីបេយ្យំ** គ្រឿងប្រទីប សំដៅយកវត្ថុសម្រាប់ ទំនុកបម្រុងដល់ប្រទីបមាន ប្រេងប្រឆេះ ម៉ាស៊ីនភ្លើង អំពូលភ្លើង ទៀន ចង្កៀង និងប្រទីបផ្កាលា ជាដើម សម្រាប់អុជ ឬ ដុតបំភ្លឺ ។

ទានវត្ថុ ទាំង ១០ នេះ គឺសម្រាប់លះឲ្យដល់ជនទូទៅ ទាំងអស់ឥតរើសមុខ, ដោយហោចទៅសូម្បីតែសត្វតិរច្ឆាន (ព្រោះជាទានខាងព្រះសូត្រ) ។

***១៣.សំណួរ៖ ទឹកអដ្ឋបាន ដែលគេធ្វើដោយផ្លែឈើមានតែ ៨ យ៉ាង ឬ មានផ្សេងពីនេះទៀត ដែរ ឬទេ ? បើមាន តើមាន អ្វីខ្លះ ?***

ចម្លើយ៖ មានផ្សេងពីផ្លែឈើ និង ផលជាតិខាងលើ ៨ ទៀតគឺៈ

- ទឹកដែលគេធ្វើ ដោយផ្លែសង្ស៉ា

- ទឹកដែលគេធ្វើ ដោយផ្លែពុទ្រាតូច
- ទឹកដែលគេធ្វើ ដោយផ្លែពុទ្រាធំ
- ទឹកដែលគេធ្វើ ដោយទឹកដោះរាវ ឬ ទឹកដោះថ្លា
- ទឹកដែលគេធ្វើ ដោយប្រេងមានប្រេងល្ង ជាដើម
- ទឹកដែលគេធ្វើ ដោយទឹកដោះស្រស់
- ទឹកដែលគេធ្វើ ដោយបបរ
- ទឹកដែលគេធ្វើ ដោយរសរុក្ខជាតិផ្សេងៗមានស្លឹក និង ផ្កាជាដើម ។

*១៤.សំណួរ៖ ទឹកអដ្ឋបាននោះ តើគេធ្វើបានគ្រប់ផ្លែឈើ និង វត្ថុឯទៀតទាំងអស់ ឬ ? មានពុទ្ធប្បញ្ញត្តិ វៀរវត្ថុណាខ្លះ ? ចូររៀបរាប់ចំនួន និង ឈ្មោះ..!*

ចម្លើយ៖ មិនមែនចេះតែធ្វើបានគ្រប់ផ្លែឈើ និង វត្ថុឯទៀតទាំងអស់ទេ មានពុទ្ធប្បញ្ញត្តិឲ្យវៀរមហាផល (ផ្លែឈើធំ) ៩ យ៉ាងចេញគឺៈ

១.ផ្លែត្នោត ២.ផ្លែដូង ៣.ផ្លែខ្នុរ ៤.ផ្លែខ្នុរសម្ល
៥.ផ្លែឃ្លោក ៦.ផ្លែល្ពៅ ៧.ផ្លែត្រសក់ ៨.ផ្លែឪឡឹក ៩.ផ្លែត្រឡាច

*និង ត្រូវវៀរនូវ ធញ្ញជាតិ (ជាតិនៃស្រូវ) ៧ យ៉ាងចេញទៀតគឺៈ*

១.ស្រូវសាលី ២.ស្រូវដំណើប ៣.ស្រូវខ្សាយ ៤.ស្រងែ
៥.ថ្កៅ ៦.ពោត-ស្គួយ ឬ កន្ទុយដំរី ៧.និង គែលលក ។

ផ្លែឈើក្រៅពីមហាផល ៩ យ៉ាង និង ធញ្ញជាតិ ៧ យ៉ាងនេះចេញ មានពុទ្ធានុញ្ញាតឲ្យធ្វើបានទាំងអស់ ។

*១៥.សំណួរ៖ ទឹកបាន ជាភេសជ្ជៈសម្រាប់ភិក្ខុមានជំងឺ បណ្តាកាលិក ទាំង៤ ទឹកបាន ចាត់ចូលក្នុងកាលិកណា ? ភិក្ខុឆាន់បានក្នុងកាលណា ? ទទួលទុកបាន ប៉ុន្មានថ្ងៃ ? បើទុកឲ្យហួសកំណត់ហើយ យកមកឆាន់ ត្រូវអាបត្តិ អ្វី ?*

ចម្លើយៈ ចាត់ចូលក្នុងយាមកាលិក[៣], ភិក្ខុឆាន់ក្នុងកាលបាន,ទទួលទុកបានត្រឹម ១ យប់ ១ ថ្ងៃយ៉ាងយូរ,បើទុកឲ្យកន្លងហួសពីកំណត់នោះទៅហើយយកមកឆាន់នឹងត្រូវ **អាបត្តិទុក្កដ** (អំពើអាក្រក់,បាប) ។

***១៦.សំណួរៈ អាមិសទាន ព្រះសម្មាសម្ពុទ្ធជាធម្មស្សាមី (ជាម្ចាស់នៃធម៌) ទ្រង់ត្រាស់សម្ដែងញែកឈ្មោះតាមលក្ខណៈ ឬ កិច្ចដែលធ្វើនោះមាន ប៉ុន្មានប្រការ ? មានអ្វីខ្លះ ?***

ចម្លើយៈ មានច្រើនប្រការណាស់គឺៈ បាដិបុគ្គលិកទាន សង្ឃគតទាន សប្បុរិសទាន អសម្មតទាន កាលទាន និង កឋិនទាន..ជាដើម ។

***១៧.សំណួរៈ ទានដែលឲ្យចំពោះបុគ្គលណាមួយៗ តាមសេចក្ដីស្រលាញ់ ឬសេចក្ដីពេញចិត្តគឺឲ្យដោយតាំងចិត្តថា លោកនេះជាគ្រូអាចារ្យ,នេះជាញាតិជាមិត្តសំឡាញ់, នេះជាកូនជាក្មួយជាចៅ, អង្គនេះជាចៅអធិការ ជាគ្រូសូត្រជាដើម ហៅថាទានអ្វី ? មានប៉ុន្មានយ៉ាង ?***

ចម្លើយៈ លោកហៅថា បាដិបុគ្គលិកទាន មាន ១៤ យ៉ាងគឺៈ

១-បុគ្គលឲ្យទានដល់ព្រះតថាគត ជាព្រះអរហន្តសម្មាសម្ពុទ្ធ

២-បុគ្គលឲ្យទានដល់ព្រះបច្ចេកពុទ្ធ

៣-បុគ្គលឲ្យទានដល់ព្រះអរហន្តជាសាវ័ករបស់ព្រះតថាគត

៤-បុគ្គលឲ្យទានដល់បុគ្គលដែលប្រតិបត្តិដើម្បីឲ្យបានលុះនូវអរហត្តផល

៥-បុគ្គលឲ្យទានដល់អានាគាមិបុគ្គល

---

៣ **យាវកាលិក, យាមកាលិក, សត្តាហកាលិក, យាវជីវិក** ទាំង ៤ នេះហៅថា **កាលិក** គឺរបស់ដែលកើតឡើងតាមកាល,វត្ថុដែលប្រើប្រាស់បានតាមកាលវេលា។

៦-បុគ្គលឲ្យទាន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឲ្យបានលុះនូវអនាគាមិផល

៧-បុគ្គលឲ្យទាន ដល់សកទាគាមិបុគ្គល

៨-បុគ្គលឲ្យទាន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឲ្យបានលុះនូវសកទាគាមិផល

៩-បុគ្គលឲ្យទាន ដល់សោតាបន្នបុគ្គល

១០-បុគ្គលឲ្យទាន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឲ្យបានលុះនូវសោតាបត្តិផល

១១-បុគ្គលឲ្យទាន ដល់បុគ្គលខាងក្រៅព្រះពុទ្ធសាសនា តែមានសេចក្ដីនឿយណាយក្នុងកាមទាំងឡាយ

១២-បុគ្គលឲ្យទាន ដល់បុគ្គលជាបុថុជ្ជនមានសីលបរិសុទ្ធ

១៣-បុគ្គលឲ្យទាន ដល់បុគ្គលជាបុថុជ្ជន ទ្រុស្តសីល

១៤-បុគ្គលឲ្យទាន ដល់សត្វតិរច្ឆាន ។

*១៨.សំណួរ៖ ឲ្យទានចំពោះរូបបដិគ្គាហក មួយៗ តាំងពីព្រះពុទ្ធជាម្ចាស់ចុះមកដល់សត្វតិរច្ឆានជាទីបំផុត ហៅថា បាដិបុគ្គលិកទាន បាដិបុគ្គលិកទាននេះមានអានិសង្សស្មើៗ គ្នា ឬ តិចច្រើនជាងគ្នាយ៉ាងណាខ្លះ ? ចូរពន្យល់*

ចម្លើយ៖ មានអានិសង្សមិនស្មើគ្នាទេ គឺមានចំនួនតិចច្រើនជាងគ្នាតាមគុណធម៌របស់បដិគ្គាហកនោះៗ ដូច្នេះគឺៈ

- ឲ្យទានដល់សត្វតិរច្ឆានបានអានិសង្ស[៤]មួយរយអត្តភាពឬ១០០ជាតិ
- ឲ្យទានដល់បុគ្គលបុថុជ្ជនទ្រុស្តសីល បានអានិសង្សមួយពាន់អត្តភាព

---

៤ អាយុ,ពណ៌សម្បុរកាយ,សេចក្ដីសុខ,កម្លាំង,ប្រាជ្ញា ទាំង ៥ នេះហៅថា អានិសង្ស ។

- ឲ្យទានដល់បុគ្គលបុថុជ្ជនមានសីលបរិសុទ្ធ បានអានិសង្សមួយសែនអត្តភាព ឬ ១០០.០០០ ជាតិ ។

- ឲ្យទានដល់បុគ្គល ខាងក្រៅព្រះពុទ្ធសាសនា ដែលមានសេចក្តីនឿយណាយក្នុងកាម បានអានិសង្ស មួយសែនកោដិអត្តភាព ឬ ជាតិ ។

- ឲ្យទានដល់បុគ្គលដែលប្រតិបត្តិ ដើម្បីឲ្យបានលុះនូវសោតាបត្តិផល បានអានិសង្សរាប់ពុំបានប្រមាណពុំអស់ឡើយ ។

- ចំណែកខាងអានិសង្សនៃទាន ដែលបុគ្គលបានឲ្យដល់សោតាបន្នបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីឲ្យបានលុះនូវសកទាគាមិផលក្តី ព្រះសកទាគាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីឲ្យបានលុះនូវអនាគាមិផលក្តី ព្រះអនាគាមិបុគ្គលក្តី បុគ្គលដែលបានប្រតិបត្តិដើម្បី ឲ្យបានលុះនូវអរហត្តផលក្តី ព្រះអរហន្តជាសាវ័ករបស់ព្រះតថាគតក្តី ព្រះបច្ចេកពុទ្ធក្តី ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធក្តី មិនបាច់និយាយឡើយគឺបានអានិសង្សច្រើនមិនអាចត្រាគណនាបាន ថាប៉ុណ្ណេះ ឬ ប៉ុណ្ណោះឡើយ ។

***១៩.សំណួរ៖ ទានដែលទាយកឲ្យចំពោះសង្ឃ មិនបានចំពោះរូបបុគ្គលណាមួយ ហៅថាទានអ្វី ? មានប៉ុន្មានយ៉ាង ?***

ចម្លើយ៖ ហៅថាសង្ឃទាន ឬ សង្ឃតាទក្ខិណាទាន មាន ៧ យ៉ាងគឺៈ

១-បុគ្គលឲ្យទានចំពោះឧភតោសង្ឃ[៩] គឺទាំងភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ហើយមានព្រះពុទ្ធជាប្រធាន

---

៩ **ភតោសង្ឃ** ប្រែថាសង្ឃទាំងពីរចំណែក គឺពួកភិក្ខុសង្ឃអង្គុយម្ខាង ពួកភិក្ខុនីសង្ឃអង្គុយម្ខាង ព្រះសាស្តាជាម្ចាស់គង់ត្រង់កណ្តាល ដូច្នេះឈ្មោះថា "**សង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន**" ។ សង្ឃគតាទក្ខិណាទានទី ១ នេះ គ្មានទក្ខិណាទានឯណាវិសេសស្មើឡើយ ប៉ុន្តែកាលដែលព្រះសាស្តាបរិនិព្វានទៅហើយនោះ គេតម្កល់ព្រះពុទ្ធបដិមា ឬ ព្រះសារីរិកធាតុលើអាសនៈក្នុងទីចំពោះមុខសង្ឃ

២-បុគ្គលឲ្យទាន ចំពោះឧភតោសង្ឃ ក្នុងកាលដែលព្រះតថាគតបរិនិព្វាន កន្លងទៅហើយ

៣-បុគ្គលឲ្យទាន ចំពោះតែភិក្ខុសង្ឃ

៤-បុគ្គលឲ្យទាន ចំពោះតែភិក្ខុនីសង្ឃ

៥-បុគ្គលឲ្យទាន ចំពោះសង្ឃដែលគេនិមន្តមកពីសំណាក់ ឧភតោសង្ឃ

៦-បុគ្គលឲ្យទានចំពោះភិក្ខុនីសង្ឃដែលគេនិមន្តពីសំណាក់ភិក្ខុនីសង្ឃ ។

***២០.សំណួរ៖ ទានទាំងពីរគឺ បាដិបុគ្គលិកទាន [៦] និងសង្ឃគតទាន [៧] មួយណា មានផលានិសង្សច្រើនជាងណា ? ព្រោះហេតុអ្វី ?***

ចម្លើយ៖ សង្ឃគតទាន មានផលានិសង្សច្រើនជាងបាដិបុគ្គលិកទាន ព្រោះឲ្យជាសាធារណៈមិនចំពោះរូបបដិគ្គាហកម្នាក់ៗ ។ សមដូចព្រះពុទ្ធដីកាព្រះអង្គត្រាស់នឹងព្រះអានន្ទ ថា « ម្នាលអានន្ទ លុះកាលជាអនាគតអង្វែងយូរទៅ មានតែគោត្រភូបុគ្គល (គោត្រភូសង្ឃ) ជាអ្នកទ្រុសសីល មានធម៌លាមក មានតែសំពត់កាសាវពស្ត្រព័ន្ធព័ទ្ធ បើមានគេឲ្យទានឧទ្ទិសចំពោះសង្ឃ ក្នុងពួកបុគ្គលទ្រុស្តសីលទាំងនោះ គង់នៅមានផលច្រើន ម្នាលអានន្ទ

---

(ត)ទាំងពីរចំណែក តម្កល់ម្ហូបចំណីលើតុ ឬ ជើងស្រាប ហើយធ្វើកិច្ចទក្ខិណោទក ជាដើមថ្វាយវត្ថុទាំងពួងដល់ព្រះពុទ្ធបដិមា ជាមុនទើបថ្វាយដល់សង្ឃទាំងពីរចំណែកជាខាងក្រោយ យ៉ាងនេះក៏ឈ្មោះថាថ្វាយទានដល់សង្ឃទាំងពីរចំណែកមានព្រះពុទ្ធជាប្រធានដែរ (ប៉ុន្តែ សម័យឥឡូវនេះគ្មានភិក្ខុនី មានតែភិក្ខុដូច្នេះឈ្មោះថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន) ។ ភោជនដែលថ្វាយដល់ព្រះពុទ្ធបដិមាយ៉ាងនេះ ត្រូវប្រគេនដល់ភិក្ខុណាដែលប្រតិបត្តិព្រះពុទ្ធបដិមា ដែលបរិបូណ៌ដោយវត្តប្រតិបត្តិ ព្រោះជាវត្ថុរបស់ព្រះពុទ្ធជាបិតា ត្រូវបានដល់ភិក្ខុជាកូន ឬ និងប្រគេនដល់សង្ឃក៏គួរ ។ បើវត្ថុនោះជាប្រេង ឬ សាដក ត្រូវអុជប្រទីបចងជាទង់ ឬ ពិតានថ្វាយ ។ ( អដ្ឋកថាសុត្តន្តបិដក )

៦ ទានដែលគេឲ្យចំពោះរូបបុគ្គល ហៅថា បាដិបុគ្គលិកទាន (ឬ បុគ្គលិកទាន)

៧ ទានដែលទាយកប្រគេន ឬ បង្អោនទៅចំពោះសង្ឃ ហៅថា សង្ឃគតទាន(ឬ សង្ឃទាន)

តថាគតពោលថា សង្ឃគតទាននោះ មានផលច្រើនរាប់ពុំបាន ម្នាលអានន្ទ តថាគតមិនដែលពោលថា បាដិបុគ្គលិកទានមានផលច្រើនជាង សង្ឃទាន ដោយបរិយាយឯណាមួយឡើយ » (ទ្រង់សរសើរ **សង្ឃទាន** តែម្យ៉ាង) ។

*<u>កំណត់សម្គាល់:</u>* ***គោត្រភូសង្ឃ*** *សង្ឃតវង្សត្រកូល គឺ ពួកអ្នកបួសក្នុងព្រះពុទ្ធសាសនា ដែលប្រព្រឹត្តឃ្លៀងឃ្លាតចាកធម៌វិន័យស្ទើរតែនឹងទាំងអស់ គ្រាន់តែមានភេទជាអ្នកបួសដោយឥតមានក្លែងក្លាយ ឬ រង្កៀសសង្ស័យឡើយប៉ុណ្ណោះឯង, ដោយហោចទៅ សូម្បីនៅត្រឹមតែយកសំពត់ជ្រលក់ពណ៌អម្ចត់មកចងនឹងកខ្លះ សៀតនឹងត្រចៀកខ្លះ ប៉ុណ្ណោះ ដោយមានការប្តេជ្ញាសម្គាល់ខ្លួនថាជាអ្នកបួសដោយពិតឥតមានសង្ស័យ ព្រោះបានទទួលផ្នួសអំពីគ្រូអាចារ្យមក, យ៉ាងនេះហៅថា គោត្រភូសង្ឃ; លុះចំណេរកាលយូរអង្វែងឆ្ងាយៗទៅ ក្នុងអនាគតខាងមុខ សង្ឃពួកនេះនឹងកើតមានជាប្រាកដ ។ តែបើ មានគេឲ្យទាន ហើយឧទ្ទិសចំពោះសង្ឃ ក៏គង់តែនឹងមាន អានិសង្សច្រើន តាមបែបសង្ឃគតទាន ដូចគ្នាដែរ ។*

***២១.សំណួរៈ ទានបែបណាហៅថា សប្បុរិសទាន ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?***

ចម្លើយៈ ទានរបស់បុគ្គលជាសប្បុរសហៅថាសប្បុរិស[៨]ទានមាន ៥ យ៉ាងគឺៈ

១-*ឲ្យទាន ដោយសទ្ធា* គឺឲ្យដោយចិត្តជឿកម្ម និង ផលរបស់កម្មប្រាកដថា អំពើគឺការឲ្យទាននេះ ជាអំពើមិនសូន្យសោះអសារឥតការឡើយ ប្រាកដជានឹងត្រឡប់បានផល ជារង្វាន់មកវិញពុំខាន ។

២-*ឲ្យទាន ដោយសេចក្តីគោរព* គឺទេយ្យវត្ថុដែលត្រូវលះឲ្យ និង គោរព បដិគ្គាហក អ្នកទទួល គោរពទេយ្យវត្ថុនោះ ត្រូវសំអាតទេយ្យវត្ថុ

---

៨ សូមមើល សុត្តន្តបិដក លេខ ៤៥ ទំព័រ ៨៨ (បន្ថែម)

ដោយផ្ចិតផ្ចង់ មិនធ្វើខ្ជីខ្ជាតាមតែបាន, ឯការគោរពបដិគ្គាហកនោះ ត្រូវសម្តែងសេចក្តីរាប់រកបដិគ្គាហក ដោយសេចក្តីស្មោះស្មើ មិនសម្តែងអាការៈទ្រមឹងត្រមើយ គឺ ត្រូវនិមន្ត ឬ អញ្ជើញឡើងអាសនៈដ៏សមគួរ ជាដើម ។

៣-*ឲ្យទាន តាមការគួរ* គឺឲ្យតាមកាល តាមរដូវ ដែលគេត្រូវធ្វើត្រូវឲ្យ ដូចជារដូវចូលវស្សា និងចេញវស្សា រដូវរងាឲ្យគ្រឿងស្លៀកដណ្តប់ រដូវក្តៅឲ្យទឹក ឬ ក៏ពេលដែលមានវត្ថុថ្មីថ្មោងមានផ្លែឈើ ជាដើម (ផ្លែដំបូង) ។

៤-*ឲ្យទាន ដោយសេចក្តីអនុគ្រោះ* គឺឲ្យដោយចិត្តមេត្តា យ៉ាងទោរទន់ចំពោះសមណៈ ឬ អ្នកក្រីក្រលំបាក ដែលរងទុក្ខវេទនាដោយសេចក្តីស្រេកឃ្លានជាដើម ឲ្យបានសុខស្រួលផុតពីសេចក្តីទុក្ខព្រួយហើយឥតតាំងចិត្តថា នឹងទារយកគុណបំណាច់ពីអ្នកទទួលទាននោះវិញឡើយ ។

៥-*ឲ្យទាន ដោយមិនបានតាំងចិត្តបៀតបៀនខ្លួនឯង និង អ្នកដទៃ* គឺឲ្យដោយតាំងចិត្តថានឹងបំបាត់នូវសេចក្តីលោភ និងសេចក្តីកំណាញ់ ហើយនឹងធ្វើឲ្យអស់នូវអាសវក្កិលេស ដែលជាមេនាំឲ្យកើតសេចក្តីទុក្ខព្រួយ ក្នុងវដ្តសង្សារប៉ុណ្ណោះ មិនបានតាំងចិត្តឲ្យអ្នកផងស្ងើចសរសើរថាប្រសើរជាងអ្នកដទៃឡើយ, ដែលថាមិនបៀតបៀនខ្លួន គឺ មិនឲ្យអ្នកដទៃសរសើរខ្លួន, មិនបៀតបៀនអ្នកដៃ គឺបន្តុះបង្អាប់ទានរបស់គេជាដើម ។

***២២.សំណួរ៖ សប្បុរិសទាន មានត្រឹមតែ ៥ ប៉ុណ្ណោះទេ ឬ មានផ្សេងពីនេះទៀត ប៉ុន្មានយ៉ាង ? បើមានចូររាប់ និងអធិប្បាយមកផង !***

ចម្លើយ៖ សប្បុរិសទាន [៩] មានផ្សេងពីនេះ ៥ យ៉ាងទៀតគឺៈ

១-ឲ្យទាន ដោយសេចក្តីគោរពចំពោះវត្ថុដែលត្រូវឲ្យ

---

៩ អង្គុត្តរនិកាយ បញ្ចកនិបាត ៤៥/៨៧

២-ឲ្យទាន ដោយតាំងសេចក្ដីគោរពចំពោះវត្ថុ និង បដិគ្គាហក

៣-ឲ្យទាន ដោយដៃខ្លួនឯង

៤-ឲ្យទាន ដោយមិនបោះឲ្យ

៥-ឲ្យទាន ដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

- ទាយកកាលដែលធ្វើទាន បានតាំងចិត្តគោរពចំពោះតែវត្ថុប៉ុណ្ណោះ មិនធ្វើសេចក្ដីអើពើចំពោះបុគ្គលអ្នកទទួល ទោះអ្នកទទួលទាននោះ មានចរិយាដូចម្ដេចម្ដា ក៏ឥតរវល់ខំប្រឹងតែសម្រិតសម្រាំងទេយ្យវត្ថុដែលខ្លួនត្រូវលះបង់ឲ្យនោះ ឲ្យស្អាតតែម្យ៉ាងយ៉ាងនេះហៅថា ឲ្យទានដោយសេចក្ដីគោរពចំពោះវត្ថុ ។

- បុគ្គលកាលធ្វើទាន បានតាំងចិត្តគោរពចំពោះទេយ្យវត្ថុផង ចំពោះបុគ្គលអ្នកទទួលទានផងទាំងពីរយ៉ាងគឺខំប្រឹងរៀបចំចាត់ចែងទេយ្យវត្ថុនោះឲ្យទាល់តែបានប្រសើរថ្លៃថ្លាមានឱជារសឆ្ងាញ់ពិសាផង ទាំងពិនិត្យមើលបុគ្គលអ្នកទទួលទានឲ្យឃើញថា មានចរិយាសណ្ដាប់ធ្នាប់ជាដើម ក៏ល្មមជាទីជ្រះថ្លាគួរកក់ក្ដៅក្នុងចិត្តបានផង ហើយក៏ឲ្យដោយសេចក្ដីគោរពចំពោះបុគ្គលអ្នកទទួលមិនព្រមសុខចិត្តប្រថុយឲ្យទៅទាំងខ្ជីខ្ជាឡើយ យ៉ាងនេះហៅថា ឲ្យទានដោយតាំងសេចក្ដីគោរពចំពោះទាំងវត្ថុ និង បដិគ្គាហក ហើយទើបឲ្យ ។

- ទាយកកាលដែលធ្វើទាន បានលើកយកទេយ្យវត្ថុដោយដៃខ្លួនឯង មិនប្រើអ្នកដទៃ ឲ្យគេឲ្យទេយ្យវត្ថុរបស់ខ្លួននោះជំនួសខ្លួនឡើយដោយតាំងចិត្តថា កាលអាត្មាអញត្រាច់រង្គាត់គឺអន្ទោលកើតស្លាប់ក្នុងវដ្ដសង្សារមិនមានទីបំផុតដែលមិនមានដៃជើងនោះ នឹងប្រមាណមិនបានឡើយ បើដូច្នោះ

អាត្មាអញនឹងធ្វើឲ្យផុតចាកសង្សារវដ្ត នឹងជាគ្រឿងរលាស់ខ្លួនចេញចាកភព យ៉ាងនេះហៅថា ឲ្យទានដោយដៃខ្លួនឯង ។

- ទាយកកាលដែលធ្វើទាន មិនបានបោះឲ្យ ឬចោលឲ្យគឺលើកហុចឲ្យដោយសេចក្តីគួរសម សម្តែងអាការទន់ភ្លន់ ប្រកបដោយចិត្តមេត្តាយ៉ាងនេះហៅថា ឲ្យទានដោយមិនបានបោះឲ្យ ។

- ទាយកកាលដែលធ្វើទាន ដោយជឿថាបុគ្គលអ្នកឲ្យទានគង់នឹងបានផលជាអំណោយរបស់ទាននោះមកវិញជាពុំខានឡើយយ៉ាងនេះហៅថា ឲ្យទានដោយចិត្តជឿថានឹងបានទទួលផលដោយពិត ។

***កំណត់ចំណាំបន្ថែមៈ*** សប្បុរិសទាន ប្រែថា អំណោយរបស់ជនសប្បុរស ឬអំណោយរបស់ជនអ្នកមានចិត្តស្ងប់ចាកបាប ។ សប្បុរសធ្វើទាន លោកពុំបានរើសមនុស្សអ្នកទទួលទេ មនុស្សល្អក៏លោកជួយសង្គ្រោះ មនុស្សអាក្រក់ក៏លោកជួយសង្គ្រោះ។ ដែលលោកធ្វើយ៉ាងនេះមិនមែនមានន័យថាលោកជួយមនុស្សអាក្រក់ឲ្យរឹតតែមាន កម្លាំងប្រព្រឹត្តអាក្រក់ច្រើនទៅទៀតទេ គឺមានន័យថា លោកមានចិត្តអាណិត ព្រោះមនុស្សយើងកាលណាមានសេចក្តីទុក្ខ ឬមានគ្រោះថ្នាក់កើតឡើងរមែងបួងសួងសុំជំនួយអំពីអ្នកដទៃ។ ចរិយាល្អរបស់សប្បុរសក្នុងផ្នែកទាននេះ អាចធ្វើមនុស្សអាក្រក់ឲ្យប្រែចិត្តមកជាមនុស្សល្អវិញក៏មាន ។ សប្បុរសពួកមួយទៀតវេលាធ្វើទានលោកពុំបាននឹកនាដល់កិរិយាប្រព្រឹត្ត ជំនឿ ទិដ្ឋិ ជាតិសាសន៍ លទ្ធិ និងសាសនារបស់មនុស្សឡើយ ។ លោកធ្វើនេះហៅសៃនត្រូវ ព្រោះលោកមិនខ្វីរវល់ដល់មុខងាររបស់គេ លោកគិតតែអំពីមុខងាររបស់លោក។ សប្បុរសធ្វើទានលោកគោរពក្នុងទេយ្យវត្ថុផង គោរពក្នុងបដិគ្គាហកផង ។ ផ្ទុយទៅវិញអសប្បុរសធ្វើទានមិនមានសេចក្តីគោរពក្នុងទេយ្យវត្ថុផង មិនមានសេចក្តី

គោរពក្នុងបដិគ្គាហកផង ។ដូច្នេះអ្នកអានគប្បីតាំងចិត្តធ្វើទានប្រកបដោយសន្ដានចិត្តជាសប្បុរសចុះ ព្រោះមានតែសប្បុរសទេ ដែលអាចធ្វើឲ្យមនុស្សលោកមូលមិត្តគ្នា មានសេចក្ដីសុខសន្តិភាព ដែលជាសេចក្ដីប្រាថ្នារបស់យើងទាំងអស់គ្នាគ្រប់ជាតិសាសន៍ក្នុងលោកនេះ ចង់បានគ្រប់ៗ គ្នា ។

*២៣.សំណួរ៖ ទានដែលផ្ទុយគ្នានឹងសប្បុរិសទាន ហៅថាទានអ្វី ? ប្រែដូចម្ដេច ? មានប៉ុន្មានយ៉ាង ? ចូរអធិប្បាយមាតិកាខ្លះៗ មកមើល៍*

ចម្លើយ៖ ហៅថា **អសប្បុរិសទាន**[១០] ប្រែថា ទានរបស់បុគ្គលជាអសប្បុរស មាន ៥ យ៉ាងដែរគឺៈ

១-ឲ្យទាន ដោយសេចក្ដីមិនគោរពចំពោះវត្ថុ

២-ឲ្យទាន ដោយមិនតាំងសេចក្ដីគោរពចំពោះវត្ថុ និង បដិគ្គាហក

៣-ឲ្យទាន ដោយការមិនឲ្យដោយដៃខ្លួនឯង

៤-ឲ្យទាន ដោយបោះឲ្យ

៥-ឲ្យទាន ដោយមិនជឿថានឹងបាន ទទួលផលវិញ

- ត្រង់ចំណុចទី ៤-៥ ថាៈ បុគ្គលដែលធ្វើទានដោយបោះឲ្យ ឬ ចោលឲ្យនោះ គឺបុគ្គលអ្នកឲ្យមានចិត្តជឿថា ឲ្យទានបានបុណ្យដែរ ប៉ុន្តែក្នុងពេលដែលស្មូមមកដល់មិនមានចិត្តមេត្តានឹងចង់ឲ្យ ឬ ជ្រះថ្លានឹងឲ្យទានដល់ស្មូមនោះសោះដោយសារតែទាល់ហើយក៏បោះឲ្យទៅ ទោះឋិតនៅក្នុងទីជិតគ្នាល្មមនឹងហុចឲ្យដោយស្រួលបានក៏បែរជាបោះឲ្យវិញឥតតាំងចិត្តយកបុណ្យឡើយ ពុំនោះសោតដោយសារតែមានទ្រព្យច្រើនក៏ហុច ឬ បោះឲ្យ

---

១០ អង្គុត្តរនិកាយ បញ្ចកនិបាត ៤៥ /៨៧

ដើម្បីឲ្យអ្នកក្រីក្រប្រជែងគ្នា ដណ្ដើមរើសយក នឹងបានមើលហើយសើច លេងសប្បាយប៉ុណ្ណោះ ។

- បុគ្គលដែលធ្វើទាន ដោយមិនជឿថានឹងបានទទួលផលនោះ គឺ បុគ្គលមិនជឿថា មានបុណ្យ មានបាប មាននរក មានសួគ៌ជាដើម មនុស្សក្ដី សត្វក្ដី កើតឡើងល្អឯង អាក្រក់ឯង ឥតមានបុណ្យបាបអ្វីតាក់តែងឲ្យឡើយ ដែលឲ្យទាននេះដោយតាំងចិត្តថា ព្រោះតែស្គាល់គ្នាហើយឲ្យទៅ ឬ ក៏ ដោយសារមានមនុស្សមកសូមហើយឲ្យទៅប៉ុណ្ណោះឥតមានចិត្តកក់ក្ដៅ ឬ នឹកសង្ឃឹមថានឹងបានបុណ្យអំពីទាននេះឡើយ ។

- ត្រង់បទទី១-២-៣ នេះមិនបានអធិប្បាយទេ ព្រោះមានទំនងសេចក្ដីដូចគ្នា នឹងសប្បុរិសទានដែរ គ្រាន់តែផ្លាស់ពាក្យថា គោរព និង មិនគោរព ប៉ុណ្ណោះ ។

***២៤.សំណួរៈ ទានដែលលោកមិនសន្មត ឬ មិនរាប់ថាជាទាន ហៅថា ជា ទានអ្វី ? មាន ប៉ុន្មានយ៉ាង ? ព្រោះអ្វី ?***

ចម្លើយៈ លោកហៅថា **អសម្មតទាន** មាន ៥ យ៉ាងគឺៈ

១-ឲ្យស្ត្រីដល់បុរស ឬ ឲ្យបុរសដល់ស្ត្រី (ដឹកញី ប្រសុីឈ្មោល)

២-បើកលែងគោឧសភ គឺគោបា ឬ គោឈ្មោលដល់មេគោ ឬ ឲ្យមេ គោដល់គោឧសភ (គោឈ្មោល)

៣-ឲ្យទឹកស្រវឹង មានសុរា និង គ្រឿងញៀនជាដើម

៤-រាំនិងច្រៀងឲ្យជាទាន ឬ ឲ្យទានរបាំមានច្រៀងរាំត្លុកក្រមាច់ជាដើម

៥-ឲ្យទានរូបគំនូរស្ត្រី និង បុរសស្ត្រី ដែលជារូបនាំឲ្យកើតតម្រេក ត្រេកត្រអាលទៅរកកាម ។

ទានទាំង ៥ នេះមិនសន្មតថាជាទានឡើយ ព្រោះមិនចាត់ថាជាទាន បានបុណ្យទេ ជាទានឥតមានផលអ្វីជាទីពឹងពុំនាក់ ដល់ខ្លួនសោះឡើយ គួរ

ប្រឹងបំពេញទានឯទៀត មានសង្ឃគតទានជាដើមឲ្យបរិបូណ៌ចុះ ព្រោះជាទានមានផលជាកម្រៃជាទីពឹងដោយពិត ។

***២៥.សំណួរៈដូចម្តេចហៅថា កាលទាន ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?***

ចម្លើយៈទានដែលគេឲ្យតាមកាល តាមសម័យ ឬ គេឲ្យមួយដងមួយកាលដែលគួរឲ្យ ហៅថា **កាលទាន**[១១], មាន ៥ យ៉ាងគឺៈ

១-ឲ្យទាន ដល់អ្នកដែលទើបនឹងមកដល់ថ្មី

២-ឲ្យទាន ដល់អ្នកដែលរៀបដំណើរនឹងចេញទៅកាន់ទីឆ្ងាយ

៣-ឲ្យទាន ដល់អ្នកជំងឺ

៤-ឲ្យទាន ក្នុងវេលាដែលកំពុងស្រេកឃ្លាន (អត់ឃ្លាន)

៥-ឲ្យទាន ផ្លែឈើ ឬ វត្ថុអ្វីដែលទើបនឹងមានឡើងជាដំបូង ។

***២៦.សំណួរៈ ការឲ្យទាន និង ការរក្សាសីលទាំងពីរនេះ ណាក្រលំបាកជាងណា ?***

ចម្លើយៈ ការឲ្យទាន ជាកិច្ចដែលបុគ្គលនឹងធ្វើឲ្យបរិសុទ្ធគ្រប់គ្រាន់បានដោយកម្រជាងការកាន់សីល,ចំណែកសីលបើបុគ្គលត្រូវការរក្សា គ្រាន់តែរៀនឲ្យចេះដឹងកិច្ចដែលត្រូវតមត្រូវវៀរចាកប៉ុណ្ណោះជាដើមហើយសមាទានកាន់យកសីលនោះអំពីសំណាក់ភិក្ខុ ឬ សាមណេរ ជាដើម មកខំប្រព្រឹត្តសង្រួមឲ្យត្រឹមត្រូវតាមច្បាប់នោះប៉ុណ្ណោះ ក៏ញុាំងកុសលឲ្យសម្រេចបរិសុទ្ធបាន ឬ ថាសីលនេះ ជនទាំងអ្នកមាន ទាំងអ្នកក្រ អាចធ្វើបានដូចគ្នា ព្រោះជាកុសល ដែលបុគ្គលត្រូវរក្សា ចំពោះវិរតិចេតនា (ចេតនានៃការវៀរ ឬ ការលះបង់) ម្នាក់ៗបាន ដោយមិនចាំបាច់ចំណាយធនធាន ឬ អស់ទ្រព្យសម្បត្តិឡើយ ។

---

១១ សុត្តន្តបិដក អង្គុត្តរនិកាយ លេខ ៤៤ ទំព័រ ៨១

ចំណែកឯ ការធ្វើទាន លុះតែបុគ្គលមានទេយ្យវត្ថុ ល្មមលះធ្វើកើតទាំង បដិគ្គាហក អ្នកទទួលទានក៏មានផងទើបធ្វើបាន វេលាដែលធ្វើនោះទៀតមានកិច្ចត្រូវខ្វល់ខ្វាយក៏ច្រើន មិនតែប៉ុណ្ណោះឡើយ ទានក្នុងព្រះពុទ្ធសាសនានេះបុគ្គលត្រូវចាត់ចែងធ្វើឲ្យត្រឹមត្រូវទៅតាមពុទ្ធានុញ្ញាតផងទៀត ទើបនឹងបានផលានិសង្សច្រើនពេញលេញសមតាមបំណង បើនឹងចេះតែធ្វើបំពានទាំងខ្ចីខ្វាដោយការមិនចេះដឹងព្រោះអាងយសស័ក្តិ ឬ ទ្រព្យសម្បត្តិច្រើនធ្វើតាមទំនើងចិត្តចង់ ដោយញាណវិប្បយុត្ត[១២](ដែលប្រាសចាកសេចក្តីដឹង) មិនអាស្រ័យច្បាប់ព្រះពុទ្ធសាសនាដែលមានមក ក្នុងគម្ពីរដីកាជាគោលផងទេ ទាននេះមិនបានឈ្មោះថា ធ្វើដោយប្រពៃឡើយទាំងផលនៃទាននោះសោត ក៏ខ្សោយចុះមកជាលំដាប់ ដូច្នេះឃើញថា ការធ្វើទានពិបាកជាងការរក្សាសីលដូចបានពិពណ៌នាមកនេះឯង ។

***២៧.សំណួរៈ ទក្ខិណាវិសុទ្ធិ សេចក្តីបរិសុទ្ធ (និងសេចក្តីមិនបរិសុទ្ធ)នៃការឲ្យទាន មាន ប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូរពន្យល់ឲ្យបានក្បោះក្បាយមកមើល***

ចម្លើយៈទក្ខិណាវិសុទ្ធិ សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធនៃទានមាន៤យ៉ាងគឺៈ

១-ទានបរិសុទ្ធអំពីអ្នកឲ្យ មិនបរិសុទ្ធអំពីអ្នកទទួល

២-ទានបរិសុទ្ធអំពីអ្នកទទួល មិនបរិសុទ្ធអំពីអ្នកឲ្យ

---

១២ **ញាណវិប្បយុត្ត** ដែលប្រាសចាកសេចក្តីដឹង; ចិត្តដែលមានតែជំនឿឥតសេចក្តីដឹងការខុសឬ ត្រូវឡើយ : ធ្វើបុណ្យដោយញាណវិប្បយុត្ត គឺធ្វើបុណ្យកុសលណាមួយដោយជឿជាក់ថាបានបុណ្យ ប៉ុន្តែឥតមានសេចក្តីដឹងអ្វីប្លែកជាងជំនឿនោះឡើយ; កិច្ចការអ្វីៗដែលអ្នកធ្វើៗតាមតែបង្គាប់គេ ឥតមានយល់ជាក់ខ្លួនឯងសោះ ក៏ហៅថា ធ្វើដោយញាណវិប្បយុត្ត ដែរ។ ពាក្យផ្ទុយ : **ញាណសម្បយុត្ត** ។ ញាណសម្បយុត្ត ដែលប្រកបដោយសេចក្តីដឹង; ចិត្តដែលប្រកបដោយប្រាជ្ញា គឺចិត្តដែលមានជំនឿព្រមទាំងប្រាជ្ញាក៏មានផង : ធ្វើបុណ្យដោយញាណសម្បយុត្ត; គឺកិច្ចការអ្វីៗដែលគេធ្វើដោយការយល់ជាក់ខ្លួនឯង ក៏ហៅថា ធ្វើដោយ**ញាណសម្បយុត្ត** ដែរ ។

៣-ទានមិនបរិសុទ្ធអំពីអ្នកឲ្យផង អំពីអ្នកទទួលផង

៤-ទានបរិសុទ្ធអំពីអ្នកឲ្យផង អំពីអ្នកទទួលផង ។

- *ទានបរិសុទ្ធអំពីអ្នកឲ្យ មិនបរិសុទ្ធអំពីអ្នកទទួលនោះគឺ អ្នកឲ្យមានសីលបរិសុទ្ធ មានសីលធម៌ល្អ ឯអ្នកទទួលជាអ្នកទ្រុស្តសីលមានធម៌អាក្រក់*

- *ទានដែលបរិសុទ្ធអំពីអ្នកទទួល មិនបរិសុទ្ធអំពីអ្នកឲ្យនោះ គឺអ្នកឲ្យជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ ឯអ្នកទទួលមានសីលបរិសុទ្ធមានធម៌ល្អ*

- *ទានដែលមិនបរិសុទ្ធអំពីអ្នកឲ្យផង មិនបរិសុទ្ធអំពីអ្នកទទួលផងនោះគឺទាំងអ្នកឲ្យ ទាំងអ្នកទទួលជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ទាំងពីរ*

- *ទានដែលបរិសុទ្ធអំពីអ្នកឲ្យផង បរិសុទ្ធអំពីអ្នកទទួលផងនោះ គឺអ្នកឲ្យក៏ជាអ្នកមានសីលបរិសុទ្ធ មានធម៌ល្អ ឯអ្នកទទួលក៏ជាអ្នកមានសីលបរិសុទ្ធ មានធម៌ល្អដូចគ្នាទាំងពីរខាង ។*

ម្យ៉ាងវិញទៀតដែលថា,ទាយក (អ្នកឲ្យទាន) បរិសុទ្ធ គឺ ទាយក រកទ្រព្យបានដោយផ្លូវត្រឹមត្រូវ ចាត់ចែងទេយ្យទាន បានត្រឹមត្រូវតាមក្បួនបច្ចេកទេស ។ ដែលថាបដិគ្គាហក(អ្នកទទួល)មិនបរិសុទ្ធ គឺបដិគ្គាហកមិនមានសីលធម៌សម្រាប់ខ្លួន មិនមានសេចក្តីវៃឆ្លាត ក្នុងការប្រើវត្ថុដែលគេចាត់ចែងឡើងតាមក្បួន បច្ចេកទេស ។ ដែលថាបដិគ្គាហក បរិសុទ្ធ គឺបដិគ្គាហក មានសីលធម៌សម្រាប់ខ្លួន មានសេចក្តីវៃឆ្លាតចេះប្រើរបស់ដែលគេចាត់ចែងឡើងតាមក្បួន បច្ចេកទេស ។ ដែលថាទាយក មិនបរិសុទ្ធ គឺទាយករកទ្រព្យបានមកដោយផ្លូវខុស ចាត់ចែងទេយ្យទានមិនត្រឹមត្រូវតាមបច្ចេកទេស ។ ទាំង ៤ នេះមានតែទានទី ៤ ទេ ដែលជាទានល្អបំផុត ព្រោះទាំងសង្ខាង មាន សេចក្តីបរិសុទ្ធដូចគ្នា ។ បំណងពុទ្ធសាសនាចង់ឲ្យមនុស្សយើងរកសេចក្តីបរិសុទ្ធ រកសេចក្តីចេះដឹងទាំងអស់គ្នា ដើម្បីរស់នៅ

ក្នុងពិភពលោកដែលចេះតែរករឿងគ្នា មិនមានទីបំផុត ទើបលោកសរសើរទានទី ៤ ថាជាទានល្អជាងទី ១ ទី ២ និង ទី ៣ ។

បុគ្គលពួកខ្លះក្នុងលោកនេះ ចូលចិត្តធ្វើទាន តែមិនចូលចិត្តរកសេចក្តីបរិសុទ្ធខាងទ្រព្យសម្បត្តិ លួចប្លន់ស៊ីសំណូកបោកបន្លំអ្នកដទៃយកមកធ្វើទាន ។ ក្នុងពេលធ្វើទានម្តងៗមិនចូលចិត្តរកសេចក្តីចេះដឹងខាងផ្លូវបច្ចេកទេសដើម្បីចាត់ចែងទេយ្យទានរបស់ខ្លួនឲ្យបានត្រឹមត្រូវ ។ ចូលចិត្តអួតកេរ្តិ៍ឈ្មោះរបស់ខ្លួនដោយការធ្វើទាន ដោយមិនមាននឹកខ្មាសគេថា សេចក្តីសៅហ្មងនឹងសេចក្តីល្ងង់របស់ខ្លួន បើមិនមានអ្នកណាគេដឹងក៏គង់ខ្លួនឯងបានដឹងដែរ ។ បុគ្គលពួកខ្លះទៀត ក្នុងលោកនេះចូលចិត្តទទួលទានរបស់គេ តែមិនចូលចិត្តរកសេចក្តីបរិសុទ្ធសម្រាប់ខ្លួនខាងផ្លូវសីលធម៌ មិនចូលចិត្តរកសេចក្តីចេះដឹងសម្រាប់ខ្លួនខាងផ្លូវ "បច្ចេកទេស" ទាំងខាងវិន័យទាំងខាងសង្គមសាស្ត្រ ដើម្បីរស់នៅក្នុងលោកនេះដោយសេចក្តីថ្លៃថ្នូរ ។ ចូលចិត្តអួតកេរ៏ឈ្មោះរបស់ខ្លួន ដោយអំណាចទានអ្នកដទៃ មិនមាននឹកខ្មាសគេថា សេចក្តីសៅហ្មងនឹងសេចក្តីល្ងង់របស់ខ្លួន បើមិនមានអ្នកណាគេដឹងក៏គង់ខ្លួនឯងបានដឹងដែរ ។ ពុទ្ធសាសនា, បានឃើញអ្នកឲ្យកខ្វក់ នឹងអ្នកទទួលកខ្វក់នេះហើយ ទើបនិយាយពីទក្ខិណាវិសុទ្ធិ ដើម្បីឲ្យទាយក និងបដិគ្គាហក រៀបចំខ្លួនឲ្យបានបរិសុទ្ធ ឲ្យមានសេចក្តីចេះដឹងគ្រប់គ្នា ។

កាលណា យើងធ្វើសេចក្តីបរិសុទ្ធតាមបំណងពុទ្ធសាសនា សង្គមមនុស្សក្នុងពិភពលោកនេះ ក៏ប្រាកដជានឹងបានទទួលសេចក្តីចម្រើន ឋានសួគ៌ ក៏ប្រាកដជានឹងបើកទ្វារចាំទទួលមនុស្សបរិសុទ្ធជាពុំខានឡើយ ។

សូមបញ្ជាក់ម្តងទៀតថា ទក្ខិណាវិសុទ្ធិ សេចក្តីបរិសុទ្ធក្នុងការឲ្យទាននឹងការទទួលទាននោះមិនមែនសំដៅយកត្រឹមតែអាជីវកម្មបរិសុទ្ធ ឬ សីល

បរិសុទ្ធប៉ុណ្ណោះទេ គឺសំដៅយកសេចក្ដីបរិសុទ្ធខាងផ្លូវចេះដឹងស្គាល់របៀបបច្ចេកទេសទូទៅ ជាពិសេស ស្គាល់វិន័យបច្ចេកទេស ទាំងខាងអ្នកឲ្យទាំងខាងអ្នកទទួល ព្រោះអ្វី ? ព្រោះថាបើទាយក មិនស្គាល់បច្ចេកទេសទូទៅទានរបស់គេគ្រាន់តែមិនសូវល្អ តែបើមិនស្គាល់វិន័យបច្ចេកទេសនោះ ទានរបស់គេក៏មិនកើតជាទានតាមវិន័យឡើយ ។ បើជាកឋិនទាន ត្រូវមានបច្ចេកទេស ខាងវិន័យទាំងសង្ខាង គឺខាងទាយកស្គាល់វិន័យបច្ចេកទេសអំពីរឿងដេរកាត់បោកជ្រលក់ចីវរ, អំពីរឿងអង្គខ័ណ្ឌ នៃចីវរដែលគេដេរចំណាយស្រាប់ ។ ចំណែកខាងភិក្ខុគឺបដិគ្គាហកត្រូវស្គាល់វិន័យបច្ចេកទេសខាងក្រាលគ្រង និង អនុមោទនា, ខាងណាមួយមានកំហុស ក្នុងវិន័យបច្ចេកទេស សូម្បីត្រឹមតែបន្តិចបន្តួច ក៏ពុំកើតជាកឋិនឡើយ ។

*២៨.សំណួរៈ ការធ្វើទានត្រូវប្រកបទៅដោយអង្គ ប៉ុន្មានយ៉ាង ទើបមានផលានិសង្សច្រើន ? មានអ្វីខ្លះ ? ចូររៀបរាប់ទាំងសង្ខាង*

ចម្លើយៈ ដើម្បីធ្វើទានបានអានិសង្សច្រើន ត្រូវប្រកបដោយអង្គទាំង៦ យ៉ាងគឺខាងអ្នកឲ្យមាន ៣ ខាងអ្នកទទួលមាន ៣ ដូចខាងក្រោម ៖

### អង្គខាងអ្នកឲ្យ ៣ គឺៈ

១- អ្នកឲ្យ មានចិត្តត្រេកអរ ក្នុងកាលមុនឲ្យ (**បុព្វចេតនា**)

២- អ្នកឲ្យ ញ៉ាំងចិត្តជ្រះថ្លា ក្នុងកាលកំពុងឲ្យ (**មុញ្ចនចេតនា**)

៣- អ្នកឲ្យមានចិត្តត្រេកអរ ចំពោះទានដែលឲ្យរួចហើយ (**អបរាបរចេតនា**)

### អង្គខាងអ្នកទទួល ៣ គឺៈ

១-បដិគ្គាហក អ្នកទទួលទាន មានរាគៈទៅប្រាស់(ពីខន្ធសន្តាន)ហើយ ឬ កំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវ**រាគៈ** *(តម្រេក,ត្រេកត្រអាលចំពោះកាម)*

២-បដិគ្គាហក អ្នកទទួលទាន មានទោសៈទៅប្រាស់ (ពីខន្ធសន្តាន) ហើយឬកំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវ**ទោសៈ** *(ការប្រទូស្ត,គំហឹង,សម្អប់)*

៣-បដិគ្គាហក អ្នកទទួលទាន មានមោហៈទៅប្រាស់ (ពីខន្ធសន្តាន) ហើយ ឬ កំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវ**មោហៈ***(មិនស្គាល់ ខុសត្រូវ)* ។

រួមអង្គទាំង ពីរ ចំណែក គឺទាំងអ្នកឲ្យ ទាំងអ្នកទទួល ត្រូវជា ៦ ប្រការ ហៅថា **ឆឡង្គទាន**[(១៣)] ប្រែថា ទានប្រកបដោយអង្គទាំង ៦ ។ ទានប្រកបដោយអង្គ ៦ ប្រការនេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរថា នឹងបានផលានិសង្សច្រើន បុគ្គលណានីមួយ មិនអាចនឹងគណនារាប់ថា ចំនួន ប៉ុណ្ណេះ ប៉ុណ្ណោះបានឡើយ ។

***២៩.សំណួរ៖*** *បើទាយកអ្នកឲ្យទាន បានប្រកបតែអង្គពីរខាងដើមគឺ ពេលមុនឲ្យទាន មានចិត្តជ្រះថ្លារីករាយ ហៅថា បុព្វចេតនា១ ពេលកំពុងលះឲ្យមានចិត្តជ្រះថ្លារីករាយ ហៅថាមុញ្ចនចេតនា១ លុះឲ្យកន្លងស្រាប់តែកើតអកុសលចិត្ត គឺមច្ឆរិយៈជាសេចក្តីកំណាញ់ នឹកស្តាយក្រោយចំពោះវត្ថុទាំងប៉ុន្មានដែលបានបរិច្ចាគរួចហើយនោះទៅវិញ* ***តើទាយកនោះឈ្មោះថា បានទទួលផលពេញលេញដែរ ឬយ៉ាងណា ?*** *ចូរទាញឧទាហរណ៍ជាតួអាងផង!*

ចម្លើយ៖ ឈ្មោះថាទទួលផលពេញលេញដែរ ប៉ុន្តែ មិនបានសម្រេចប្រយោជន៍អ្វីក្នុងការដែលទទួលនោះឡើយ ព្រោះខ្វះ **អបរាបរចេតនា** ១ ខាងចុងទៀត តួយ៉ាងដូចរឿង អបុត្តកសេដ្ឋី ដែលមានសេចក្តីដំណាលថា *កាលពីអតីតជាតិ អបុត្តកសេដ្ឋីនោះកើតជាគហបតីម្នាក់ បានឃើញព្រះបច្ចេក ពុទ្ធព្រះនាមតគរសិខី កំពុងនិមន្តបិណ្ឌបាតតាមផ្លូវ ក៏មានសេចក្តី*

---

១៣ សុត្តន្តបិដក លេខ ៤៦ ទំព័រ ១១៤

*ជ្រះថ្លា ហើយស្រែកប្រាប់ទៅភរិយា ឲ្យប្រគេនបិណ្ឌបាតដល់លោក លុះប្រាប់ដូច្នោះហើយក៏ចេញទៅកាន់ទីដទៃទៅ ចំណែកខាងភរិយា បានឮពាក្យនោះហើយ ក៏ត្រេកអរចាត់ចែងភោជនដ៏ប្រណិតផ្ចិតផ្ចង់ យកទៅដាក់បាត្រប្រគេន ព្រះបច្ចេកពុទ្ធអង្គនោះ រួចហើយក៏លោកនិមន្តចេញទៅ ។ គហបតីនោះត្រឡប់មកវិញបានជួបនឹងព្រះបច្ចេកពុទ្ធនោះសួរថា លោកម្ចាស់បាន អ្វីខ្លះដែរ ឬ ទេ ? ហើយចូលទៅចាប់បាត្របើកមើល ឃើញនូវភោជនយ៉ាងល្អៗ ក៏បែរទៅជានឹកស្ដាយក្រោយថា ឱហ្ន៎! បិណ្ឌបាត(ចង្ហាន់) នេះល្អណាស់តើ ប្រសិនបើបានទាសកម្មករបរិភោគវិញ វានឹងធ្វើការឲ្យអញ ឯសមណៈនេះយកទៅបរិភោគ (ឆាន់) ឥតប្រយោជន៍សោះ ។*

*គហបតីនោះ លុះបានមកកើតជាអបុត្តកសេដ្ឋី ដោយអំណាចវិបាក (ផល) នោះឯង បណ្ដាលឲ្យមានសេចក្ដីកំណាញ់ ស្វិតស្វាញ ហួងហែងទ្រព្យសម្បត្តិ ទុកមិនឲ្យអ្នកដទៃ ទាំងមិនឲ្យចូលចិត្តប្រើប្រាស់របស់ល្អៗពេញចិត្ត និង ចូលចិត្តប្រើតែរបស់ណាអន់ថោកពុំទាន់សម័យក្នុងមួយជីវិតនេះជាទោស គឺ មកពីគ្មានចេតនាមួយខាងចុង **អបរាបរចេតនា** ហ្នឹងឯង ។*

***៣០.សំណួរ៖ បដិគ្គាហក អ្នកទទួលទាន ដែលមាន រាគៈ ទោសៈ និង មោហៈ ទៅប្រាសពីខន្ធសន្តានហើយនោះ តើសំដៅយកបុគ្គលថ្នាក់ណា ? ដែលថាកំពុងប្រតិបត្តិ ដើម្បីកំចាត់បង់នូវ រាគៈ ទោសៈ មោហៈ នោះសំដៅយកបុគ្គលថ្នាក់ណា ?***

ចម្លើយ៖ បុគ្គលដែលមានរាគៈទោសៈមោហៈទៅប្រាស់ពីខន្ធសន្តានហើយសំដៅយកបុគ្គលថ្នាក់ខ្ពស់គឺ អរិយបុគ្គល មានសោតាបន្នបុគ្គលជាដើម ឯបុគ្គលដែលកំពុងប្រតិបត្តិដើម្បីកំចាត់បង់នូវ រាគៈ ទោសៈ និង មោហៈ សំដៅយកបុគ្គលថ្នាក់បន្ទាប់គឺ កុលបុត្រដែលលះបង់ ឃរាវាសសម្បត្តិ

ហើយចេញទៅបួស ក្នុងព្រះពុទ្ធសាសនា ហើយសិក្សារៀនសូត្រចេះដឹង ហើយធ្វើសេចក្ដីប្រតិបត្តិដើម្បីកំចាត់បង់នូវកិលេសគឺ រាគៈ ទោសៈ មោហៈ ឲ្យអស់ពីខន្ធសន្ដាន បំណងនឹងឲ្យដល់ឋានៈជាអរិយបុគ្គលផងដែរ ។

***៣១.សំណួរ៖ ការឲ្យទាន ដែលលោកហៅថាជា ទានដ៏ប្រសើរខ្ពង់ខ្ពស់ មានប៉ុន្មានប្រការ ? អ្វីខ្លះ ?***

ចម្លើយ៖ ទានដ៏ប្រសើរខ្ពស់ខ្ពស់នោះមាន ៧ ប្រការគឺៈ

១-ឲ្យទាន ដើម្បីឆ្លងចាកតណ្ហា ដែលជាគ្រឿងនាំ ឬ បណ្ដើរសត្វឲ្យអន្ទោលកើតស្លាប់ក្នុងភពតូចភពធំ ។

២-ឲ្យទាន ដោយសេចក្ដីគោរព គឺគោរពគ្រប់ទ្វារទាំងបី(កាយ វាចា ចិត្ត) ព្រមទាំងទេយ្យវត្ថុដែលត្រូវលះឲ្យ មិនឲ្យដោយអាការៈសោះអង្គើយ

៣-ឲ្យទាន ដោយសេចក្ដីខ្មាសបាប ក្ដៅនឹងបាប ។

៤-ឲ្យទាន ដោយមិនគិតសំចៃទុកគឺមិននឹកស្ដាយក្រោយ ។

៥-ឲ្យទាន ចំពោះទក្ខិណេយ្យបុគ្គល ។

៦-ឲ្យទាន ដោយសោមនស្សរីករាយ និង ការពិចារណាឃើញប្រយោជន៍ជាក់លាក់ មិនស្រវិនស្រវាន់ដោយវិចិកិច្ឆានីវរណៈ ។

៧-ឲ្យទាន ដោយគ្រឿងអលង្ការ និង បរិវារនៃចិត្តគឺតាំងចិត្តថានឹងយកការឲ្យទានជាគ្រឿងប្រដាប់សម្រាប់ជាលំអររបស់ជាគ្នានឹងចិត្ត ។

***៣២.សំណួរ៖ វត្ថុដែលរាប់បញ្ចូលថាជា ភោជនាហារ ហើយលោក ហៅថា បិណ្ឌបាតប្បច្ច័យ នោះបានដល់ វត្ថុអ្វី ?***

ចម្លើយ៖ វត្ថុដែលរាប់បញ្ចូលថាជាភោជនាហារនោះមានច្រើនយ៉ាងគឺ បាយ នំ (នំស្រស់,នំក្រៀម) ត្រី សាច់ ផ្លែឈើ និង មើមឈើ ជាដើម ។

*៣៣.សំណួរ៖ វត្ថុដែលរាប់បញ្ចូល ជាភោជនាហារហើយ ទាយកមិនគួរប្រគេនដល់ភិក្ខុក្នុងវេលាណា ? ចូរអធិប្បាយឲ្យបានសព្វគ្រប់ !*

ចម្លើយ៖ ទាយកមិនគួរប្រគេនដល់ភិក្ខុក្នុងវេលាវិកាល គឺតាំងពីវេលារសៀលទៅដល់យប់ ឲ្យលោកទទួលផ្ទាល់ដៃឡើយ បើប្រគេនដោយសម្ដីជាកប្បិយវោហាបាន គឺបវរណាឲ្យលោកដឹង ហើយប្រគល់វត្ថុនោះដល់កប្បិយការកៈ គឺកូនសិស្សរបស់លោក អ្នកទទួលរៀបចំទុកដាក់ សម្រេចកិច្ចប្រគេន, ចំណែកលោកត្រូវគ្រាន់តែទទួលដឹងដោយចិត្តតែប៉ុណ្ណោះបើប្រគេនដូច្នេះ ទើបលោកឆាន់ភោជននោះទៅថ្ងៃក្រោយទៀតបានឥតមានទោស ។ ភោជននោះកុំថាឡើយវត្ថុទទួលផ្ទាល់ដៃក្នុងកាលខុស សូម្បីទទួលភោជនណាមួយក្នុងកាលត្រូវហើយ ទុកដាក់ដោយខ្លួនឯងឲ្យកន្លងរាត្រីមួយឡើងទៅ ភិក្ខុឆាន់ភោជននោះត្រូវ អាបត្តិបាចិត្តិយៈ នៅត្រង់សន្និធិការកសិក្ខាបទ ដោយពិត ។ មួយទៀតភោជនាហារដែលភិក្ខុត្រូវលេបចូលទៅក្នុងបំពង់កទាំងប៉ុន្មាន លុះតែប្រគេនដោយត្រឹមត្រូវទើបឆាន់បាន វៀរលែងតែទឹកសុទ្ធ គឺទឹកដែលឥតលាយដោយវត្ថុអ្វីមួយ និង ឈើស្ទន់(ឈើចាក់ធ្មេញ)ចេញ មិនបាច់ប្រគេន គ្រាន់តែយកទៅដាក់ក្បែរភិក្ខុប្រើប្រាស់ឆាន់បានឥតមានទោស ឬ អាបត្តិអ្វីឡើយ ។

*៣៤.សំណួរ៖ ការប្រគេនវត្ថុអ្វីមួយដល់ភិក្ខុ ត្រូវប្រកបដោយអង្គប៉ុន្មានយ៉ាងទើបហៅថា ប្រគេន ? អង្គប្រគេន ទាំងនោះមាន អ្វីខ្លះ ?*

ចម្លើយ៖ ការប្រគេនវត្ថុអ្វីមួយដល់ភិក្ខុត្រូវប្រគេនប្រកបដោយអង្គ ៥ យ៉ាង ទើប ហៅថា ប្រគេន ។ បណ្ដាអង្គប្រគេនទាំង ៥ នោះគឺៈ

១-វត្ថុដែលមានទម្ងន់ល្មមបុរសមានកម្លាំងយ៉ាងកណ្តាល លើកម្នាក់ឯងរួច[១៤] គឺសំដៅយកបុរសដែលមានវ័យកណ្តាល កំពុងពេញកម្លាំង។

២-ត្រូវហត្ថបាសប្រាកដ គឺអ្នកប្រគេនស្ថិតនៅក្នុងហត្ថបាស២ហត្ថ ១ ចំអាម (សម្រាប់ ហត្ថបាសប្រគេន គឺមានចម្ងាយ ២ ហត្ថ ១ ចំអាម) ។

៣-អ្នកប្រគេនត្រូវបន្ទន់ខ្លួន បង្អោនវត្ថុចូលមក គឺបង្អោនចូលមកសម្តែងឲ្យឃើញថា ជាអ្នកត្រូវការប្រគេនពិត ។

៤-ទេវតាក្តី មនុស្សក្តី សត្វតិរច្ឆានក្តី ប្រគេនគឺពិតជាមានគេប្រគេនមែន ។

៥-ភិក្ខុទទួលវត្ថុនោះដោយកាយផ្ទាល់ក្តី ដោយវត្ថុជាប់នឹងកាយក្តី។

***៣៥.សំណួរ៖ ត្រង់អង្គទី២ ពាក្យថា ត្រូវហត្ថបាសប្រាកដ គឺអ្នកប្រគេនស្ថិតនៅក្នុងហត្ថបាស ២ហត្ថ ១ចំអាមនោះ តើហត្ថបាស ប្រែដូចម្តេច ? កំណត់ត្រឹមណាដល់ទីត្រឹមណា ទើបស្ថិតនៅក្នុងហត្ថបាស ? ចូរពន្យល់មកមើល៍***

ចម្លើយ៖ *ហត្ថបាស* ប្រែថា *អន្ទាក់ដៃ* ក្នុងទីនេះជាឈ្មោះឱកាសដែលត្រូវលាតដៃប្រគេន លាតដៃទទួល មិនលាតលូក ឬ ឈោងដៃចូលទៅឲ្យកើនលើសប្រមាណ ។ ឯពិធីដែលនឹងវែហត្ថបាស ២ ហត្ថ ១ ចំអាម នោះគឺ

- ចំណែកខាងទាយកអ្នកប្រគេន ត្រូវគិតហត្ថបាសពីត្រឹមទីបំផុតខាងក្នុងអវយវៈខ្លួនចូលទៅ ។

---

[១៤] បើវត្ថុគឺភាជនៈដូចជា តុ ថាស ជាដើមដែលដាក់តម្កល់ចង្ហាន់លើនោះជារបស់ធ្ងន់ហួសប្រមាណ បើទាយកមិនអាចលើប្រគេនម្នាក់ឯងរួចទេ គប្បីចូលទៅជិតបដិគ្គាហក ឲ្យជាប់ហត្ថបាសហើយចាប់លើកជ្រុងតុ ឬ ថាសបង្អើបឲ្យផុតបន្តិចឡើងប្រគេនទៅ ក៏ឈ្មោះថាប្រគេនដោយពិតទាំងបដិគ្គាហក ក៏គួរទទួលឆាន់បានដោយឥតមានទោសឡើយ ។

- ចំណែកខាងបដិគ្គាហក គឺភិក្ខុអ្នកទទួល ត្រូវគិតពីត្រឹមទីបំផុតខាងក្រៅអវយវៈ (លោក) ចូលមក ។

- ផ្សំគ្នាទៅឲ្យបានប្រវែង ២ ហត្ថ ១ ចំអាម គឺបើទាយកឈរប្រគេនចំពីមុខ (ភិក្ខុក៏ឈរទទួលដូចយ៉ាង ទទួលភត្តដែលគេដាក់បាត្រ) ត្រូវគិតពីត្រឹមមេជើងទាយកចូលទៅ ភិក្ខុត្រូវគិតពីចុងបំផុតកែងជើងចូលមក ឲ្យបានប្រវែង ២ ហត្ថ ១ ចំអាម, យ៉ាងនេះហៅថា **ហត្ថបាស**[១៥] គឺល្មមលាតដៃប្រគេនលាតដៃទទួលបានដោយគោរព បុរសក្តី ស្ត្រីក្តី អាចប្រគេន ឬ ដាក់បាត្របានដូចគ្នា ។

- បើ ទាយក និង បដិគ្គាហក អង្គុយដូចគ្នាក្តី ម្នាក់ឈរ ម្នាក់អង្គុយ ឬដេកក្តី ប្រគេនចំពីមុខក្តី ពីក្រោយឬពីខាងក្តី ក៏មានទំនងដូចន័យនេះដែរ, អ្នកប្រគេនត្រូវគិតពីខាងក្នុងចូលទៅ អ្នកទទួលត្រូវគិតពីខាងក្រៅចូលមក រួមប្រវែងហត្ថបាសទៅឲ្យបាន ២ ហត្ថ ១ ចំអាម,មិនចាំបាច់វាស់ទេគ្រាន់តែលៃស្មានមើលឲ្យឃើញល្មមបាន ២ ហត្ថ ១ ចំអាម ប៉ុណ្ណោះ ឬ ឲ្យជិតជាងនេះបន្តិចក៏ឥតទាស់ កុំឲ្យតែជិតពេកបើស្ត្រីក្រែងប្រគេន ឬ ដាក់បាត្រពុំកើត ត្រូវចេះលៃឲ្យបានស្រួលទាំងអ្នកប្រគេន និង អ្នកទទួល ។

***៣៦.សំណួរៈ ត្រង់អង្គទី ៥ ថាភិក្ខុទទួលវត្ថុនោះដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ពាក្យថាទទួលផ្ទាល់ដោយកាយនោះដូចម្តេច ? ទទួលដោយវត្ថុដែលជាប់នឹងកាយនោះដូចម្តេច ? ចូរអធិប្បាយទាំងពីរមកមើល៍ !***

---

[១៥] ហត្ថបាស មានពីរគឺៈ ហត្ថបាសសង្ឃកម្ម មានចម្ងាយ ១ ហត្ថ ១ ចំអាម, និង ហត្ថបាសប្រគេន

ចម្លើយ៖ ពាក្យថាទទួលដោយផ្ទាល់កាយនោះ បើទាយកប្រគេនអ្វីមួយភិក្ខុលូកដៃទៅទទួលចាប់កាន់វត្ថុដែលប្រគេននោះផ្ទាល់នឹងដៃ មិនមានភាជនៈអ្វីមួយមានជើងពានជាដើម ទៅទទួលយក ហៅទទួលផ្ទាល់ដោយកាយ ។

ពាក្យថាទទួលដោយវត្ថុដែលជាប់នឹងកាយនោះ បើទាយកប្រគេនវត្ថុអ្វីមួយ ភិក្ខុកាន់សំពត់ ឬ ភាជនៈមានជើងពានជាដើម លូកទៅទទួលទស់យក ឬ ផ្ទេរយកវត្ថុដែលគេប្រគេននោះមិនបានទទួលទស់យកផ្ទាល់នឹងដៃសុទ្ធ ហៅថាទទួលដោយវត្ថុដែលជាប់ដោយកាយ ។

***សំណួរពិសេស៖ តើមានហេតុប៉ុន្មានយ៉ាង ដែលធ្វើឲ្យដាច់ប្រគេនលោក ? បើយើងប្រគេនចង្ហាន់លោករួចហើយ អាចប៉ះបានដែរ ឬ ទេ ?***

ចម្លើយពិសេស៖ ហេតុដែលនាំឲ្យដាច់ប្រគេន ៧ យ៉ាង

១.ចង្ហាន់ភិក្ខុ ដែលទទួលប្រគេនហើយ តែលោកប្រែភេទជាស្រីវិញ

២.ចង្ហាន់ភិក្ខុ ដែលទទួលប្រគេនហើយ តែលោកធ្វើមរណកាលទៅ

៣.ចង្ហាន់ភិក្ខុ ដែលទទួលប្រគេនហើយ តែលោកលាចាកសិក្ខាបទទៅ

៤.ចង្ហាន់ភិក្ខុ ដែលទទួលប្រគេនហើយ តែលោកចូលកាន់សាសនាដទៃវិញ

៥.ចង្ហាន់ភិក្ខុ ដែលទទួលប្រគេនហើយ លោកលះបង់ដល់អនុបសម្បន្ន

៦.ចង្ហាន់ភិក្ខុ ដែលទទួលប្រគេនហើយ លោកលះបង់ចោលលែងអាល័យ

៧.ចង្ហាន់ភិក្ខុ ដែលទទួលប្រគេនហើយ ចោរដណ្តើមយកទៅ ។

*កំណត់ចំណាំ:* ត្រង់ពុទ្ធបរិស័ទប៉ះ ឬ កាន់ពេលប្រគេនរួចហើយ ឈ្មោះថាមិនដាច់ប្រគេនទេ បើត្រូវការបន្ថែមចង្ហាន់ ឬ សម្លថ្មីទៀតក្នុងចានលោកកំពុងឆាន់ ត្រូវតែប្រគេនសាជាថ្មីទើបគួរ តែបើលោកកាន់ចាននោះស្រេចហើយ មិនចាំបាច់ប្រគេនទៀតទេ ។ ត្រង់កន្លែងដែលចង្អៀត យើងអាចជួយកាស ឬ សម្រួលចង្ហាន់លោកឲ្យបានស្រួលជាការប្រពៃណាស់ ។

*៣៧.សំណួរ៖ ទេយ្យវត្ថុជាពីជគាម ឬ ភូតគាម គឺវត្ថុដែលមានគ្រាប់ មើម ដើម ឬស ទង ជាពូជល្មមដុះទៅទៀតបាន ដូចជាផ្លែម្ទេសទុំ ត្របែកទុំ ដើមអំពៅ សណ្តែកបណ្តុះ ទងដំឡូង ទងកញ្ឆែតជាដើម បើទាយកមានប្រាថ្នានឹងធ្វើទានដល់សមណៈក្នុងព្រះពុទ្ធសាសនាគប្បី ធ្វើដូចម្តេចឲ្យជារបស់គួរលោកទទួលឆាន់បាន ?*

ចម្លើយ៖ គប្បីអុជ ដុត ពុះ ចោះ ចុច ឬស្រុស ធ្វើឲ្យស្រេចជារបស់ កប្បិយៈ ត្រូវតាមពុទ្ធានុញ្ញាតដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាត សមណកប្ប ៥ ប្រការ ដល់ភិក្ខុទាំងឡាយនោះទើបលោកទទួលឆាន់បានមិនខុសនឹងវិនយប្បញ្ញត្តិ ក្នុងភូតគាមសិក្ខាបទ ។

*៣៨.សំណួរ៖ សមណកប្ប ប្រែដូចម្តេច ? មាន ៥ យ៉ាងនោះ អ្វីខ្លះ ?*

ចម្លើយ៖ សមណកប្ប ប្រែថា វត្ថុជារបស់គួរដល់សមណៈ ឬ វត្ថុដែលគួរដល់សមណៈទទួលបរិភោគប្រើប្រាស់បាន,មាន ៥ ប្រការនោះគឺៈ

១-វត្ថុដែលគេអុជ ដុត កំដៅភ្លើង ឬ ស្រុស

២-វត្ថុដែលគេពុះ ចោះ ចិតដោយសាស្ត្រា (កាំបិត)

៣-វត្ថុដែលគេចុច ឬ កេះដោយក្រចក

៤-វត្ថុដែលគ្មានពូជដុះតទៅទៀតបាន (ផ្លែឈើខ្ចី)

៥-ផ្លែដែលមានពូជបន្លិចយកគ្រាប់ចេញបាន ។

*៣៩.សំណួរ៖ អង្គនៃការទទួលប្រគេន ៥ ប្រការ និងសមណកប្ប ៥ ប្រការ ដែលបានពោលរួចមកហើយ ទាយកអ្នកឲ្យទានគួរសិក្សាឲ្យចាំស្ទាត់ឬទេ ?*

ចម្លើយ៖ គួរណាស់ គួរសិក្សាសង្កេតមើលឲ្យចេះចាំចូលចិត្តស្ទាត់កុំខាន ព្រោះជាកិច្ច ឬជាផ្លូវដែលទាយក ទាយិកាតែងធ្វើរឿយៗដើម្បីកុំឲ្យខុសឆ្គងនឹងវិនយប្បញ្ញត្តិ ព្រមទាំងអាចធ្វើទានទៅបានដោយល្អប្រសើរទៀតផង ។

*៤០.សំណួរ៖ បច្ច័យទាំង ៤ យ៉ាងគឺ ចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ គិលានភេសជ្ជប្បច្ច័យ បើទាយកធ្វើទាន ដល់វេលាប្រគេន ត្រូវតែលើកប្រគេន ឲ្យជាប់ហត្ថបាសដូចគ្នា ឬ ផ្សេងគ្នាយ៉ាងណា ?*

ចម្លើយ៖ ផ្សេងគ្នាយ៉ាងនេះគឺ ចីវរប្បច្ច័យ និងសេនាសនប្បច្ច័យ ទាយកប្រគេនដោយវាចា គឺគ្រាន់តែសូត្របាលីវេរ ឬ គេនិយាយប្រគេនជាសម្រាយ ក៏បានឈ្មោះថាប្រគេនដោយពិត ភិក្ខុទទួលប្រើប្រាស់បានឥតមានទោស ព្រោះជាបច្ច័យមិនបានលេបចូលទៅក្នុងបំពង់ក ។

រីឯ បិណ្ឌបាតប្បច្ច័យ និង គិលានភេសជ្ជប្បច្ច័យ ទោះទាយកបាននាំមកតម្កល់ទុកក្នុងទីចំពោះមុខភិក្ខុសង្ឃជាប់ហត្ថបាស រួចសូត្រវេរជាបាលី ឬ សម្រាយសព្វគ្រប់ហើយក្តី ត្រូវតែទាយកលើកបច្ច័យនោះប្រគេនឲ្យត្រូវតាមអង្គប្រគេនទាំង ៥ ប្រការនោះទៀត ទើបឈ្មោះថាប្រគេន, ភិក្ខុក៏ទទួលឆាន់បានឥតមានទោសពៃរ៍អ្វីឡើយ ។

*៤១.សំណួរ៖ ដំណើរការឲ្យទានរមែងជាប់ទាក់ទងដោយវត្ថុខ្លះ ដោយចេតនាខ្លះ ដោយបុគ្គលអ្នកឲ្យខ្លះ ដោយបុគ្គលអ្នកទទួលខ្លះតាមឈ្មោះផ្សេងៗពីគ្នា តែបើពោលតាមភូមិបុគ្គល និង វត្ថុមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?*

ចម្លើយ៖ មាន ៣ យ៉ាងគឺៈ

១-បុគ្គលណាបរិភោគ វត្ថុថោកទាបដោយខ្លួនឯង លុះត្រូវការឲ្យទានដល់បុគ្គលដទៃ ក៏ចាត់ចែងវត្ថុដ៏ថ្លៃថ្លា បុគ្គលនោះឈ្មោះថា **ទានបតិ** ឬ **ទានស្វាមិ** ប្រែថាអ្នកមានទានជាម្ចាស់ គឺថាលើកទានឲ្យទៅជាម្ចាស់

២-បុគ្គលណាបរិភោគវត្ថុបែបណា ដោយខ្លួនឯង លុះត្រូវការឲ្យទានបុគ្គលដទៃក៏ឲ្យវត្ថុបែបនោះដែរ បុគ្គលនោះឈ្មោះថា **ទានសហាយ** ប្រែថាអ្នកមានទានជាសម្លាញ់ ឬ ជាគ្នា ។

៣-បុគ្គលណាបរិភោគវត្ថុថ្លៃថ្លាខ្លួនឯង លុះវេលាឲ្យទានក៏ត្រឡប់ជាយកវត្ថុថោកទាប ទៅឲ្យដល់បុគ្គលដទៃវិញ បុគ្គលនោះឈ្មោះថា **ទានទាស** ប្រែថា អ្នកមានទានជាខ្ញុំបម្រើ ឬ ជាទានយ៉ាងថោកថយ ។

***៤២.សំណួរៈ ការបរិច្ចាគទានតាមភូមិនៃបុគ្គលនិងវត្ថុ ដូចបានពោលមកនេះ តើបានអានិសង្សផ្សេងគ្នាយ៉ាងណាខ្លះ ?***

ចម្លើយៈ បានអានិសង្សផ្សេងគ្នាយ៉ាងនេះគឺ បានអានិសង្សតាមថ្នាក់យ៉ាងខ្ពង់ខ្ពស់ កណ្តាល ថោកទាប តាមលំដាប់នៃទាននោះៗ ដែរ ។

***៤៣.សំណួរៈ បើពោលរួបរួមដោយអានិសង្សនៃអាមិសទាន មានប៉ុន្មាន ?***

ចម្លើយៈ អានិសង្សនៃអាមិសទាន មាន ៥ យ៉ាងគឺៈ

១-អ្នកឲ្យទានរមែងជាទីស្រឡាញ់ពេញចិត្តនៃអ្នកផងច្រើនគ្នា ដែលនៅជិតខាង ឬ នៅក្នុងទីឆ្ងាយ ។

២-ពួកសប្បុរសរមែងរាប់រកសង្គ្រោះ នូវបុគ្គលដែលមានសទ្ធាធ្វើទាន ដោយការស្វែងរកប្រយោជន៍ នឹងប្រាថ្នាចង់ឲ្យបុគ្គលនោះបានសេចក្តីសុខ សេចក្តីចម្រើនគ្រប់កាល ។

៣-កិត្តិស័ព្ទគឺ កេរ្តិ៍ឈ្មោះដ៏ពិរោះរមែងខ្ចរខ្ចាយ ផ្សាយទៅក្នុងទិសទាំងពួង ទាំងមនុស្ស និង ទេវតាក៏រមែងឲ្យសព្ទសាធុការពរ ។

៤-អ្នកឲ្យទាន ទោះចូលទៅកាន់ចំណោមបរិស័ទណាមួយ រមែងមានសេចក្តីក្លៀវក្លា អង់អាច មិនក្រអឹមក្រអៀម ។

៥-អ្នកឲ្យទាន លុះបែកធ្លាយរាងកាយឃ្លាតចាកលោកនេះ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក លុះច្យុតចាកទេវលោកដោយអំណាចអស្សន្នកុសលជាប់មក ក៏បានមកកើតក្នុងមនុស្សលោកនេះទៀត រមែងកើតក្នុងត្រកូលខ្ពស់ដែលបរិបូណ៌ដោយភោគសម្ប័ទ ។

*៤៤.សំណួរ៖ អានិសង្សទាំង ៥ យ៉ាងដូចពោលមកនេះ ចែកចេញជាប៉ុន្មានផ្នែក ? ផ្នែកប៉ុន្មានជាសន្ទិដ្ឋិកផល ? ផ្នែកប៉ុន្មានជាសម្បរាយិកផល ?*

ចម្លើយ៖ ចែកចេញជា ២ ផ្នែកគឺផ្នែកអានិសង្ស ៤ ខាងដើមជាសន្ទិដ្ឋិកផល គឺ ផលដែលគួរឃើញជាក់ច្បាស់ ដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ, ព្រមទាំងផ្នែកអានិសង្សមួយខាងចុង ជាសម្បរាយិកផល គឺ ផលដែលត្រូវបានជួបប្រសព្វឃើញច្បាស់ក្នុងបរលោក (លោកខាងមុខ) ។

*៤៥.សំណួរ៖ ការធ្វើទានដែលអាចឲ្យមាន ផលានិសង្សច្រើន ត្រូវប្រកបដោយអង្គប៉ុន្មាន ? មានអ្វីខ្លះ ?*

ចម្លើយ៖ ការឲ្យទានមានផលានិសង្សច្រើនត្រូវប្រកបដោយអង្គ បី គឺៈ

១- **ចេតនា** គំនិតដែលនាំចិត្តឲ្យភ្ញាក, ឲ្យផ្តួចគិត ក្នុងការលះឲ្យ

២- **វត្ថុ** ជារបស់ ឬ ទេយ្យធម៌ដែលមានសម្រាប់លះឲ្យ

៣- **បដិគ្គាហក** បុគ្គល អ្នកទទួលទាន (ព្រះសង្ឃ ឬ អ្នកមានសីល)

ការដល់ព្រមដោយអង្គទាំង បី នេះជាការងាយស្រួល ប្រសើរសម្រាប់អ្នកធ្វើទានផង និង បានផលានិសង្សច្រើនផង ។

*៤៦.សំណួរ៖ អង្គទី ១ គឺ ចេតនា នោះបានដល់ ចេតនាយ៉ាងណាខ្លះ ?*

ចម្លើយ៖ បានដល់ចេតនាយ៉ាងនេះគឺ អ្នកឲ្យទានត្រូវញ៉ាំងចេតនាឲ្យជ្រះថ្លាគ្រប់កាលទាំង បី គឺៈ

- មុនពេលនឹងឲ្យ ត្រូវញ៉ាំងចិត្តរបស់ខ្លួនឲ្យរីករាយចំពោះវេលាដែលខ្លួនបម្រុងឲ្យ ១ (**បុព្វចេតនា**) ។
- ក្នុងពេលកំពុងឲ្យ ត្រូវញ៉ាំងចិត្តរបស់ខ្លួនឲ្យរីករាយចំពោះទេយ្យវត្ថុ និង បដិគ្គាហក ១ (**មុញ្ចនចេតនា**) ។

- ក្រោយពេលដែលឲ្យរួចហើយ ក៏ត្រូវញុាំងចិត្តរបស់ខ្លួន ឲ្យរីករាយថែមមួយកម្រិតទៀត ១ (**អបរាបរចេតនា**) ។

*៤៧.សំណួរៈ អង្គទី ២ គឺ វត្ថុ បានដល់ វត្ថុ អ្វីខ្លះ ?*

ចម្លើយៈ បានដល់វត្ថុគឺ បច្ច័យ មានចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យជាដើម ជាបច្ច័យដ៏បរិសុទ្ធប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ ។

*៤៨.សំណួរៈ អង្គទី៣ គឺបដិគ្គាហក នោះសំដៅយកបដិគ្គាហក បែបណា ?*

ចម្លើយៈ សំដៅយកបដិគ្គាហក ដែលបានកំចាត់ រាគៈ ទោសៈ និង មោហៈ ចេញពីខន្ធសន្តានហើយ និងលោកដែលកំពុងសិក្សាធ្វើនូវសេចក្តីប្រតិបត្តិ ដើម្បីកំចាត់បង់នូវ រាគៈ ទោសៈ មោហៈឲ្យអស់ពីខន្ធសន្តាន ក៏រាប់ថាជាបដិគ្គាហក ដែរ ។

*៤៩.សំណួរៈ ទានដែលទាយកឲ្យដល់បដិគ្គាហក បដិគ្គាហក អាចធ្វើទានរបស់ទាយកនោះឲ្យមានផលានិសង្សតិច និងច្រើនជាងគ្នាពិតឬ ? ហេតុអ្វី?*

ចម្លើយៈ បដិគ្គាហក អាចធ្វើទានរបស់ទាយកឲ្យមានផលតិច និងច្រើនជាងគ្នាពិតមែន ព្រោះបដិគ្គាហក ខ្លះ មានគុណធម៌និងសីលធម៌តិច ខ្លះមានគុណធម៌និងសីលធម៌ច្រើន ខ្លះឥតមានគុណធម៌ និងសីលធម៌អ្វីសោះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ហេតុនោះបានជាទាយកឲ្យទានមានផលតិច និងច្រើនជាងគ្នា ដូចមានសេចក្តីសម្តែងទុកក្នុងវេលាមសូត្រថាៈ

*កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង កើតជាវេលាមព្រាហ្មណ៍ បានបរិច្ចាគទាន មានខាទនីយៈនិងភោជនីយៈ (បង្អែម និងចំអាប) ជាដើមដល់លោកិយមហាជន[១៦] អស់ពេល ៧ ឆ្នាំ និង ៧ ខែ ឥតមានសល់ថ្ងៃណាមួយ*

---

១៦ ច្រើនតែជនទ្រុស្តសីល សូម្បីតែសរណគមន៍ ៣ ក៏មិនមានផង

*ឡើយ លុះដល់ថ្ងៃបង្ហើយបុណ្យ ក៏បានបរិច្ចាគទ្រព្យយ៉ាងច្រើនក្រៃលែងគឺ ភាជនៈមាសពេញទៅដោយមាសភាជនៈប្រាក់ពេញទៅដោយប្រាក់ភាជនៈ សំរឹតពេញទៅដោយសំរឹត ក្នុងភាជនៈមួយមុខៗចំនួន* ***ប្រាំបីម៉ឺនបួនពាន់*** *មិនតែប៉ុណ្ណោះ បានបរិច្ចាគ ដំរី សេះ គោ រថ ស្រីកញ្ញា និងសំពត់ សុទ្ធតែ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាងទាំងអស់ ក្នុងរបស់នីមួយៗ មាន ចំនួន ប្រាំបីម៉ឺនបួនពាន់ ដូចគ្នា ទាននេះ លោកហៅថា* **មហាទាន** *(ការ ដាក់ទានច្រើន ឬ ឲ្យទានច្រើនៗ)* ។

- ទានដែលគេឲ្យដល់សោតាបន្នបុគ្គលតែម្នាក់ មានផលច្រើនជាង មហាទាននោះទៅទៀត ។

- ទានដែលគេឲ្យដល់ សកទាគាមិបុគ្គលតែម្នាក់ មានផលច្រើនជាង ទានដែលគេឲ្យដល់សោតាបន្នបុគ្គលចំនួនមួយរយនាក់ទៅទៀត ។

- ទានដែលគេឲ្យដល់ អានាគាមិបុគ្គលតែម្នាក់ មានផលច្រើនជាង ទាន ដែលគេឲ្យដល់ សកទាគាមិបុគ្គលចំនួន ១០០ នាក់ទៅទៀត ។

- ទានដែលគេឲ្យដល់ បុគ្គលជាព្រះអរហន្តតែម្នាក់ មានផលច្រើន ជាងទាន ដែលគេឲ្យដល់ អានាគាមិបុគ្គលចំនួន ១០០ នាក់ទៅទៀត ។

- ទានដែលគេឲ្យដល់ ព្រះបច្ចេកពុទ្ធតែមួយអង្គ មានផលច្រើនជាង ទាន ដែលគេឲ្យដល់ បុគ្គលជាព្រះអរហន្តចំនួន ១០០ អង្គទៅទៀត ។

- ទានដែលគេឲ្យដល់ ព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គ មានផលច្រើន ជាង ទានដែលគេឲ្យដល់ ព្រះបច្ចេកពុទ្ធចំនួន ១០០ អង្គទៅទៀត ។

- ទានដែលគេឲ្យដល់ សង្ឃមានព្រះពុទ្ធជាប្រធាន មានផលច្រើន ជាងទានដែលគេឲ្យដល់ ព្រះសម្មាសម្ពុទ្ធ តែមួយព្រះអង្គទៅទៀត ។

- វិហារទាន គឺការឲ្យទីលំនៅ មានកុដិ សាលាជាដើមដល់សង្ឃដែលនិមន្តមកពីទិសទាំងបួន មានផលច្រើនជាងទាន ដែលគេឲ្យដល់សង្ឃមានព្រះពុទ្ធជាប្រធាននោះទៅទៀត ។

សេចក្តីទាំងអស់នេះ ប្រៀបដូចដីស្រែដែលមានជីជាតិ និង ដីស្រែដែលមិនមានជីជាតិ ដីស្រែណាដែលមានជីជាតិល្អ អ្នកស្រែយកពូជស្រូវទៅព្រោះសាបក្នុងស្រែនោះ ស្រែនោះឯងក៏អាចបណ្តាលឲ្យមានផលគឺផ្លែផ្កាចម្រើនដល់អ្នកម្ចាស់ស្រែនោះវិញយ៉ាងណា ឯបដិគ្គាហកណាដែលមានគុណធម៌ និងសីលធម៌ដ៏បរិសុទ្ធល្អ ទេយ្យវត្ថុដែលទាយកនាំយកទៅតម្កល់ទុកក្នុង បដិគ្គាហក នោះៗឯង អាចធ្វើទានរបស់ទាយកនោះឲ្យមានផលច្រើន ក៏យ៉ាងនោះដែរ ។ មួយទៀតដីស្រែណាដែលប្រកបដោយគ្រួសរវានឥតមានជីជាតិ អ្នកស្រែយកពូជស្រូវទៅព្រោះសាបក្នុងដីស្រែនោះៗឯងមិនអាចធ្វើពូជនោះឲ្យមានផល គឺផ្លែផ្កាចម្រើនដល់អ្នកម្ចាស់ស្រែនោះវិញយ៉ាងណា,ឯ បដិគ្គាហក ដែលមិនមានគុណធម៌ និងសីលធម៌ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទេយ្យវត្ថុដែលទាយកនាំយកទៅតម្កល់ទុកក្នុងបដិគ្គាហក នោះៗឯង មិនអាចធ្វើទានរបស់ទាយកនោះ ឲ្យមានផលច្រើនឡើយ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះបដិគ្គាហក អាចធ្វើទានរបស់ទាយកឲ្យមានផលតិច និងច្រើនជាងគ្នាយ៉ាងនេះ ។

***៥០.សំណួរ៖ បដិគ្គាហក ដែលធ្វើទាន របស់ទាយកឲ្យថយផល មានប៉ុន្មានពួក ? អ្វីខ្លះ ?***

ចម្លើយ៖ បដិគ្គាហក ដែលធ្វើទានរបស់ទាយកឲ្យថយផលមាន ៨ ពួកគឺ:

១- អ្នកមាន សេចក្តីយល់ឃើញខុស

២- អ្នកមាន ការត្រិះរិះខុស

៣- អ្នកមាន   វាចា(ពាក្យសម្ដី)ខុស

៤- អ្នកមាន   ការងារខុស

៥- អ្នកមាន   ការងារចិញ្ចឹមជីវិតខុស

៦- អ្នកមាន   ព្យាយាមខុស

៧- អ្នកមាន   សតិខុស

៨- អ្នកមាន   ការតាំងចិត្តខុស ។

*៥១.សំណួរ៖ បដិគ្គាហក ដែលធ្វើទានរបស់ទាយកឲ្យមានផលច្រើន មានប៉ុន្មានពួក ? មានអ្វីខ្លះ ?*

ចម្លើយ៖ បដិគ្គាហក ដែលធ្វើទានទាយកឲ្យមានផលច្រើនមាន ៨ ពួកគឺៈ

១- អ្នកមាន   សេចក្ដីយល់ឃើញត្រូវ

២- អ្នកមាន   ការត្រិះរិះត្រូវ

៣- អ្នកមាន   វាចា(ពាក្យសម្ដី)ត្រូវ

៤- អ្នកមាន   ការងារត្រូវ

៥- អ្នកមាន   ការងារចិញ្ចឹមជីវិតត្រូវ

៦- អ្នកមាន   ព្យាយាមត្រូវ

៧- អ្នកមាន   សតិត្រូវ

៨- អ្នកមាន   ការតាំងចិត្តត្រូវ ។

*៥២.សំណួរ៖ ទានណាដែលគេឲ្យដល់សត្វតិរច្ឆាន ដើម្បីចិញ្ចឹមបំណងឲ្យបរិបូណ៌ដោយគុណ មានលក្ខណៈសម្ព័ទជាដើមក្តី បំណងយកទឹកដោះឬឲ្យចាំផ្ទះឬក៏ឲ្យថែរក្សាទ្រព្យសម្បត្តិជាដើមក្តី ទាននោះលោកសង្គ្រោះថាជាទានបានបុណ្យ ឬទេ ? ព្រោះហេតុអ្វី ?*

ចម្លើយ៖ទានដែលគេឲ្យដល់សត្វតិរច្ឆានហើយសម្លឹងយកគុណនិងឧបការៈអំពីសត្វតិរច្ឆាននោះៗ វិញយ៉ាងនេះ លោកមិនសង្គ្រោះថា ជាទានបានបុណ្យទេ ព្រោះហេតុនៃការឲ្យនោះមិនត្រូវតាមលក្ខណៈរបស់ទាន ។

*៥៣.សំណួរ៖ ការឲ្យទានដល់សត្វតិរច្ឆាន ដែលលោកសង្គ្រោះថាជាទានបានបុណ្យនោះ តើត្រូវឲ្យដោយលក្ខណៈបែបណា ?*

ចម្លើយ៖ ត្រូវឲ្យដោយលក្ខណៈបែបនេះគឺ អ្នកឲ្យទានដល់សត្វតិរច្ឆានមានឆ្កែ ឆ្មា ជាដើមត្រូវប្រកបដោយមេត្តាគឺតាំងចិត្តអនុគ្រោះដោយពិតៗ មិនសម្លឹងយកគុណបំណាច់ ឬ ឧបការៈអ្វីពីសត្វនោះៗវិញទេ ការឲ្យទានដូច្នេះទើបលោកសង្គ្រោះថាជាទានបានបុណ្យពិតប្រាកដ ។

*៥៤.សំណួរ៖ អ្នកឲ្យទានដល់បុគ្គលដទៃ គឺឲ្យដោយសេចក្ដីខ្លាចគេក្ដី ឲ្យដោយតម្រេកស្រឡាញ់គ្នាក្ដី ឲ្យដោយការសូកប៉ាន់ក្ដី យ៉ាងនេះជាដើមនឹងចាត់ថាជាទានបានបុណ្យដែរឬទេ ? ព្រោះអ្វី ?*

ចម្លើយ៖ ការឲ្យទានយ៉ាងនេះ នឹងចាត់ថាជាទានបានបុណ្យផងពុំបាន ព្រោះការឲ្យទានដូច្នោះជាទានប្រកបដោយទោស មិនមែនជាលក្ខណៈនៃកុសលចិត្តដែលនាំឲ្យកើតទៅជាបុណ្យឡើយ ។

*៥៥.សំណួរ៖ ទានដែលគេឲ្យរលីបរលោប បន្តិចបន្តួចត្រឹមតែមួយពំនូត ឬត្រឹមតែកន្លះពំនូតប៉ុណ្ណោះ ទាននោះលោកសង្គ្រោះថាជាទានបានដែរឬទេ ?*

ចម្លើយ៖ ទាននោះលោកមិនសង្គ្រោះថាជាទានទេ ព្រោះទាននោះរលីប-រលោបមិនអាចឲ្យសម្រេចផលតាមបំណងរបស់អ្នកទទួលបាន គឺអ្នកទទួលមិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅល្មមឆ្អែតគ្រប់គ្រាន់ដោយសារទាននោះបានឡើយ ។

*៥៦.សំណួរៈ បុគ្គលអ្នកឲ្យទាន តើតាំងចិត្តបែបណា ចាត់ជាបាដិបុគ្គលិកទាន ? បែបណាចាត់ជាសង្ឃគតទាន ? ចូរអធិប្បាយមកមើល៍ !*

ចម្លើយៈ បុគ្គលអ្នកឲ្យទាន គឺឲ្យដោយតាំងចិត្តចំពោះបុគ្គលថាលោកនេះជាភិក្ខុ លោកនេះជាសាមណេរ លោកនេះល្ងង់ លោកនេះចេះដូច្នេះជាដើម ទាននោះហៅថា បាដិបុគ្គលិកទាន បើឲ្យដោយតាំងចិត្តចំពោះសង្ឃតែម្យ៉ាងទានរបស់បុគ្គលនោះឈ្មោះថាសង្ឃគតទាន ឬសង្ឃគតាទក្ខិណាទាន ដូចទាយកណានីមួយគិតថា អាត្មាអញនឹងឲ្យសង្ឃគតាទក្ខិណាទាន ហើយក៏ចាត់ចែងទេយ្យធម៌បម្រុងទុកជាស្រេច ហើយដើរទៅកាន់វត្តនិមន្តលោកដោយពាក្យថា បពិត្រព្រះករុណាដ៏ចម្រើន សូមលោកម្ចាស់ចាត់ព្រះថេរៈមួយអង្គ ចំពោះអំពីសង្ឃឲ្យដល់ខ្ញុំព្រះករុណា, លោកក៏ចាត់សាមណេរអំពីសង្ឃបញ្ជូនទៅឲ្យ ទាយកនោះ ក្រឡេកឃើញក៏ដល់នូវសេចក្តីរាយមាយចិត្តថា ឯងបានទៅនិមន្តព្រះថេរៈមួយអង្គចំពោះអំពីសង្ឃ ឥឡូវត្រឡប់ជាបានសាមណេរទៅវិញដូច្នេះក្តី ពុំនោះសោត ទុកជាបានព្រះមហាថេរហើយមានសេចក្តីសោមនស្សត្រេកអរកើតឡើងថា អឺត! អញបានព្រះមហាថេរអង្គនេះដូច្នេះក្តី ទានរបស់ទាយកនោះ មិនហៅថាសង្ឃគតទានទេ ទាននោះត្រឡប់ទៅជា បាដិបុគ្គលិកទានទៅវិញ ។

មួយវិញទៀត លុះតែទាយកណាទៅនិមន្តលោក សូម្បីបានអង្គណានីមួយទោះជាសាមណេរក្តី ភិក្ខុក្តី ភិក្ខុចាស់ក្តី ភិក្ខុក្មេងក្តី ភិក្ខុល្ងង់ក្តី ភិក្ខុចេះក្តី អំពីសង្ឃមកហើយមិនមានសេចក្តីសន្ទិះសង្ស័យ សម្គាល់ថាលោកនេះលោកនោះ ហើយធ្វើសេចក្តីគោរពចំពោះសង្ឃតែម្យ៉ាង ដោយគិតថាអាត្មាអញនឹងឲ្យទានដល់ភិក្ខុសង្ឃដូច្នេះ ទានរបស់ទាយកនោះទើបឈ្មោះថាជាសង្ឃគតទាន ឬ សង្ឃគតាទក្ខិណាទាន ដោយពិត ។

*៥៧.សំណួរៈ ទាយកឲ្យទានដល់សមណៈជាបុថុជ្ជន ដែលខ្លួននិមន្តទទួលយកចំពោះអំពីសង្ឃ និងការឲ្យទានដល់សមណៈជាសោតាបន្នបុគ្គល ដែលជាបាដិបុគ្គលិក ដែលខ្លួននិមន្តចំពោះរូបមក ទាំងពីរនេះណាមានផលច្រើនជាង ? ព្រោះហេតុអ្វី ?*

ចម្លើយៈ ឲ្យទានដល់សមណៈជាបុថុជ្ជន ដែលបាននិមន្តយកចំពោះអំពីសង្ឃមកនោះឯង មានផលច្រើនជាងឲ្យទានដល់សមណៈ ជាសោតាបន្ន ដែលជាបាដិបុគ្គលិកដែលខ្លួននិមន្តចំពោះរូបបុគ្គលមក ព្រោះសមណៈជាបុថុជ្ជននោះ ទាយកបានធ្វើសេចក្តីគោរពចំពោះសង្ឃ ឯសមណៈជាសោតាបន្ននោះ ទាយកធ្វើសេចក្តីគោរពចំពោះរូបបុគ្គល ហេតុនោះទើបមានផលតិចជាងគ្នា ឯបដិគ្គាហកជាសោតាបន្នបុគ្គលក្តី សកទាគាមិបុគ្គលក្តី ជាលំដាប់ឡើងទៅ គប្បីដឹងតាមន័យនេះដូចគ្នា ។

*៥៨.សំណួរៈ តើអង្គហេតុដែលនាំឲ្យកើតជាសង្ឃទាន មានប៉ុន្មានយ៉ាង ?*

ចម្លើយៈ អង្គហេតុដែលនាំឲ្យកើតជាសង្ឃទាន មាន ២ យ៉ាងគឺៈ

១-ទៅនិមន្តបដិគ្គាហក អំពីសំណាក់ព្រះសង្ឃ

២-ពេលលោកនិមន្តមកដល់ផ្ទះ ត្រូវតាំងចិត្តគោរពចំពោះសង្ឃ

*៥៩.សំណួរៈ ទានដែលនាំឲ្យចំពោះរូបបុគ្គល ហៅថា បាដិបុគ្គលិកទាន ដែលមិនចំពោះរូបបុគ្គល ហៅថាសង្ឃគតទាន ឯសង្ឃគតទាននេះសំដៅយកលោកប៉ុន្មានអង្គ ទើបឈ្មោះថាសង្ឃក្នុងការឲ្យទាននេះ ? មានសេចក្តីខុសគ្នាពីសង្ឃសម្រាប់ធ្វើកម្មផ្សេងៗ មានឧបោសថកម្មជាដើមយ៉ាងណា ?*

ចម្លើយៈ សង្ឃសម្រាប់ធ្វើទាន និង សង្ឃសម្រាប់ធ្វើសង្ឃកម្មផ្សេងៗមានឧបោសថកម្មជាដើម មានសេចក្តីខុសគ្នាយ៉ាងនេះគឺៈ

- សង្ឃសម្រាប់ធ្វើទាន មិនមានកំណត់ចំនួនថាប៉ុណ្ណេះប៉ុណ្ណោះអង្គទេ ដូចទាយកត្រូវការធ្វើទានហើយទៅនិមន្តអំពីគណៈសង្ឃមួយអង្គក្តី ពីរអង្គក្តី ឬច្រើនអង្គក្តី ហើយគណៈសង្ឃក៏បានចាត់ភិក្ខុឬសាមណេរតាមចំនួនដែលគេនិមន្ត, ទាយកនោះក៏បានទទួលហើយធ្វើសេចក្តីគោរពចំពោះសង្ឃតែម្យ៉ាងមិនបានតាំងចិត្តសម្គាល់ថាលោកនេះ លោកនោះទេ ហើយឲ្យតាំងចិត្តថាអាត្មាអញឲ្យទានដល់សង្ឃទាននេះចាត់ជាសង្ឃទានឬសង្ឃគតទាន ឈ្មោះថាទាយកបានឲ្យដល់សង្ឃពេញទី ។

- ឯសង្ឃសម្រាប់ធ្វើកម្ម មានឧបោសថកម្មជាដើម លុះត្រាតែគ្រប់ចំនួនអង្គ ទើបហៅថាសង្ឃ អាចធ្វើកម្មនោះៗបាន ដូចឧបោសថកម្ម មានកំណត់ចំនួនភិក្ខុយ៉ាងតិចត្រឹម ៤ អង្គ កឋិនកម្មមានកំណត់ចំនួនយ៉ាងតិចត្រឹម ៥ អង្គ បើតិចជាងនេះមិនហៅថាសង្ឃឡើយ ។

ហេតុនេះសង្ឃសម្រាប់ធ្វើទាន និង សង្ឃសម្រាប់ធ្វើកម្មផ្សេងៗ មានឧបោសថកម្មជាដើម មានសេចក្តីខុសគ្នាយ៉ាងនេះឯង ។

***៦០.សំណួរ៖ ទាយកឲ្យទានដល់បដិគ្គាហក ថ្នាក់ដាន់ទាប និង ថ្នាក់ដាន់ខ្ពស់ដែលមិនមានគុណវិសេស និងមានគុណវិសេសលើសជាងគ្នានោះ តើអំណោយនៃអានិសង្ស មានកម្រិតផ្សេងគ្នាយ៉ាងណាខ្លះ ?***

ចម្លើយ៖ អំណោយនៃអានិសង្សមានកម្រិតផ្សេងគ្នាយ៉ាងនេះគឺៈ

- ឲ្យទានដល់សត្វតិរច្ឆានបានអានិសង្ស[១៧] មួយរយ អត្តភាព ឬ ១០០ ជាតិ
- ឲ្យទានដល់បុគ្គលបុថុជ្ជនទ្រុស្តសីល បានអានិសង្សមួយពាន់អត្តភាព

---

១៧ *អាយុ ១,ពណ៌សម្បុរកាយ ១,សុខ ១,កម្លាំង ១,ប្រាជ្ញា ១* ទាំង ៥ នេះហៅថា អានិសង្ស ។

- ឲ្យទានដល់បុគ្គលបុថុជ្ជនមានសីលបរិសុទ្ធ បានអានិសង្សមួយសែនអត្តភាព ឬ ១០០.០០០ ជាតិ ។

- ឲ្យទានដល់បុគ្គល(តាបស)ខាងក្រៅព្រះពុទ្ធសាសនាដែលមានសេចក្តីនឿយណាយក្នុងកាម បានអានិសង្សមួយសែនកោដិអត្តភាព ។

- ឲ្យទានដល់បុគ្គលដែលប្រព្រឹត្ត ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល[១៨]បានអានិសង្សរាប់ពុំបានប្រមាណពុំអស់ឡើយ ។

- ចំណែកខាងអានិសង្សនៃទាន ដែលបុគ្គលបានឲ្យដល់សោតាបន្នបុគ្គលក្តី បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលក្តី ព្រះសកទាគាមិបុគ្គលក្តី បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលក្តី ព្រះអនាគាមិបុគ្គលក្តី បុគ្គលដែលបានប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផលក្តី ព្រះអរហន្តជាសាវ័ករបស់ព្រះតថាគតក្តី ព្រះបច្ចេកពុទ្ធក្តី ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធក្តី មិនបាច់និយាយឡើយ គឺមានអានិសង្សច្រើនលើសប្រមាណនឹងរាប់កំណត់ចំនួនថាប៉ុណ្ណេះ ប៉ុណ្ណោះពុំបានឡើយ (រាប់ចំនួនមិនអស់ គឺអានិសង្សច្រើនជាអនេក) ។

***៦១.សំណួរៈ ហេតុដែលនាំឲ្យធ្វើទាន មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?***

ចម្លើយៈ ហេតុដែលនាំឲ្យធ្វើទាន មាន ៨ យ៉ាងគឺៈ

១-ឲ្យទានដោយ សេចក្តីស្រឡាញ់ពេញចិត្ត

២-ឲ្យទានដោយ សេចក្តីខឹងក្រោធ

---

១៨ សូម្បីឧបាសកដល់ត្រឹមត្រៃសរណគមន៍៣ក្តី កាន់សីល៥ក្តី សីល១០ក្តី សាមណេរឬភិក្ខុទើបនឹងបួសបានមួយថ្ងៃក្តី ភិក្ខុមានវត្តប្រតិបត្តិដែលបួសយូរហើយក្តី ភិក្ខុទ្រទ្រង់វិបស្សនាក្តីទាំងអស់នេះ ឈ្មោះថាប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវ សោតាបត្តិផល ។

៣-ឲ្យទានដោយ សេចក្ដីវង្វេង

៤-ឲ្យទានដោយ សេចក្ដីភ័យខ្លាច

៥-ឲ្យទានដោយ គិតថាត្រកូលរបស់ខ្លួនធ្លាប់តែឲ្យទានមក

៦-ឲ្យទានដោយ តាំងចិត្តថានឹងបានទៅកើតក្នុងសុគតិ

៧-ឲ្យទានដោយ គិតថាអាត្មាអញកំពុងឲ្យទាន នឹងកើតចិត្តជ្រះថ្លា

៨-ឲ្យទានដើម្បីជាគ្រឿងប្រដាប់ ឬ គ្រឿងបរិក្ខារនៃចិត្ត ។

*៦២.សំណួរៈ បុគ្គលអ្នកឲ្យទាន ឈ្មោះថាបានឲ្យនូវអ្វី ដល់បុគ្គលដទៃ ? មួយទៀត អ្នកឲ្យទានឈ្មោះថាជាអ្នកចងមិត្តទុកយ៉ាងដូចម្ដេច ?*

ចម្លើយៈ បុគ្គលអ្នកឲ្យទានឈ្មោះថាបានឲ្យនូវ អាយុ, ពណ៌សម្បុរកាយ, សេចក្ដីសុខ,កម្លាំង,និងសេចក្ដីអង់អាចដល់បុគ្គលដទៃ, មួយទៀត អ្នកឲ្យទាននោះឈ្មោះថាជាអ្នកចងមិត្តទុក ឬ ប្រមូលកម្លាំងទុកដោយប្រពៃ ព្រោះថាមនុស្សក្នុងលោករមែងមានកិច្ចរវល់ជាធម្មតា កាលបើកិច្ចការដែលត្រូវធ្វើកើតឡើងហើយ បុគ្គលដែលមិនមានមិត្តសម្លាញ់ រមែងបានសេចក្ដីលំបាកដោយកិច្ចការនោះៗ ផ្ទាល់ខ្លួនឯង តែកាលបើមានមិត្តសម្លាញ់គ្នីគ្នាច្រើនត្រឹមណា ឈ្មោះថាជាអ្នកមានកម្លាំងរឹងមាំច្រើនត្រឹមណោះដែរ ។

ម្យ៉ាងទៀត ទាននេះចាត់ទុកជាមិត្តសម្លាញ់ ជាកម្លាំងដ៏ប្រសើរ ជាបច្ច័យជួយជូនដំណើរឲ្យបានទទួលផល គឺ សេចក្ដីសុខ សេចក្ដីចម្រើនដ៏ធំទូលាយតាំងអំពីលោកនេះ រហូតដល់លោកខាងមុខ ប្រៀបដូចរាងកាយទាំងមូល ត្រូវមានអវយវៈ គឺដៃជើងជាមិត្តសម្លាញ់ ឬ ជាកម្លាំងសម្រាប់ជួយធុរៈបានដោយស្រួល,យ៉ាងណាមិញ អ្នកមានសទ្ធា ត្រេកអរក្នុងការបរិច្ចាគទាន ក៏រមែងបាននូវទាននោះឯងជាមិត្តសម្លាញ់របស់ខ្លួនយ៉ាងនោះដែរ ។

*៦៣.សំណួរ៖ បុគ្គលមានទ្រព្យសម្បត្តិ ល្មមនឹងលះធ្វើទៅជាទានបានខ្លះដែរ ទាំងសទ្ធាក៏មានខ្លះដែរ តែមកពីមានធម៌អ្វីជាជំទាស់ ឬជាគ្រឿងស្ទាក់ដំណើរចិត្តមិនឲ្យចំណាយទ្រព្យធ្វើទៅជាទានកើត ? ចូរអធិប្បាយ*

ចម្លើយ៖ មកពីមានធម៌ មច្ឆរិយៈ សេចក្ដីកំណាញ់ កើតឡើងជាទំនាស់ ឬរារាំងស្ទាក់ដំណើរឃាត់ចិត្តមិនឲ្យលះបង់ទ្រព្យធ្វើទៅជាទានកើត តួយ៉ាងដូចបុគ្គលអ្នកធ្វើស្រែ ឬ ធ្វើជំនួញជាដើម វេលាកំពុងធ្វើមានគំនិតគិតទុកថារបរស្រែ ឬ ជំនួញដែលអាត្មាអញធ្វើនេះ កាលណាផលប្រយោជន៍បានសម្រេចហើយស្រាប់តែមានមច្ឆរិយចិត្ត គឺ ចិត្តកំណាញ់កើតឡើងរារាំងគិតទុកជាមុនថា ចុះបើអាត្មាអញចំណាយទ្រព្យនោះៗ ធ្វើជាទានអស់ទៅ ខ្លួនអញក្ដី ប្រពន្ធកូនរបស់អញក្ដី នឹងបានអ្វីចិញ្ចឹមជីវិតនឹងបានអ្វីប្រើប្រាស់ក្នុងគ្រួសារ នឹងបានអ្វីសន្សំទុកសម្រាប់ការពារទៅមុខ កាលបើសេចក្ដីកំណាញ់ដ៏មានកម្លាំងកើតឡើងគ្របសង្កត់ ចាកចិត្តមិនឲ្យងើបក្បាលរួចដរាបណាបុគ្គលនោះឯងឈ្មោះថា មិនអាចលះបង់ទ្រព្យធ្វើទៅជាទានបានដរាបនោះ ព្រោះហេតុនោះ មច្ឆរិយៈសេចក្ដីកំណាញ់នេះជាមន្ទិលរារាំង ស្ទាក់ដំណើរបុគ្គលមិនឲ្យធ្វើទានកើតដូច្នេះឯង ។

*៦៤.សំណួរ៖ បុគ្គលឲ្យទានអ្វី ឈ្មោះថាបានបុណ្យទាំងថ្ងៃ ទាំងយប់ គ្រប់វេលា ? ព្រោះហេតុអ្វី ?*

ចម្លើយ៖ បុគ្គលណា ដាំសួនឈើផ្កាក្ដី ដាំសួនឈើដើមក្ដី សាងស្ពានក្ដី ដងទឹកដាក់ពាងតម្កល់ទុកទៀបផ្លូវក្ដី ជីកស្រះ ឬ ជីកអណ្ដូងក្ដី ធ្វើទីនៅស្នាក់អាស្រ័យមានសាលា ជាដើមក្ដី ឲ្យជាទានដល់បុគ្គលដទៃ បុណ្យរមែងចម្រើនក្រៃលែងដល់បុគ្គលនោះទាំងថ្ងៃ ទាំងយប់ គ្រប់វេលា ព្រោះរបស់

ទាំងនោះជាសាធារណៈទូទៅដល់ជនទាំងពួងដែលគេត្រូវពឹងពាក់អាស្រ័យ មិនមានពេលកំណត់ថាថ្ងៃ ឬ យប់ឡើយ ។

*៦៥.សំណួរ៖ បុគ្គលឲ្យទានអ្វី ឈ្មោះថាឲ្យកម្លាំង ?*

ចម្លើយ៖ ឲ្យទានគ្រឿងបរិភោគផ្សេងៗ មានបាយ ទឹក នំ ចំណី ជាដើម ឈ្មោះថាឲ្យនូវកម្លាំង ។

*៦៦.សំណួរ៖ បុគ្គលឲ្យទានអ្វី ឈ្មោះថាឲ្យពណ៌សម្បុរកាយ ?*

ចម្លើយ៖ ឲ្យទានគ្រឿងអលង្ការផ្សេងៗ មានសំពត់សម្រាប់ស្លៀកដណ្តប់ជាដើម ឈ្មោះថាឲ្យពណ៌សម្បុរកាយ ។

*៦៧.សំណួរ៖ បុគ្គលឲ្យទានអ្វី ឈ្មោះថាឲ្យសេចក្តីសុខ ?*

ចម្លើយ៖ ឲ្យទានយានជំនិះ មានរថយន្ត ស្បែកជើង និង ឆ័ត្រ ជាដើម ឈ្មោះថាឲ្យសេចក្តីសុខ ។

*៦៨.សំណួរ៖ បុគ្គលឲ្យទានអ្វី ឈ្មោះថាឲ្យចក្ខុ (ភ្នែក) ?*

ចម្លើយ៖ ឲ្យទានប្រទីបគ្រឿងបំភ្លឺ មានអំពូលភ្លើង សាំង ឬ ប្រេងម៉ាស៊ីន ម៉ាស៊ីនភ្លើង ចង្កៀងគោម ជាដើម ឈ្មោះថាឲ្យចក្ខុ ។

*៦៩.សំណួរ៖ បុគ្គលឲ្យទានអ្វី ឈ្មោះថាឲ្យវត្ថុគ្រប់យ៉ាង ?*

ចម្លើយ៖ ឲ្យទានទីលំនៅអាស្រ័យ មានកុដិ សាលា រោងជាដើម ឈ្មោះថាឲ្យវត្ថុគ្រប់យ៉ាង ។

*៧០.សំណួរ៖ បុគ្គលឲ្យទានអ្វី ឈ្មោះថាឲ្យនូវព្រះនិព្វាន ?*

ចម្លើយ៖ អ្នកឲ្យទានធម៌ គឺប្រៀនប្រដៅធម៌ បង្ហាត់បង្ហាញធម៌ សម្តែងធម៌ឲ្យគេស្តាប់ ឈ្មោះថាឲ្យនូវព្រះនិព្វាន ។

*៧១.សំណួរ៖ មានទានមួយហៅថា អភ័យទាន អភ័យទាននោះ ប្រែដូចម្តេច ? បានដល់ការប្រព្រឹត្តយ៉ាងណាខ្លះ ?*

ចម្លើយ៖ ប្រែថាការឲ្យអភ័យដល់អ្នកដទៃ ឬ ធ្វើអ្នកដទៃមិនឲ្យមានភ័យ មិនឲ្យមានសេចក្ដីខ្លាច បានដល់កិរិយាប្រព្រឹត្តកាន់សីល ៥ គឺ វៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យករបស់អ្នកដទៃដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងផ្លូវកាម វៀរចាកការនិយាយកុហក វៀរចាកការផឹកគ្រឿងស្រវឹង គឺសុរានិងមេរ័យ ហៅថាអភ័យទាន ។

***៧២.សំណួរ៖ បើគ្រាន់តែការប្រព្រឹត្តកាន់សីល៥ផ្ទាល់ខ្លួនប៉ុណ្ណោះទេ ម៉េចក៏ហៅថាអភ័យទានដែរ ? បណ្ដាលទានទាំង ពីរ គឺ អាមិសទាន និងធម្មទាន អភ័យទាននេះ សង្គ្រោះចូលក្នុងទានណា ? ចូរអធិប្បាយ***

ចម្លើយ៖ ការប្រព្រឹត្តកាន់សីល៥ បានជាហៅថាអភ័យទាន ព្រោះថាសត្វដែលកើតមកក្នុងលោកសន្និវាសនេះមិនថាសត្វប្រភេទណាឡើយ សុទ្ធតែមានសេចក្ដីភ័យខ្លាចវិនាសជីវិត ហើយចង់រស់នៅជាធម្មតា មានសេចក្ដីភ័យខ្លាចវិនាសទ្រព្យសម្បត្តិ ហើយហួងហែងរក្សាទុកជាធម្មតា,មានសេចក្ដីភ័យខ្លាចគេកុហកបោកប្រាស់ បញ្ឆោតឲ្យខូចប្រយោជន៍របស់ខ្លួនជាធម្មតា, មានសេចក្ដីភ័យខ្លាចគេប្រមាថមើលងាយដល់ខ្លួន និង គ្រួសាររបស់ខ្លួនជាធម្មតា បុគ្គលរក្សាសីល ៥ បានវៀរចាកនូវការផ្ដាច់ផ្ដិលជីវិតសត្វ ឲ្យស្លាប់ ឈ្មោះថាបានឲ្យជីវិតដល់សត្វទាំងពួង, វៀរចាកការលួចទ្រព្យសម្បត្តិរបស់ជនទាំងពួង ឈ្មោះថាបានឲ្យសេចក្ដីសុខដល់អ្នកដទៃ, វៀរចាកការរំលោភដោយផ្លូវកាមចំពោះប្រពន្ធកូនរបស់ជនទាំងពួង ឈ្មោះថាបានឲ្យ សេចក្ដីសុខដល់គេ វៀរចាកការនិយាយកុហក បញ្ឆោតបោកប្រាស់ជនទាំងពួង ឲ្យគេខូច ប្រយោជន៍ដោយសារសម្ដីខ្លួន ឈ្មោះថាបានឲ្យសេចក្ដីសុខដល់គេ, វៀរចាកការផឹកទឹកស្រវឹង គឺ សុរា និង មេរ័យ ដែលជាហេតុឲ្យមានសេចក្ដីកោងកាច ប្រមាថមើលងាយដល់ជនទាំងពួង ឈ្មោះថាបានឲ្យសេចក្ដីសុខ

ដល់គេ យ៉ាងនេះឯងហៅថា អភ័យទាន អភ័យទាននេះលោកសង្គ្រោះចូលក្នុងធម្មទានដែរ ។

***៧៣.សំណួរ៖ ទក្ខិណាទាន ដែលអាចឲ្យសម្រេចផលដល់ ប្រេតទាំងឡាយត្រូវប្រកបដោយអង្គ ប៉ុន្មាន ? អ្វីខ្លះ ?***

ចម្លើយ៖ ត្រូវប្រកបដោយអង្គ ៣ យ៉ាងគឺៈ

១-**អត្តនោ អនុមោទនេន** ដោយសេចក្ដីអនុមោទនារបស់ខ្លួនគឺពួកប្រេត (ពួកអ្នកដែលធ្វើមរណកាល ទៅកាន់លោកខាងមុខ) បានមកអនុមោទនារីករាយទទួលយកក្នុងខណៈដែលគេឧទ្ទិសដល់ខ្លួន (ប្រេត) ។

២-**ទាយកានំ ឧទ្ទិសេន** ដោយសេចក្ដីឧទ្ទិសរបស់ទាយកទាំងឡាយគឺទាយកអ្នកឲ្យទាន ក្នុងវេលាធ្វើទាន ប្រារព្ធនូវបុគ្គលណាក៏ឧទ្ទិសកុសលជូនដល់បុគ្គលនោះ ឬ គេធ្វើឧទ្ទិសចំពោះញាតិការទាំង ៧ សន្តានក្ដី ញាតិក្នុងសង្សារវដ្តក្ដី ។

៣-**ទក្ខិណេយ្យសម្បទាយ** ដោយការដល់ព្រមគឺទក្ខិណេយ្យបុគ្គលគឺ លោកជាបដិគ្គាហក អ្នកទទួលទាន (អ្នកមានសីល) មាននៅជាប្រធានក្នុងទីចំពោះមុខទាយក ។

***៧៤.សំណួរ៖ អ្នកដែលឲ្យទានហើយ ឧទ្ទិសកុសលជូនទៅបេតជន មានមាតាបិតា ជាដើម ដែលធ្វើមរណៈកាលទៅកាន់លោកខាងមុខហើយនោះសុទ្ធតែបានដល់ទាំងអស់ ឬ មិនបានដល់ខ្លះដែរ ? ប្រសិនបើមិនបានដល់ជននោះទេ តើកុសលដែលអ្នកឧទ្ទិសជូនទៅនោះ នឹងទៅជា អ្វីវិញ ?***

ចម្លើយ៖ មិនមែនបានទាំងអស់ទេ បានដល់ខ្លះ មិនបានដល់ខ្លះ, បើមិនបានដល់ទេ កុសលនោះនឹងត្រូវបានមកម្ចាស់ទានវិញ, សូមអាននិទាន....!

ក្នុងគម្ពីរអង្គុត្តរនិកាយ ទសកនិបាតមកឆ្លើយបញ្ជាក់ក្នុងបញ្ហានេះថា មានព្រាហ្មណ៍ម្នាក់ឈ្មោះ **ជាណុស្សោណិ** បានចូលទៅក្រាបថ្វាយបង្គំទូលសួរព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គជាព្រាហ្មណ៍ បានឲ្យនូវទាន ទាំងធ្វើនូវជំនឿថា " *ទាននេះរមែងសម្រេចផលដល់ញាតិ និងសាលោហិតដែលស្លាប់ហើយទៅកាន់បរលោក ចំណែកខាងពួកញាតិ និងសាលោហិតក៏រមែងបានទទួលនូវទាននេះ* " បពិត្រព្រះគោតមដ៏ចម្រើន ទាននេះបានសម្រេចដល់ពួកញាតិ និង សាលោហិតដែលស្លាប់ហើយទៅកាន់បរលោកដែរ ឬ ទេ ? ឯពួកញាតិ និង សាលោហិតនោះបានទទួលនូវផលទាននោះដែរ ឬ ទេ ?

*ព្រះមានព្រះភាគទ្រង់ត្រាស់ថា៖* ម្នាលព្រាហ្មណ៍ ទាននេះបានសម្រេចក្នុងទីដែលគួរ និង មិនបានសម្រេចក្នុងទីដែលមិនគួរ ។

*ព្រាហ្មណ៍សួរថា៖* បពិត្រព្រះគោតមដ៏ចម្រើន ទីណាដែលគួរ ? និង ទីណាដែលមិនគួរ ?

*ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា៖* ម្នាលព្រាហ្មណ៍បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយហើយ ទៅកើតក្នុងនរក កម្មវិបាកណាជាអាហាររបស់សត្វនរក សត្វនរកនោះក៏រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយកម្មវិបាកនោះ ទានដែលគេឧទ្ទិសឲ្យទៅនោះ រមែងមិនសម្រេចដល់សត្វនរកនោះឡើយ ទីនេះឯងហៅថា**ទីមិនគួរ** ។ មួយទៀត ម្នាលព្រាហ្មណ៍បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយហើយ ទៅកើតជាសត្វតិរច្ឆាន វត្ថុមានស្មៅនិងស្លឹកឈើជាដើមឯណាជាអាហាររបស់សត្វតិរច្ឆាន សត្វតិរច្ឆាននោះរមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្ត

ទៅដោយវត្ថុមានស្មៅ និងស្លឹកឈើជាដើមនោះ។ទានដែលគេឧទ្ទិសឲ្យទៅនោះរមែងមិនសម្រេចដល់សត្វតិរច្ឆាននោះឡើយទីនេះឯងហៅថា**ទីមិនគួរ**ដែរ ។ មួយវិញទៀត ម្នាលព្រាហ្មណ៍បុគ្គលខ្លះក្នុងលោកនេះជាអ្នកមិនសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយហើយ ទៅកើតក្នុងកំណើតជាមនុស្ស វត្ថុមានបាយជាដើមឯណាជាអាហាររបស់មនុស្ស មនុស្សនោះរមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុមានបាយជាដើមនោះ ទានដែលគេឧទ្ទិសទៅឲ្យនោះ រមែងមិនសម្រេចដល់មនុស្សនោះឡើយ ទីនេះឯងក៏ហៅថា**ទីមិនគួរ**ដែរ ។ មួយវិញទៀត ម្នាលព្រាហ្មណ៍បុគ្គលខ្លះក្នុងលោកនេះជាអ្នកមិនសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយហើយ ទៅកើតក្នុងកំណើតជាទេវតា វត្ថុមានសុធាភោជនដ៏ទិព្វ ជាដើមឯណា ជាអាហាររបស់ទេវតា ទេវតានោះរមែងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយវត្ថុមានសុធា-ភោជនដ៏ទិព្វ ជាដើមនោះ ទានដែលគេឧទ្ទិសទៅឲ្យនោះ រមែងមិនសម្រេចដល់ទេវតានោះឡើយ ទីនេះឯងក៏ហៅថាទី**មិនគួរដែរ** ។ មួយវិញទៀត ម្នាលព្រាហ្មណ៍បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ ។ល។ ជាអ្នកមានទិដ្ឋិយល់ខុស បុគ្គលនោះលុះបែកធ្លាយរាងកាយហើយ ទៅកើតក្នុងកំណើតជាប្រេត វត្ថុមានទឹកមាត់ និងទឹកសំបោរជាដើមឯណាជាអាហាររបស់ប្រេត ប្រេតនោះរមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុ មានទឹកមាត់ និងទឹកសំបោរជាដើមនោះ តែបើមានញាតិនិងសាលោហិត គេឧទ្ទិសផលនៃទានណាអំពីលោកនេះទៅដើម្បីប្រេតនោះ ប្រេតនោះឯងរមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយផលទាននោះ ទានដែលគេឧទ្ទិសឲ្យទៅនោះរមែងសម្រេចផលដល់ប្រេតនោះបាន ទីនេះឯងហៅថា**ទីគួរ** ។

*ព្រាហ្មណ៍ទូលសួរថា៖* បពិត្រព្រះគោត្តមដ៏ចម្រើន ប្រសិនបើញាតិនិងសាលោហិតដែលស្លាប់ហើយគ្មានទៅកើតជាប្រេតទេ តើបានអ្នកណាទទួលនូវទាននោះ ?
*ព្រះពុទ្ធត្រាស់ថា៖* ម្នាលព្រាហ្មណ៍ ពួកញាតិនិងសាលោហិតដទៃទៀតរបស់បុគ្គលនោះ ដែលស្លាប់ហើយទៅកើតជាប្រេតទទួលនូវទាននោះឯង។
*ព្រាហ្មណ៍ទូលសួរទៀតថា៖* បពិត្រព្រះគោតមដ៏ចម្រើន ចុះប្រសិនបើញាតិនិងសាលោហិតដទៃទៀតរបស់បុគ្គលនោះ ដែលស្លាប់ហើយក៏គ្មានទៅកើតជាប្រេតដែរ តើបានអ្នកណាទទួលនូវទាននោះ ?
*ព្រះសម្ពុទ្ធត្រាស់ថា៖* ម្នាលព្រាហ្មណ៍ ទីណាដែលសូន្យស្ងាត់អស់កាលជាអង្វែង គ្មានញាតិនិងសាលោហិតណាមួយដែលស្លាប់ ហើយទៅកើតជាប្រេតទេ ទីនោះឯងហៅថាទីមិនគួរ មិនមែនជាឱកាស ម្នាលព្រាហ្មណ៍ចំណែកខាងទាយកអ្នកឲ្យទានហើយ ឧទ្ទិសកុសលជូនដល់បុគ្គលណាទោះបានសម្រេចដល់បុគ្គលនោះក្តី មិនបានសម្រេចដល់បុគ្គលនោះក្តី ឯទាយកក៏មិនមែនជាឥតផលឡើយ គឺថាផលនៃទាននោះ ត្រូវត្រឡប់បានមកទាយកជាម្ចាស់ទាននោះវិញជាក់ជាពុំខានឡើយ ។

***៧៥. សំណួរ៖ ទាយក ទាយិកា វេលាធ្វើទានម្តងៗខ្លះសូត្រវេរជាបាលី,ខ្លះសូត្រវេរតែពាក្យសម្រាយ ខ្លះសូត្រវេរទាំងបាលីទាំងពាក្យសម្រាយ ប្រើច្រើនបែបដូច្នេះ តើសេចក្តីសំខាន់នៅត្រង់សូត្រវេរបែបណា ?***

ចម្លើយ៖ សេចក្តីសំខាន់នោះ នៅត្រង់យល់ឬដឹងសេចក្តី ទោះបីសូត្រវេរតែជាភាសាបាលីសុទ្ធក្តី ជាភាសាសម្រាយសុទ្ធក្តី ឲ្យតែស្តាប់សេចក្តីបានហើយត្រូវតាមលក្ខណៈនៃការវេរហើយក៏ឈ្មោះថាបានការដូចគ្នាទាំងអស់.

*៧៦.សំណួរ៖ កិច្ចដែលលើកប្រគេនតែម្តង និង កិច្ចដែលសូត្រវេរផ្សេងគ្នា ឬដូចគ្នា ? ចូរអធិប្បាយមកមើល៍*

ចម្លើយ៖ ផ្សេងគ្នាដោយវោហារ និងរបៀបដែលធ្វើ ដូចគ្នាដោយសេចក្តីរួមមកគឺជាការប្រគល់ឲ្យ ឬ លើកឲ្យហ្នឹងឯង ប៉ុន្តែពាក្យថាវេរនេះបវេណីម្យ៉ាងរបស់ពុទ្ធបរិស័ទដែលធ្លាប់ធ្វើជាលំដាប់មក គឺរៀបគ្រឿងសក្ការៈដាក់តម្កល់ទុកក្នុងទីចំពោះមុខនៃភិក្ខុសង្ឃ ហើយម្នាក់សូត្រវេរបាលី ឬ ជាសម្រាយឲ្យអ្នកឯទៀតថាតាម ឬ ក៏សូត្រថាព្រមគ្នាទាំងអស់ក៏បាន មានសេចក្តីផ្សេងគ្នាខ្លះ អំពីពាក្យប្រគេនដូច្នេះឯង ។

*៧៧.សំណួរ៖ បើមិនបានសូត្រវេរ លើកប្រគេនផ្ទាល់តែម្តង និង សូត្រវេរហើយទើបលើកប្រគេនជាខាងក្រោយ តើកិច្ចទាំងពីរនេះ មួយណាមានផលច្រើនជាង ឬ យ៉ាងណា ? ព្រោះអ្វី ?*

ចម្លើយ៖ កិច្ចទាំងពីរមានផលស្មើគ្នាទេ ប៉ុន្តែ កិច្ចដែលសូត្រវេរនោះមានសេចក្តីវិសេសជាង ព្រោះការសូត្រវេរជាកិច្ចសម្រាប់ធ្វើក្នុងពេលដែលមានគ្នាច្រើននាក់ ដើម្បីប្រមូល ឬ ដាស់តឿនលើកទឹកចិត្ត ឲ្យប្រមូលត្របាញ់ជាមួយ សម្តែងឆន្ទៈគឺសេចក្តីពេញចិត្តរីករាយចំពោះក្នុងការលះ ក្នុងការឧទ្ទិសឲ្យបានស្មើភាពគ្នាប៉ុណ្ណោះ ។

*៧៨.សំណួរ៖ បើនិយាយតាមផ្លូវធម៌វិញ ការដែលសូត្រវេរជាបាលី ឬ សម្រាយចំពោះមុខភិក្ខុសង្ឃ ឈ្មោះថាទាយកឲ្យដោយវាចាដាច់ស្រឡះដល់ភិក្ខុសង្ឃហើយ គួរលោកទទួលឆាន់បានឥតមានទោស ចុះហេតុអ្វីបានជាត្រូវឲ្យលើកប្រគេនថែមទៀត ? ព្រោះអ្វី ?*

ចម្លើយ៖ បានជាត្រូវឲ្យលើកប្រគេនថែមទៀតនោះ ព្រោះមានវិនយប្បញ្ញត្តិថា ភិក្ខុទទួលបិណ្ឌបាតប្បច្ច័យក្តី គិលានភេសជ្ជប្បច្ច័យក្តី លុះតែទទួល

ប្រកបដោយអង្គប្រគេនទាំង ៥យ៉ាង ទើបគួរទទួលឆាន់បានមិនមានទោស ឯចីវរប្បច្ច័យ និងសេនាសនប្បច្ច័យ បើទាយកស្ងូត្រវេរប្រគេនដោយវាចារួច ហើយ ទោះបីលើកប្រគេនថែមទៀតក្តី មិនបានលើកប្រគេនក្តី ភិក្ខុគួរទទួលប្រើប្រាស់បាន ឥតមានទោសឡើយ ព្រោះជារបស់ប្រើប្រាស់ផ្ទាល់កាយខាងក្រៅ មិនបានលេបចូលទៅក្នុងបំពង់ក ដូចជា បិណ្ឌបាតប្បច្ច័យ និងគិលានភេសជ្ជប្បច្ច័យនោះឡើយ ។

***៧៩.សំណួរ៖ បើទាយកទាយិកា មានសេចក្តីជ្រះថ្លាកើតឡើងក្នុងសន្តានចិត្ត ហើយប្រាថ្នានឹងចាត់ចែងនូវភត្តណានីមួយ តាមសេចក្តីពេញចិត្តរបស់ខ្លួន ឬវេរដល់ភិក្ខុសង្ឃ ភត្តនោះមានឈ្មោះប៉ុន្មានយ៉ាង ? អ្វីខ្លះ ?***

ចម្លើយ៖ ភត្តនោះមានឈ្មោះ ១៩ យ៉ាងគឺៈ

១-**សង្ឃភត្តំ** ភត្តដែលប្រគេនដល់សង្ឃ ។

២-**ឧទ្ទេសកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុ ១ អង្គក្តី ២ អង្គក្តី ៣ អង្គក្តី ជាដើម តាមពាក្យដែលសង្ឃចាត់ឲ្យ ។

៣-**និមន្តនភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុដែលបាននិមន្តមក ។

៤-**សលាកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុច្រើនអង្គ ដែលគេសរសេរឈ្មោះក្នុងស្លាកហើយចាប់យក ។

៥-**បក្ខិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃក្នុងថ្ងៃបក្សទាំងពីរ គឺសុក្កបក្ស ចំណែកខាងខ្នើត, កាឡបក្ស ចំណែកខាងរនោច ក្នុងមួយបក្សប្រគេនតែមួយថ្ងៃ គឺថ្ងៃណាមួយមិនមានកំណត់ ។

៦-**ឧបោសថិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃក្នុងថ្ងៃឧបោសថ។

៧-**បាដិបទិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃក្នុងថ្ងៃ១កើត-រោច

៨-**អាគន្តុកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃដែលទើបមកដល់ថ្មី

៩-**គមិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលមានដំណើរទៅកាន់ទីណាមួយ ។

១០-**គិលានភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃអ្នកមានជំងឺ ។

១១-**គិលានុបដ្ឋាកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ អ្នករក្សាជំងឺភិក្ខុ សាមណេរផងគ្នា ។

១២-**និច្ចភត្តំ** ភត្តដែលប្រគេនជានិច្ចដល់ភិក្ខុសង្ឃ ។

១៣-**កុដិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ដែលនៅក្នុងលំនៅមានកុដិជាដើម (ភត្តនេះហៅបានតាមឈ្មោះកន្លែងដែលសង្ឃនៅ) ។

១៤-**វារិកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ចាត់ជាវេន (ដូចជាវេនដាក់បិណ្ឌ ឬ វេនគេធ្វើតាមភូមិជាដើម) ។

១៥-**វិហារភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃដែលនៅក្នុងវត្តមួយៗបានឆាន់គ្រប់គ្រាន់បរិបូណ៌ទាំងអស់ ។

១៦-**ចតុក្កភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ៤ អង្គៗដែលខ្លួនបាននិមន្តអំពីគណៈសង្ឃ ដើម្បីទទួលចង្ហាន់នៅផ្ទះខ្លួនរាល់ៗ ថ្ងៃពុំដែលដាច់ ។

១៧-**អដ្ឋកភត្តំ** ភត្តដែលប្រគេនដល់ភិក្ខុសង្ឃ ៨ អង្គៗដែលខ្លួនបាននិមន្តអំពីគណៈសង្ឃ ដើម្បីទទួលចង្ហាន់នៅផ្ទះខ្លួនរាល់ៗ ថ្ងៃពុំដាច់ ។

១៨-**គុឡភត្តំ** ភត្តដែលលាយដោយស្ករអំពៅ មានបាយដំណើបបបរស្ករ នំលតជាដើម ចំពោះភិក្ខុសង្ឃក្នុងវត្តនីមួយៗ តាមសទ្ធា ។

១៩-**មតកភត្តំ** វេរនូវភត្តឧទ្ទិសចំពោះបុគ្គលដែលស្លាប់ហើយ ។

ភត្តទាំង ១៩ នេះ បើទាយកប្រាថ្នានឹងវេរភត្តណា ត្រូវលើកយកឈ្មោះភត្តនោះមកដាក់បញ្ចូលត្រង់ វង់ក្រចក (........) ភ្ជាប់ជាមួយនឹងពាក្យ (**ឥមំ**...........) ដែលមាននៅក្នុងបាលីវេរ ដូចខាងក្រោម ៖

# ច្បាលីទេរភត្ត

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (៣ចប់)
**អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស** (**ឥមំ......**) **សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម តេ គុណវន្តានយោ** (**ឥមំ.......**)**អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។ ទុតិយម្បិ..............។ តតិយម្បិ.............។**

ប្រែថា៖ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ វីចង្ហាន់បិណ្ឌបាតនៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះ ដល់លោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម ហើយយើងខ្ញុំទាំងឡាយ សូមវេរនូវ(..........នេះ) ព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតា និងបិតាជាដើមនោះ សម្គាល់នូវ(....នេះ) ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឲ្យរួចរំដោះចាកទុក្ខទាំងពួង សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយបីប្រការ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នកមានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្សដែលហួរជូនទៅជាមិនដាច់នេះហោង ។

*.......អស់វារៈ២ដងផង ។ .........អស់វារៈ៣ដងផង ។*

*សូមអនុមោទនាប្រគេន(ចង្ហាន់.....).....ដល់ព្រះសង្ឃ...។*

*៨០.សំណួរ៖ មាតាបិតា ទុកជា បដិគ្គាហក គួរទទួលទេយ្យទានរបស់កូនប្រុស កូនស្រីផង បាន ឬ ទេ ? ចូរពន្យល់ និងទាញគោលអាង !*

ចម្លើយ៖ គួរណាស់គឺគួរទទួលទេយ្យទានរបស់កូនប្រុស-ស្រីបានដោយពិត ព្រោះក្នុងសព្រហ្មកសូត្រគម្ពីរអង្គុត្តរនិកាយចតុក្កនិបាត ព្រះពុទ្ធទ្រង់សម្តែងថា មាតាបិតាជាអាហុនេយ្យបុគ្គលរបស់កូនប្រុសស្រីៗ គួរចាត់ចែងវត្ថុដ៏សមគួរ ហើយបង្អោនចូលទៅបូជា ។ បុគ្គលអ្នកមានសទ្ធាបានចាត់ចែងគ្រឿងសក្ការៈដ៏ថ្លៃថ្លាមានបាយ និងទឹកជាដើម ហើយនាំមកបង្អោនចូលទៅបូជាចំពោះបព្វជិតទាំងឡាយ ក្នុងសាសនាដោយគោរពយ៉ាងណា ឯកូនប្រុស កូនស្រី ក៏ត្រូវតែចាត់ចែងគ្រឿងសក្ការៈដ៏ផ្ចិតផ្ចង់មានបាយ និងទឹកជាដើម នាំចូលទៅជូន ឬ បូជាដល់មាតាបិតាដោយគោរព វៀរលែងតែរបស់ណាមួយដែលមាតាបិតាទទួលប្រើប្រាស់ពុំបាន ក៏យ៉ាងនោះដែរ ។

*៨១.សំណួរ៖ មាតាបិតានៅក្នុងផ្ទះជាមួយ ឬ នៅផ្ទះជិតខាងកូនប្រុសស្រីចាត់ចែងវត្ថុមានខាទនីយភោជនីយាហារ (បង្អែមនិងចម្អាប) ជាដើម មិនបានអើពើចាប់រំលែកវត្ថុនោះខ្លះយកទៅជូនមាតាបិតាសិនទេ ហើយនាំបង្ហួសទៅប្រគេនព្រះសង្ឃឯវត្តតែម្តង តើកូនប្រុសស្រីនោះឈ្មោះថា ប្រព្រឹត្តដោយប្រពៃចំពោះមាតាបិតា បាន ឬទេ ?*

ចម្លើយ៖ បើធ្វើដូច្នោះ មិនបានឈ្មោះថាប្រព្រឹត្តដោយប្រពៃទេ ព្រោះមាតាបិតា លោកទុកជាបដិគ្គាហក វិសេសមួយផ្នែកខាងក្នុងរបស់កូនៗ ពុំគួររំលងចោលឡើយ ព្រោះក្នុងមាតាបិតុបដ្ឋានសូត្រ ថាសូម្បីកូនបួសជាបព្វជិតហើយ ដើរទៅស្វែងរកបិណ្ឌបាតបានមកហើយនឹកឃើញដល់មាតាបិតាដែលកំពុងខ្សត់ខ្សោយ ក៏កូនជាបព្វជិតនោះចាប់រំលែកយកទៅជូនមាតាបិតាមុនជានិច្ច ហើយទើបបរិភោគខ្លួនឯងជាខាងក្រោយដែរ ។

# ធម្មទាន

***៨២.សំណួរ៖ ធម្មទាន ប្រែថា ការឲ្យធម៌ជាទានដល់អ្នកដទៃ ហៅថាធម្មទាន តើបានដល់ការឲ្យដូចម្តេចខ្លះ ?***

ចម្លើយ៖ បានដល់ការបង្រៀនធម៌ សម្តែងធម៌ប្រាប់អ្នកដទៃ ដូចប្រាប់ថាធម៌នេះជាកុសលធម៌ នេះជាអកុសលធម៌ ធម៌នេះប្រកបដោយទោស ធម៌នេះមិនប្រកបដោយទោសជាដើម ឬ សម្តែងប្រាប់កម្ម និង ផលរបស់កម្មឲ្យឃើញជាក់ប្រាកដក្នុងលោកនេះ និង លោកខាងមុខ ហាក់ដូចជាចង្អុលប្រាប់ដោយជាក់ច្បាស់ និង សម្តែងធម៌ញាំងជនដទៃឲ្យងាកបែរចេញអំពីអកុសលធម៌ ហើយឲ្យតម្កល់នៅក្នុងកុសលធម៌វិញ។ ម្យ៉ាងទៀត ការខំប្រឹងសរសេរចារចម្លងពុទ្ធវចនៈ គឺព្រះត្រៃបិដកព្រមទាំងអដ្ឋកថា ឬ ចំណាយទ្រព្យកសាងគម្ពីរដីកា ច្បាប់ព្រះពុទ្ធសាសនាទុកសម្រាប់ឲ្យសិក្ខាកាមកុលបុត្ររៀនសូត្រឲ្យបានចេះដឹងបានប្រព្រឹត្តកាន់តាមដើម្បីធ្វើមគ្គឲ្យកើតឡើង និង បានតវង្សព្រះពុទ្ធសាសនាឲ្យរីកចម្រើនតាំងនៅអស់កាលជាយូរអង្វែងតទៅយ៉ាងនេះជាដើម ហៅថាធម្មទាន (ឬ លោកិយធម្មទាន ក៏បាន) ។

***៨៣.សំណួរ៖ ការឲ្យទានធម៌បែបណា ដែលលោកចាត់ថាជាធម្មទានដ៏ខ្ពង់ខ្ពស់ ឬ ជាកំពូលនៃទានទាំងពួង ?***

ចម្លើយ៖ ការសម្តែងប្រាប់នូវសច្ចៈ[១៩]ទាំងបួនដល់អ្នកដទៃថា ធម៌នេះបុគ្គលគួរកំណត់ដឹង (**កងទុក្ខ**)[២០],ធម៌នេះបុគ្គលគួរលះបង់ (**តណ្ហា**)[២១], ធម៌នេះ

---

១៩ ពិតជាមានទុក្ខ, ពិតជាមានប្រភពទុក្ខ,ពិតជាមានកន្លែងរំលត់ទុក្ខ,ពិតជាមានវិធីរំលត់ទុក្ខ

២០ ទុក្ខទាំង១២កង (ឬទុក្ខមាន៤កង ជាតិទុក្ខ,ជរាទុក្ខ,ព្យាធិទុក្ខ,មរណទុក្ខ)

បុគ្គលគួរធ្វើឲ្យជាក់ច្បាស់ ( **និព្វាន** )[២២], ធម៌នេះបុគ្គលគួរចម្រើន ( **អដ្ឋង្គិកមគ្គ** )[២៣] យ៉ាងនេះជាដើម ហៅថា ធម្មទានកំពូលនៃទានទាំងពួង ។

***៨៤.សំណួរៈ ការឲ្យវត្ថុដែលមានរូប អាចចាប់កាន់ទទួលបាន ចាត់ថាជាអាមិសទានមិនមែនឬ ចុះដូចពុទ្ធវចនៈ គឺធម្មវិន័យជាច្បាប់សម្តែងប្រាប់ផ្លូវលោក និង ផ្លូវធម៌ដែលចារឹកដាក់នឹងក្រដាស ឬ ស្លឹករឹតហៅថា សៀវភៅ ឬ គម្ពីរ ជារបស់មានរូបអាចចាប់កាន់ទទួលបានដូចគ្នាដែរ និងចាត់ថាជាទានអ្វីទៅវិញ ? ព្រោះហេតុអ្វី ?***

ចម្លើយ៖ ចាត់ថាជាធម្មទានពេញទី ព្រោះហេតុថាសៀវភៅ ឬ គម្ពីរនោះគេគ្រាន់តែចារឹកធម្មវិន័យ ជារបស់មានរូបអាចចាប់កាន់ទទួលបានក៏ពិតមែន ប៉ុន្តែ គេមិនអាចបរិភោគលេបចូលទៅក្នុងបំពង់ក និងមិនអាចប្រើប្រាស់ផ្ទាល់កាយ ដូចជាបច្ច័យទាំងបួននោះបានឡើយ ហេតុនេះទើបបានលោកចាត់ជាធម្មទាន ។

***៨៥.សំណួរៈ អាមិសទាន និងធម្មទានទាំងពីរនេះទានណាមានផលានិសង្សខ្ពង់ខ្ពស់ប្រសើរជាង ? ចូរអធិប្បាយមកមើល៍ !***

ចម្លើយ៖ ធម្មទានមានអានិសង្សខ្ពង់ខ្ពស់ប្រសើរជាង ព្រោះការសម្តែងធម៌ជាសាធារណៈដល់បុគ្គលដទៃក្តី ការប្រៀនប្រដៅប្រាប់អំពីគុណទោស ខុសត្រូវ ក្នុងផ្លូវលោក ផ្លូវធម៌ ចំពោះមនុស្សម្នាក់ៗក្តី ការបង្ហាត់បង្រៀនធម៌អាចំ

---

២១ តណ្ហា ប្រែថាចំណង់, សេចក្តីប្រាថ្នាមាន ៣ កាមតណ្ហា១, ភវតណ្ហា១, វិភវតណ្ហា១

២២ និព្វានមាន២គឺ សឧបាទិសេសនិព្វាន១ និង អនុបាទិសេសនិព្វាន១

២៣ ឃើញត្រូវ,ត្រិះរិះត្រូវ,សម្តីត្រូវ,ការងារត្រូវ,ចិញ្ចឹមជីវិតត្រូវ,ព្យាយាមត្រូវ,រលឹកត្រូវ,តាំងចិត្តត្រូវ ទាំង៨នេះលោកហៅថាអដ្ឋង្គិកមគ្គ (ឬ អរិយមគ្គ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ៨)

ចំពោះពួកគណៈសាធារណៈក្តី ឈ្មោះថាប្រគល់នូវចំណេះវិជ្ជាប្រាជ្ញាស្មារតីដ៏ធំទូលាយទៅដល់បុគ្គលដទៃ ដូចយ៉ាងបុគ្គលដែលបានទទួលអំណោយសេចក្តីសុខដោយភោគសម្ប័ទ ឬ ដោយឋានន្តរ គឺតំណែងយសស័ក្តិណាមួយ សុទ្ធតែបានមកពីការរៀនសូត្រស្តាប់ទាំងអស់ ឬ ថាមានការស្តាប់នេះឯងជាមូលហេតុ ។ ការសិក្សា ការត្រង់ត្រាប់ស្តាប់យកឧបាយ នេះរាប់ថាជាមេគំនិត ឬជាដើមពូជនៃប្រយោជន៍សេចក្តីល្អគ្រប់យ៉ាង បុគ្គលដែលបានសម្រេចមគ្គផលនិព្វានជាគុណវិសេសដ៏ខ្ពស់បំផុត ព្រោះអាស្រ័យការស្តាប់នេះជាបច្ច័យ ។ ចំណែកខាងបុគ្គលអ្នកប្រៀនប្រដៅធម៌ឈ្មោះថា ឲ្យទានព្រះនិព្វាន សមដូចពុទ្ធភាសិតថាៈ " **អមតន្ទទោ ច សោ ហោតិ យោ ធម្មមនុសាសតិ** " *បុគ្គលណាប្រៀនប្រដៅធម៌ បុគ្គលនោះឈ្មោះថាឲ្យព្រះនិព្វានដល់ជនដទៃ ។*

- ធម្មទាន ជាទានមានផលានិសង្សដ៏ខ្ពង់ខ្ពស់ ឈ្នះទានទាំងអស់ដោយហេតុថាជាប្រធាន ឬ ថាជាជីវិតនៃអាមិសទាន ។

- ធម្មទាន ជាអាយុនៃពុទ្ធសាសនា អាចធ្វើពុទ្ធសាសនាឲ្យមានពន្លឺរស្មីរុងរឿង ឋិតថេរដរាបទៅ ។

- ប្រសិនបើបុគ្គលឲ្យចីវរ ដែលមានសាច់ល្អដូចបណ្តូលចេកចំពោះព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពដែលអង្គុយប្រជុំគ្នាត្រៀបត្រាឥតមានចន្លោះក្នុងផ្ទៃចក្រវាឡរហូតដល់ព្រហ្មលោក នៅក្នុងទីប្រជុំនោះមានធម្មកថិកអង្គណាមួយ ធ្វើអនុមោទនាដោយគាថា[២៤]បួនបាទ[២៥] ក៏ប្រសើរ

---

២៤ **គាថា** កម្រងវាចាដែលមានរបៀបកំណត់ ដោយខ្យល់អក្សរមាន ឆន្ទ គណៈ ឃ្លា ល្បះ។
២៥ **បាទ** ឃ្លាសង្កាត់របស់គាថា, របស់កាព្យឃ្លោង : បាទទី១, បាទទី២...។

ជាងចីវរទាននោះទៅទៀត ។ ឯចីវរទាននោះមិនបានមួយចំរៀកនៃគាថា នោះ ដែលគេច្រៀកឲ្យជា ១៦ ចំរៀក អស់វារៈ ១៦ ដង, ចំណែក បិណ្ឌបាតទានក្តី សេនាសនទានក្តី គិលានភេសជ្ជទានក្តី ក៏មានន័យដូចគ្នា នេះដែរ ព្រោះហេតុនោះ ការសម្តែងធម៌ក្តី ការស្តាប់ធម៌ក្តី ជាការប្រសើរ យ៉ាងនេះឯង ។

- ដោយហោចទៅ **ធម្មទាន** គ្រាន់តែបុគ្គលអនុមោទនាដោយគាថា បួនបាទប៉ុណ្ណោះ ក៏នៅតែប្រសើរជាងទានដែលបុគ្គលយកចង្ហាន់បិណ្ឌបាត ដ៏ឧត្តមដាក់ពេញក្នុងបាត្រ ហើយឲ្យដល់អរិយបុគ្គល មានព្រះពុទ្ធជាដើម ដូច្នេះផង, ជាងគិលានភេសជ្ជទានដែលបុគ្គលយកទឹកដោះស្រស់ និង ប្រេងជាដើម ដាក់ពេញក្នុងបាត្រហើយឲ្យដល់អរិយបុគ្គល មានព្រះពុទ្ធជា ដើមដូច្នោះផង, ជាងសេនាសនទានដែលបុគ្គលសាងវិហារ ដូចយ៉ាងមហា វិហារ ឬ យ៉ាងលោហប្រាសាទរាប់សែនមិនតែមួយ ហើយឲ្យដល់អរិយ-បុគ្គលមានព្រះពុទ្ធជាដើមដូច្នោះផង ព្រោះហេតុអ្វី ព្រោះបុគ្គលដែលចេះ លែលកធ្វើបុណ្យទានមានសភាពដូច្នោះកើត លុះតែបានស្តាប់ធម៌ពាក្យ ប្រៀនប្រដៅជាមុនហើយទើបចេះធ្វើ បើមិនបានស្តាប់ធម៌សោះទេ ក៏មិន អាចធ្វើអ្វីបានឡើយ ។

- មែនពិត សត្វទាំងឡាយបើមិនដែលបានស្តាប់ធម៌ហើយ សូម្បីតែ បបរមួយបោយក្តី បាយមួយវែកក្តី ក៏មិនអាចធ្វើទៅជាទានបានឡើយ។ ដូច្នេះហើយ ទើបធម្មទានបានឈ្មោះថា មានផលានិសង្សខ្ពង់ខ្ពស់ប្រសើរ ជាងអាមិសទានដោយហេតុនេះឯង ។

***៨៦.សំណួរ៖ ធម្មទាន ប្រែដូចម្តេច ? ធម្មទានចែកជា ប៉ុន្មានប្រភេទ ? មាន អ្វីខ្លះ ? ចូរពន្យល់ឲ្យបានងាយស្តាប់មកមើល៍***

ចម្លើយ៖ ធម្មទាន ប្រែថា ឲ្យធម៌ ដោយន័យថា ឲ្យបញ្ញា ឲ្យវិជ្ជា ដោយការសម្តែងឲ្យស្តាប់,ដោយការបង្រៀន និង ដោយការសាងតម្រា (សៀវភៅ) ។

**ធម្មទានចែកចេញជាពីរប្រភេទគឺ:**

១-**លោកិយធម្មទាន** ប្រែថា *"ឲ្យធម៌សម្រាប់លោក"* ដោយន័យថា ឲ្យបញ្ញា,ឲ្យវិជ្ជា សម្រាប់ធ្វើឲ្យបានចម្រើនក្នុងផ្លូវបច្ចុប្បន្ន និងបរលោក បានដល់វិជ្ជាពុទ្ធសាសនាថ្នាក់ទី ១[២៦] និង ទី ២[២៧] វិជ្ជាអក្សរសាស្ត្រ គណិតសាស្ត្រ ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ សេដ្ឋសាស្ត្រ ជាដើម ។

២-**លោកុត្តរធម្មទាន** ប្រែថា *"ឲ្យធម៌សម្រាប់ឆ្លងចាកលោក"* ដោយន័យថា ឲ្យបញ្ញា ឲ្យវិជ្ជា សម្រាប់វែកញែកសង្ខារធម៌, សម្រាប់រំដោះមនុស្សសត្វចេញចាកត្រៃលោក បានដល់វិជ្ជាពុទ្ធសាសនាថ្នាក់ទី ៣ ឬ ថ្នាក់ទីបំផុត ឬ បរមត្ថវិជ្ជា ។

***៨៧.សំណួរ៖ អានិសង្សនៃធម្មទាន បើពោលដោយរួបរួមមានប៉ុន្មានប្រការ? អ្វីខ្លះ? ចូររៀបរាប់ឲ្យងាយស្តាប់បានមកមើល៍***

ចម្លើយ៖ អានិសង្សនៃធម្មទាន មាន ៥ ប្រការគឺ:

១-លោកអ្នកសម្តែង កាលបើសម្តែងដោយផ្ចិតផ្ចង់ តាមអង្គនៃធម្មកថិកចំពោះព្រះសទ្ធម្ម នឹងរឹងរិតតែជាអ្នកយល់ច្បាស់ធ្លុះធ្លាយក្នុងអត្ថក្នុងធម៌ក្រៃលែងតទៅទៀត ។

---

២៦ បានដល់សម្បទាប្រយោជន៍បច្ចុប្បន្ន៤យ៉ាង( **ឧដ្ឋានសម្បទា:**ព្យាយាម១,**អារក្ខសម្បទា:** រក្សាទ្រព្យសម្បត្តិ១,**កល្យាណមិត្តតា:** សេពគប់មិត្តល្អ១,**សមជីវិតា:** ចិញ្ចឹមជីវិតសមគួរ១ )

២៧ បានដល់សម្បទាប្រយោជន៍បរលោក៤យ៉ាង( សទ្ធា, សីល, ចាគ និង បញ្ញាសម្បទា)

២-សេចក្តីរីករាយក្នុងអត្ថ ក្នុងធម៌រមែងកើតឡើងគឺធម្មទេសនានោះ ក៏ពិរោះចាប់ចិត្តខ្លួនឯង និង បុគ្គលអ្នកស្តាប់តាមលំដាប់នៃធម៌ដែលលើកឡើងសម្តែង ។

៣-សេចក្តីត្រេកអរមានកម្លាំងឆ្អែតចិត្តក្នុងអត្ថ ក្នុងធម៌នោះៗក៏កើតឡើង

៤-រូបកាយ និងនាមកាយរបស់អ្នកសម្តែង និងអ្នកស្តាប់ក៏ស្ងប់រម្ងាប់ចាកអកុសលធម៌ផ្សេងៗដរាបដល់ចិត្តសង្វេគតក់ស្លុតក្នុងសង្ខារទាំងឡាយ

៥-ចិត្តរបស់លោកដែលកំពុងសម្តែងធម៌ ក៏តាំងមាំក្នុងការស្ងប់ស្ងាត់ចាកនីវរណធម៌[២៨]( ជាធម៌រារាំងចិត្តមិនឲ្យងាកទៅរកអំពើជាកុសល ) ។ អានិសង្សទាំង ៥ យ៉ាងនេះ ជា**សន្ទិដ្ឋិកផល** គឺផលដែលឃើញច្បាស់ក្នុងបច្ចុប្បន្ននេះក៏មាន ជា **សម្បរាយិកផល** គឺផលដែលត្រូវមានជាប់ទៅក្នុងបរលោកក៏មាន ។

*៨៨.សំណួរ៖ តើអ្នកស្តាប់ធម៌ទទួលបានអានិសង្សប៉ុន្មានយ៉ាង? មានអ្វីខ្លះ?*

ចម្លើយ៖ អ្នកស្តាប់ធម៌រមែងទទួលបានអានិសង្ស ៥ យ៉ាងគឺៈ

១-រមែងបានស្តាប់ធម៌ដែលមិនទាន់បានស្តាប់ ។

២-ធម៌ណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្ត និងចូលចិត្តច្បាស់ឡើងបាន ។

៣-រមែងកំចាត់បង់នូវសេចក្តីសង្ស័យបាន ។

---

២៨ មាន ៥ យ៉ាង គឺ ១-**កាមច្ឆន្ទៈ** សេចក្តីប្រាថ្នាឬការពេញចិត្តចំពោះកាម; ២-**ព្យាបាទៈ** គំនុំ ឬ សេចក្តីគុំកួនធ្វើឲ្យអ្នកដទៃវិនាស; ៣-**ថីនមិទ្ធៈ** ការច្រអូសធុញទ្រាន់និងការងងុយដេក; ៤- **ឧទ្ធច្ចកុក្កុច្ចៈ** សេចក្តីរាយមាយនិងសេចក្តីរសាប់រសល់ឬក្តៅក្រហាយក្នុងចិត្ត; ៥-**វិចិកិច្ឆា** សេចក្តីសន្ទិះសង្ស័យមិនដាច់ស្រេចក្នុងចិត្ត : *នីវរណធម៌ជាទំនាស់នៃសមាធិ ។*

៤-រមែងធ្វើសេចក្ដីឃើញឲ្យត្រង់តាមការពិត ។

៥-ចិត្តអ្នកស្ដាប់នោះរមែងជ្រះថ្លា ។

អ្នកស្ដាប់នឹងទទួលបាននូវអានិសង្សទាំង ៥ យ៉ាងនេះ ត្រូវតាំងចិត្តស្ដាប់ បញ្ជូនក្រសែចិត្តទៅតាមធម៌ មិនបណ្ដោយឲ្យចិត្តរវើរវាយ មានសុភាសិតជាគ្រឿងដាស់តឿនសតិថា *"សុស្សូសំ លភតេ បញ្ញំ"* ការស្ដាប់*ដោយល្អ រមែងបាននូវបញ្ញា* ។ ការតាំងចិត្តស្ដាប់ដូច្នេះ រមែងសម្រេចប្រយោជន៍នៃការស្ដាប់ គឺទទួលបានអានិសង្សដូចពោលមកហើយនេះ ។

ម្យ៉ាងទៀត វាចាសុភាសិតរមែងបានផលដល់អ្នកស្ដាប់ដោយគោរព ដូចជាផ្កាឈើដែលមានទ្រង់ទ្រាយសណ្ឋានល្អ ទាំងពណ៌សម្បុរក៏ល្អ ក្លិនក៏ក្រអូប រមែងជ្រួតជ្រាបទៅក្នុងកាយរបស់អ្នកទ្រទ្រង់ក៏ដូច្នោះដែរ ។

**សព្វទានំ ធម្មទានំ ជិនាតិ**

អំណោយធម៌ ឈ្នះអស់អំណោយទាំងអស់!

**សព្វរសំ ធម្មរសោ ជិនាតិ**

រសនៃព្រះធម៌ ឈ្នះអស់រសទាំងអស់!

**សព្វរតឹ ធម្មរតិ ជិនាតិ**

ការត្រេកអរក្នុងធម៌ ឈ្នះអស់ការត្រេកអរទាំងពួង!

**តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ**

ការអស់ទៅនៃតណ្ហា ឈ្នះអស់ទុក្ខទាំងពួង!

***៨៩.សំណួរៈ តាមទានប្រវត្តិថា ទានមានមកជាមួយការកើតឡើងនៃពិភពលោក, ចង់ដឹងថា តើអ្នកណាជាអ្នកបង្កើតទាននេះ មិនមែនព្រះពុទ្ធបរមគ្រូរបស់យើងទេឬ ?***

ចម្លើយៈ ទានកើតមកពីសញ្ចេតនាញាណនៃមនុស្ស គឺមនុស្សទាំងអស់គ្នាដឹងថាខ្លួនម្នាក់ៗពុំអាចរស់នៅបានដោយមិនមានអំណោយអំពីមនុស្សគ្នាឯង។ ព្រះពុទ្ធបរមគ្រូរបស់យើង ទ្រង់មិនបង្កើតទានទេ តែទ្រង់ស្គាល់ថាជីវិតមនុស្សបើមិនមានទាន ក៏មិនអាចរស់នៅបានក្នុងពិភពលោកសឹងប្រកបទៅដោយគ្រោះថ្នាក់បានឡើយ ។ ការស្គាល់របស់ព្រះអង្គអំពីរឿងទាននេះ មិនត្រឹមតែធ្វើឲ្យព្រះអង្គយកចិត្តទុកដាក់ សំអាតទានធម្មតា(បាដិបុគ្គលិកទាន) ឲ្យល្អលើសដើមបុណ្ណោះទេ គឺថែមទាំងធ្វើឲ្យព្រះអង្គរៀបចំសង្ឃទាន សម្រាប់សាសនារបស់ព្រះអង្គ ដោយការបដិវត្តន៍ចាកទានទូទៅក្នុងមនុស្សលោក ។

***៩០.សំណួរៈ ធម្មទាន និង អាមិសទានដែលមាននិយាយក្នុងទានប្រភេទណាមួយមានផលច្រើនជាង ?***

ចម្លើយៈ ធម្មទានមានផលច្រើនជាង ព្រោះធម្មទានធ្វើឲ្យមនុស្សមានបញ្ញាជាសម្មាទិដ្ឋិ ។ បញ្ញាបែបនេះកាលណាកើតឡើង រមែងធ្វើឲ្យមនុស្សយើងឃើញសច្ចធម៌បានសម្រេចមគ្គផលនិព្វាន អស់សេចក្តីទុក្ខប្រចាំខន្ធ ៥ ។ ចំណែក អាមិសទានមានត្រឹមតែធ្វើឲ្យមនុស្សធូរថយចាកសេចក្តីទុក្ខក្នុងបច្ចុប្បន្នបន្តិចបន្តួច ។ ឧទាហរណ៍ សាងមន្ទីរពេទ្យជួយឲ្យមនុស្សបានជាជំងឺ តែមិនបានយូរប៉ុន្មានក៏ចាប់ឈឺឡើងវិញ។សាងធម៌ដោយបង្រៀន ឬដោយគម្ពីរក្បួនតម្រា ជួយឲ្យមនុស្សឃើញនូវអរិយសច្ច (ទុក្ខ,សមុទយ, និរោធ,មគ្គ) ក្នុងទីបំផុតក៏បាននិព្វាន ។ សាងមន្ទីរពេទ្យជាកុសលជាន់ទាប សាងធម៌ជាកុសលជាន់ខ្ពស់ ។

*៩១.សំណួរ៖ ក្នុងទានលក្ខណៈមាននិយាយអំពីរបស់អាក្រក់ល្អ,ចង់ដឹងថា តើគុណភាពនេះសំដៅយកវត្ថុដែលមានតម្លៃច្រើន ឬ សំដៅយកទឹកចិត្ត ស្រឡាញ់រាប់អាន ?*

ចម្លើយ៖ គុណភាពត្រូវថ្លឹងតាមទឹកចិត្ត ប្រសិនបើជាមនុស្សទាល់ក្រ ។ ត្រូវថ្លឹងតាមវត្ថុមានតម្លៃច្រើន ប្រសិនបើជាមនុស្សមានទានស្តុកស្តម្ភ ។ តែបញ្ហានេះមិនអាចសម្រេចដាច់ខាតបានទេ ព្រោះក្នុងគម្ពីរជាន់ខ្ពស់នៃព្រះពុទ្ធសាសនា លោកមិនបានសំអាងយកវត្ថុ លោកសំអាងយកតែទឹកចិត្តប៉ុណ្ណោះ ។ ដូច្នេះហើយបញ្ហាអាក្រក់ល្អ នឹងជាគុណភាពរបស់ចិត្ត ឬរបស់វត្ថុនោះ យើងត្រូវទុកឲ្យអ្នកធ្វើទានឆ្លើយដោយខ្លួនឯងចុះ ។ របៀបឆ្លើយគឺបើអ្នកក្រឲ្យទានដោយអំបិលបុកក្រសាំង ដែលជាអាហារ គេចាត់ថាអន់បំផុតក្នុងសង្គមអ្នកមានស្តុកស្តម្ភ តែចិត្តរបស់អ្នកក្រនឹកថា ជាអាហារខ្ពង់ខ្ពស់សម្រាប់ខ្លួនគេ ក៏អាចសម្រេចបានថាគុណភាពខ្ពង់ខ្ពស់ ស្រេចហើយតែចិត្តខ្ពង់ខ្ពស់ មិនមែនស្រេចលើវត្ថុនោះទេ ។ ផ្ទុយទៅវិញអ្នកមានទានស្តុកស្តម្ភឲ្យដោយវត្ថុដដែលនេះ តែគេសម្គាល់ថាជាវត្ថុខ្ពង់ខ្ពស់របស់គេដែរនោះ ក៏ត្រូវសម្រេចថា សេចក្តីខ្ពង់ខ្ពស់ស្រេចហើយតែចិត្ត ។ តែតាមធម្មតាសេចក្តីពិតដែលមាននៅក្នុងចិត្តរបស់មនុស្សយើង មិនអាចប្រព្រឹត្តទៅបានស្មើគ្នា ឬ ដូចគ្នាទាំងអស់ទេ ។ បើអ្នកក្រគិតថាអំបិលបុកក្រសាំងជាអាហារខ្ពង់ខ្ពស់របស់ខ្លួន គំនិតនេះប្រហែលមានពិតមែន ព្រោះអ្នកក្រគ្នាធ្វើទានអំពីគ្មាន ។ ចំណែកអ្នកមានស្តុកស្តម្ភគិតថា អំបិលបុកក្រសាំងជាអាហារខ្ពង់ខ្ពស់របស់ខ្លួនដែរនោះ គំនិតនេះប្រហែលជាមិនពិតទេ ព្រោះអ្នកមានគេធ្វើទានអំពីសល់ ។

*៩២.សំណួរ៖ ក្នុងទានប្បច្ចេកទេស មាននិយាយអំពីអ្នកធ្វើទាន ត្រូវស្គាល់របៀបបច្ចេកទេស, ចង់ដឹងថា តើរបៀបបច្ចេកទេសនោះមានគ្រប់ទេយ្យទានទាំងអស់ ឬ សល់ខានមិនមានខ្លះដែរ ?*

ចម្លើយ៖ មានគ្រប់ទាំងអស់ ព្រោះរបៀបធ្វើទានគឺជារបៀបហាត់រៀនរបស់មនុស្សយើង ព្រោះមនុស្សម្នាក់ៗបើតាមនិស្ស័យសន្តានដែលមានមកជាមួយធម្មជាតិនោះ សុទ្ធចង់ល្អគ្រប់ៗគ្នា ។ ដើម្បីឲ្យបានសម្រេចតាមបំណងរបស់ខ្លួន អ្នកធ្វើទានត្រូវតែហាត់រៀនធ្វើឲ្យត្រូវរបៀបបច្ចេកទេស ទើបត្រូវបានទទួលផលតាមរបៀបបច្ចេកទេស ។

*៩៣.សំណួរ៖ ក្នុងទានវិចារណ៍ មាននិយាយអំពីទានដែលបុគ្គលធ្វើដោយជ្រើសរើស និង ទានដែលបុគ្គលធ្វើដោយមិនមានជ្រើសរើស តើ ជ្រើសរើសអ្វីខ្លះ ?*

ចម្លើយ៖ ជ្រើសរើសទាំងទេយ្យទាន ទាំងបដិគ្គាហក ។ ដែលថាជ្រើសរើសទេយ្យទានគឺជ្រើសរើសរបស់ដែលត្រូវឲ្យ ។ របៀបជ្រើសរើស គឺត្រូវយករបស់ណាដែលរកបានដោយកម្លាំងការងារដ៏ត្រឹមត្រូវរបស់ខ្លួន ព្រោះពុទ្ធសាសនា មិនចង់ឲ្យគេជិះជាន់យកទ្រព្យសម្បត្តិអំពីជនពួកមួយ មកសង្គ្រោះជនពួកមួយទៀត គឺធ្វើបាបលើជនពួកមួយ ធ្វើបុណ្យលើជនពួកមួយ ។ ដទៃអំពីនេះទៀត ពុទ្ធសាសនាមិនចង់ឲ្យអ្នកធ្វើទាន យករបស់ដែលខ្លួនប្រើលែងកើត ឬ របស់ដែលខ្លួនចោលលែងប្រើមកធ្វើទាននោះទេ ព្រោះទានជាអនុស្សាវរីយ៍របស់អ្នកបំពេញទាន ។ ដូច្នេះត្រូវរើសយករបស់ណាដែលខ្លួនស្រឡាញ់ ដែលខ្លួនទុកដាក់ថាជារបស់ថ្លៃថ្នូរ យកមកធ្វើទាន ទើបឈ្មោះថាបានបំពេញមុខងារខាងទេយ្យទាន ។ ដែលថាជ្រើសរើសបដិគ្គាហកនោះ គឺជ្រើសរើសបុគ្គលអ្នកទទួលទាន ។ របៀបជ្រើសរើសគឺស្វែងរកបុគ្គលមានសីលធម៌ មានសេចក្តីព្យាយាមលះបង់បាប មានបញ្ញា

ស្គាល់ខុសត្រូវ ។ល។ ព្រោះពុទ្ធសាសនាចង់ឲ្យមនុស្សមានសីលធម៌ប្រចាំខ្លួន មានសេចក្តីព្យាយាមធ្វើការល្អសម្រាប់មនុស្ស មានបញ្ញាស្គាល់បញ្ហាជីវិត ។ល។ មិនចង់ឲ្យមានមនុស្សគំផិល មិនចង់ឲ្យមានមនុស្សទុច្ចរិត មិនចង់ឲ្យមនុស្សមានមារយាទថោកទាបរស់នៅក្នុងសង្គម ព្រោះការរស់នៅថោកទាបនៃជនពួកនេះ អាចធ្វើឲ្យសង្គមមនុស្ស មានគ្រោះថ្នាក់ ក្នុងអនាគតកាលជាមិនខាន ។

*៩៤.សំណួរ៖ការជ្រើសរើស បដិគ្គាហក នោះគេត្រូវជ្រើសរើសក្នុងឋាន:ទានណាជា បាដិបុគ្គលិកទាន ឬ សង្ឃទាន ?*

ចម្លើយ៖ គេជ្រើសរើសតែក្នុងបាដិបុគ្គលិកទាន, ចំណែកសង្ឃទាន គេមិនត្រូវជ្រើសរើសទេ ព្រោះពាក្យថា "**សង្ឃ**" ក៏ដូចជាពាក្យ "**រាជការ**" ដែរ សង្ឃមិនមានទ្រុស្តសីល តែបុគ្គលមានទ្រុស្តសីល ។ រាជការមិនមានទុច្ចរិត តែភ្នាក់ងាររាជការ មានទុច្ចរិត ។

*៩៥.សំណួរ៖ តើពុទ្ធសាសនារបស់យើងជាសត្រូវនឹងមនុស្សទុច្ចរិត ឬទេ ?*

ចម្លើយ៖ មិនមែនទេ ។

*៩៦.សំណួរ៖ បើមិនជាសត្រូវទេ ហេតុដូចម្តេចទើបដឹកនាំមិនឲ្យមនុស្សធ្វើអំណោយដល់មនុស្សទុច្ចរិត ?*

ចម្លើយ៖ មិនមែនមិនឲ្យធ្វើអំណោយក្នុងពេលដែលមនុស្សទុច្ចរិតកំពុងរងគ្រោះថ្នាក់នោះទេ គឺមិនឲ្យធ្វើអំណោយក្នុងពេលដែលមនុស្សទុច្ចរិតសុខសប្បាយធម្មតា ព្រោះពុទ្ធសាសនាមិនមានប្រាថ្នាអ្វីក្រៅពីការកាត់ជំនួយ បើជនទុច្ចរិតដឹងខ្លួនសូមចុះចូលពុទ្ធសាសនាឲ្យសង្គ្រោះដើម្បីសុខសន្តិភាពក្នុងជីវិតរបស់គេ ។

*៩៧.សំណួរៈ ដែលថាសង្ឃទានធ្វើបានដោយលំបាកនោះ តើលំបាកព្រោះអ្វី ?*
ចម្លើយៈ លំបាកព្រោះរៀបចំចិត្តឲ្យនៅក្នុងភាពជាប្រក្រតីមិនបាន ព្រោះចិត្តរបស់មនុស្សយើងតែងរេទៅក្នុងសោមនស្សភាព ប្រសិនបើបានទេយ្យទាន និង បដិគ្គាហក ដែលខ្លួនធ្លាប់ស្រឡាញ់ ធ្លាប់ស្គាល់រាប់អាន ។ តែងរេទៅក្នុង ទោមនស្សភាព ប្រសិនបើបានទេយ្យទាន និង បដិគ្គាហក ដែលខ្លួនមិនចូលចិត្ត មិនធ្លាប់បានប្រាស្រ័យទាក់ទង ។

*៩៨.សំណួរៈ ទានចែកជា ២ គឺជាបាដិបុគ្គលិកទាន និង សង្ឃគតាទក្ខិណាទាន ព្រះពុទ្ធទ្រង់សរសើរថា សង្ឃគតាទក្ខិណាទាន ប្រសើរជាងបាដិបុគ្គលិកទាន សូម្បីថ្វាយដល់ព្រះពុទ្ធបានមិនដល់សង្ឃគតាទក្ខិណាទាន ចុះហេតុអ្វីបានជាសង្ឃគតាទក្ខិណាទាន មិនដែលឲ្យផលជាទិដ្ឋធម្មវេទនីយកម្មសោះ ហាក់ដូចជាបាដិបុគ្គលិកទានមានផលច្រើនជាង ?*
ចម្លើយៈ សង្ឃគតាទក្ខិណាទាន នៅតែមានបុណ្យច្រើនជាង ឲ្យតាំងពីថ្ងៃធ្វើទៅទល់នឹងបានព្រះនិព្វានទើបអស់ ចំណែកទិដ្ឋធម្មវេទនីយនោះ ឲ្យតែក្នុងមួយជាតិនេះទេ មិនជូនទៅជាតិមុខទៀតឡើយ ប្រៀបដូចអ្នកធ្វើស្រែធ្វើស្រូវស្រាល ៣ ខែ ឆាប់បាន តែមិនសូវបានផលច្រើន អ្នកធ្វើស្រូវធ្ងន់ពិតមែនតែយូរ ប៉ុន្តែមានផលច្រើនជាង,ទិដ្ឋធម្មវេទនីយ ដូចជាស្រូវស្រាល, សង្ឃគតាទក្ខិណាទាន ដូចជាស្រូវធ្ងន់ ។

*៩៩.សំណួរៈ ទានប្រកបដោយធម៌ប៉ុន្មានយ៉ាងទើបបានបុណ្យ ? គេឲ្យទានដទៃៗក្រៅសាសនាគង់គេឲ្យកើតដែរ ក៏មិនចាត់ថាបានបុណ្យផង ?*
ចម្លើយៈ ទានប្រកបដោយធម៌ ៤ យ៉ាងទើបបានបុណ្យគឺៈ

១-**សទ្ធា** សេចក្តីជឿបុណ្យ, ជឿបាប, ជឿកម្ម, ជឿផល

២-**ហិរិ** គឺសេចក្តីខ្មាសទុច្ចរិត, ខ្មាសអំពើអាក្រក់, ខ្មាសបាប

៣-**ចាគចេតនា** គឺជាចេតនានៃការលះឲ្យ

៤-**វិរតិ** គឺការវៀរ, វៀរលែង, ការតមដាច់ខាត, ការកាន់ត្រណម ។

គេឲ្យទានដទៃៗក្រៅសាសនា បានជាចាត់ថាមិនបានបុណ្យ ព្រោះមិនប្រកបដោយធម៌ទាំង ៤ យ៉ាងខាងលើនេះឯង ។

***១០០.សំណួរ៖ ហេតុដែលឲ្យកើតជាទាន តើ មានប៉ុន្មានយ៉ាង ?***

ចម្លើយ៖ ហេតុដែលឲ្យកើតជាទានមាន ២ យ៉ាងគឺៈ

១-**សទ្ធា** ការជឿ

២-**អប្បមាទ** សេចក្តីមិនធ្វេសប្រហែស ។

***១០១.សំណួរ៖ ឲ្យទានមិនកើតព្រោះធម៌ អ្វី ?***

ចម្លើយ៖ ឲ្យទានមិនកើតព្រោះធម៌ ពីរ យ៉ាងគឺៈ

១-**មច្ឆរិយ** សេចក្តីកំណាញ់

២-**បមាទ** សេចក្តីប្រមាទ

***១០២.សំណួរ៖ ពាក្យថា "ទាន" សំដៅយកធម៌ ប៉ុន្មានយ៉ាង ?***

ចម្លើយ៖ ពាក្យថា "**ទាន**" សំដៅយកធម៌ ៣ យ៉ាងគឺៈ

១-**សទ្ធា** ការជឿ

២-**ហិរិ** សេចក្តីខ្មាសអំពើបាប

៣-**កុសល** សេចក្តីល្អ ។

- ការធ្វើទាន អាចឲ្យសម្រេចត្រឹមមគ្គ ៣ គឺៈ

១-សោតាបដិមគ្គ

២-សកទាគាមិមគ្គ

៣-អនាគាមិមគ្គ

បើធ្វើសីលផងទើបសម្រេចផលបាន ។៚

*១០៣.សំណួរៈ សាច់ដែលមិនគួរប្រគេនលោក និង លោកមិនគួរឆាន់ មានប៉ុន្មានយ៉ាង ? បើភិក្ខុដឹងហើយ នៅតែឆាន់ តើ ភិក្ខុនោះត្រូវ អាបត្តិ អ្វី ?*

ចម្លើយៈ សាច់មិនគួរឆាន់ មិនគួរប្រគេន ហៅថា អកប្បិយមំសៈ ១០ យ៉ាង

| | |
|---|---|
| ១-សាច់មនុស្ស | ២-សាច់ដំរី |
| ៣-សាច់សេះ | ៤-សាច់ឆ្កែ |
| ៥-សាច់ពស់ | ៦-សាច់សីហៈ |
| ៧-សាច់ខ្លាធំ | ៨-សាច់ខ្លាដំបង |
| ៩-សាច់ខ្លាឃ្មុំ | ១០-សាច់ខ្លារខិន ។ |

ព្រះសម្មាសម្ពុទ្ធបរមគ្រូជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឆាន់សាច់មនុស្សទេ ភិក្ខុណាឆាន់ត្រូវអាបត្តិថុល្លច្ច័យ ។ ភិក្ខុមិនត្រូវឆាន់សាច់ដំរី-សេះ-ឆ្កែ-ពស់-សីហៈ-ខ្លាធំ-ខ្លាដំបង-ខ្លាឃ្មុំ និងសាច់ខ្លារខិនទេ បើភិក្ខុណាឆាន់ត្រូវអាបត្តិទុក្កដ ។

*ចំណាំៈសាច់ដទៃទៀត ផ្សេងអំពីសាច់ទាំង ១០ ខាងលើនេះ ពុទ្ធបរិស័ទអាចប្រគេនភិក្ខុបាន ហើយភិក្ខុអាចឆាន់បានដោយមិនមានទោសឡើយ ។*

*(វិន័យបិដក ភាគ ៧ ទំព័រ ២៧៩-២៨៤)*

## សាច់បរិសុទ្ធដោយហេតុ ៣ យ៉ាង

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងថាសាច់គេធ្វើចំពោះ (ខ្លួន) កុំគប្បីបរិភោគ ភិក្ខុណាបរិភោគត្រូវអាបត្តិទុក្កដ ។

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតត្រី និងសាច់ ដែលបរិសុទ្ធជាទីបំផុតដោយហេតុ ៣ យ៉ាងគឺ មិនបានឃើញ ១ មិនបានឮ១ មិនបានរង្កៀស ១ ។ (វិន័យបិដក ភាគ ៧ ទំព័រ ៣៣៧)

# ទានានិសង្ស

# ទានានិសង្ស

ពាក្យថាទានានិសង្ស មានន័យថា ផលនៃការធ្វើទាន ឬ ផលានិសង្ស នៃការធ្វើទាន ។ ចំពោះអានិសង្សទាននេះ ជនពួកមួយក្នុងលោកនេះគេមិន មានជំនឿផងទេ ព្រោះគេយល់ថា ទានធ្វើទៅអស់ទ្រព្យ ផលរបស់ទានមាន ទ្រព្យ ហេតុ និងផលមិនស៊ីគ្នា ។ ក្នុងចំណុចនេះខ្ញុំយល់ថា ហេតុផលស៊ីគ្នា ហើយ ហេតុអ្វីបានជាថាស៊ីគ្នា ? ហេតុថា មានកើតពីអស់ អ្វីតែមិនមានអស់ ក៏មិនមាន មានដែរ ។ អ្នកធ្វើទានអស់ទ្រព្យទៅ តែផលរបស់ទានជួយឲ្យ អ្នកធ្វើមានចិត្តល្អ ចិត្តល្អជាបច្ច័យឲ្យមានបដិសន្ធិចិត្តល្អ ទៅក្នុងភពថ្មី ។ បដិសន្ធិលោកចែកជា ៤ គឺ អបាយបដិសន្ធិ, កាមសុគតិបដិសន្ធិ, រូបាវចរ បដិសន្ធិ និងអរូបាវចរបដិសន្ធិ ។ អ្នកមានចិត្តល្អ មិនដែលទៅបដិសន្ធិក្នុង អបាយទេ បើយ៉ាងអន់ណាស់ក៏គង់ទៅបដិសន្ធិក្នុងកាមសុគតិភព គឺបើកើត ក្នុងស្រុកមនុស្សរមែងកើតក្នុងត្រកូលខ្ពង់ខ្ពស់ ឬត្រកូលមានទ្រព្យសម្បត្តិ។ ការដោះស្រាយនេះត្រូវយើងចាំទុក ព្រោះការដោះស្រាយនេះ បានផ្អែកទៅ លើបរមត្ថធម៌ ដែលស្ដីអំពីចិត្តទាំងស្រុង តែប៉ុណ្ណោះ ។

មកដល់ចំណុចនេះ ខ្ញុំសូមលើកយកនូវអានិសង្ស នៃការធ្វើទាន នានាដែលមាននៅក្នុងគម្ពីរព្រះត្រ័យបិដក និងសូត្រផ្សេងៗទៀត ដើម្បីឲ្យ ពុទ្ធបរិស័ទអ្នកធ្វើទាន បានជាគំនិតត្រិះរិះពិចារណា ប្រកបដោយបញ្ញាចេះ ស្វែងរកហេតុ រកផល ដែលប្រកបដោយវិចារណញាណ និង កាន់តែមាន សទ្ធាយ៉ាងមុតមាំបន្ថែមទៀត ទៅលើផលកម្រៃ នៃការបរិច្ចាគទាននោះៗ ដូចតទៅនេះ ៖

## ➢ ១.អានិសង្សទឹកឃ្មុំ

- រីករាយក្នុងទេវលោកអស់ ៣ ម៉ឺនកប្ប
- ភ្លៀងទឹកឃ្មុំ
- ជាអ្នកមានបាយ និងទឹកជាប្រក្រតី
- កើតតែក្នុងទេវលោក និងមនុស្សលោក
- ជាអ្នកបានសម្រេចនូវ សេចក្តីប្រាថ្នាគ្រប់យ៉ាង
- មិនទៅកាន់ទុគ្គតិអស់ ៣ ម៉ឺនកប្ប
- បាននូវបដិសម្ភិទា[២៩]៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដកលេខ ៧៤ ទំព័រ ១៨៤)

## ➢ ២.អានិសង្សឱសថព្យាបាលជំងឺ

- នឹងត្រេកអរក្នុងទេវលោកអស់ ១ សែនកប្ប
- បានជាស្តេចចក្រពត្តិ ១ ពាន់ដង
- រីករាយក្នុងការប្រគំតន្ត្រី ក្នុងទេវលោកនោះសព្វៗកាល
- បានសោយរាជ្យជាក្សត្រ
- កើតជាទេវតាក្តី ជាមនុស្សក្តី មិនមានអាពាធ វៀរបង់នូវព្យាធិជាគ្រឿងក្តៅក្រហាយក្នុងលោក
- ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះ មិនស្គាល់ទុគ្គតិ
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដកលេខ ៧៤ ទំព័រ ១៩៤)

---

២៩ **បដិសម្ភិទា** ៤ គឺៈ១.ប្រាជ្ញាដែលបែកចំពោះអត្ថ, ២.ប្រាជ្ញដែលបែកចំពោះក្នុងធម៌, ៣.ប្រាជ្ញាដែលបែកចំពោះក្នុងភាសានិយាយ,៤.ប្រាជ្ញាដែលបែកចំពោះក្នុងបដិភាណ ។

## ➢ ៣.អានិសង្សថ្វាយទឹក

- បានទៅកើតក្នុងឋានតាវតឹង្ស
- មានវិមានដ៏ល្អប្រសើរ
- ប្រសើរជាងស្រីអប្សរ ១០០០ នាក់
- គ្របសង្កត់លើស្រីទាំងនោះ ដោយហេតុ ១០ យ៉ាង
- បានកើតជាមហេសីនៃស្តេចទេវរាជ ៥០ ដង
- បានកើតជាមហេសីស្តេចចក្រពត្តិ ២០ ដង
- កាលណាប្រាថ្នាចង់បានទឹក នៅលើកំពូលភ្នំក្តី នៅលើចុងឈើក្តី ពួដ៏អាកាសក្តី នៅលើផែនដីក្តី ក៏បាននូវទឹកនោះដ៏ឆាប់
- បើចង់បានទឹកកាលណាមេឃក៏ញុំាងភ្លៀងឲ្យធ្លាក់ក្នុងកាលនោះ
- កំដៅក្តី សេចក្តីក្រហលក្រហាយក្តី ធូលីក្តីក៏មិនមានក្នុងកាយឡើយ
- មិនទៅកាន់ទុគ្គតិអស់ ៩១ កប្ប
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ[៣០]៨ និង អភិញ្ញា ៦ ។

(ចាក បិដកលេខ ៧៦ ទំព័រ ២១)

## ➢ ៤.អានិសង្សភេសជ្ជៈ

- ជាអ្នកមានអាយុវែង - មានកម្លាំង - មានប្រាជ្ញាច្រើន
- មានពណ៌សម្បុរល្អ - មានសេចក្តីសុខ -មិនមានឧបទ្រុព
- មិនមានចង្រៃ -ត្រូវគេគោរពកោតក្រែងសព្វកាល
- មិនមានការប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់
- មានយស ។

---

៣០ **វិមោក្ខធម៌** គឺជា ធម៌ដែលនាំឲ្យរួចស្រឡះចាកសេចក្តីសៅហ្មងចិត្ត (ព្រះនិព្វាន) ។

## ➢ ៥. អានិសង្សសប្បិ (ទឹកដោះថ្លា)

- បានកើតជាទេវតា និងមនុស្សតែងបានសេចក្តីសុខដ៏ធំ
- បានដល់នូវអចលបទ គឺព្រះនិព្វាន
- បានសោយរាជ្យជាស្តេចទេវតា ៥៤ ដង
- បានជាស្តេចចក្រពត្តិ ៥១ ដង
- បាននូវភោគៈប្រមាណមិនបាន
- មិនទៅកាន់ទុគ្គតិអស់ ៣០ ពាន់កប្ប
- មិនដែលសុំសប្បិអ្នកដទៃ
- សប្បិកើតឡើងតាមសេចក្តីប្រាថ្នា
- បាននូវសប្បិរាប់មិនអស់
- បាននូវសំពត់គ្រឿងក្រអូប និងសប្បិ និងវត្ថុដទៃដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន
- មានសតិប្បដ្ឋានជាទីដេក មានសមាធិជ្ឈានជាគោចរ ញ៉ាំងពោជ្ឈង្គឲ្យកើតឡើង
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដកលេខ ៧៤ ទំព័រ ២២)

## ➢ ៦.អានិសង្សបាយ និងទឹក

- មានអាយុវែង - មានកម្លាំង - មានសេចក្តីសុខ
- មានពណ៌សម្បុរល្អ - មានយស - ជាអ្នកមានប្រាជ្ញា
- ជាអ្នកក្លៀវក្លា - ជាអ្នកមានបាយ និងទឹក ។

## ៧.អានិសង្សទឹកដោះរាវ

- បាននូវទឹកដោះថ្លាប្រមាណមិនបាន
- បាននូវកប្បព្រឹក្សជាទិព្វ
- បានសោយបទេសរាជ្យរាប់ជាតិមិនអស់
- បានកើតជាព្រះឥន្ទ្រសោយទេវរាជ្យ ៥០ ដង
- បានជាស្តេចចក្រពត្តិ ៥១ ដង
- មិនទៅកាន់ទុគ្គតិអស់ ៩៤ កប្ប
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា[៣១]៦ ។

## ៨.អានិសង្សទឹកដោះជូរ

- បានបរិភោគភត្ត គឺអមតៈ និង កាយគតាសតិដ៏ប្រសើរ ។

## ៩.អានិសង្សស្បែកជើង (ធ្វើពីស្បែកសុទ្ធ)

- មានយានដំរី យានសេះ គ្រែស្នែង និង រថទ្រុងគ្រឿង រថ ៦ ម៉ឺន តែងចោមរោមគ្រប់កាលទាំងពួង
- អន្ទោលទៅក្នុងភពមានទ្រនាប់ជើងមាសប្រាក់ ជាវិការៈនៃកែវមណី តែងតែកើតឡើងគ្រប់ជំហាន
- ទ្រនាប់ជើងទាំងនេះ តែងនាំឲ្យស្ទុះទៅកាន់សម្មតិនិយាម ជាគ្រឿងជម្រះនូវអាការៈ និង គុណធម៌
- មិនទៅកាន់ទុគ្គតិអស់ ៩១ កប្ប
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

---

៣១ **អភិញ្ញា** សេចក្តីដឹងយ៉ាងខ្ពស់; សេចក្តីដឹងវិសេសដែលកើតអំពីកម្លាំងនៃឈានៈ បានសម្រេចអភិញ្ញា ។

- **១០. អានិសង្សបោសសំអាត**

- រីករាយក្នុងទេវលោក
- មានចិត្តឥតកករល្អក់ឡើយ ជាចិត្តថ្លាស្អាតសព្វៗកាល
- មិនដែលស្គាល់សេចក្តីសោកដែលជាហេតុធ្វើឲ្យចិត្តក្តៅឡើយ
- រោគឃ្លង់ ពក ស្រែង ឆ្កួតជ្រូក ឃ្លង់ដែក ពិស កមរមាសពុំមាន
- ជាចិត្តត្រង់ ប្រាថ្នាសមាធិណា សមាធិនោះរមែងសម្រេច
- មិនដែលត្រេកត្រអាល ចំពោះវត្ថុដែលគួរត្រេកត្រអាល
- មិនដែលប្រទូស្ត ចំពោះវត្ថុដែលគួរប្រទូស្ត
- មិនដែលវង្វេង ចំពោះវត្ថុដែលគួរវង្វេង
- មិនទៅកាន់ទុគ្គតិអស់ ៩១ កប្ប
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។
(ចាកៈ បិដកលេខ ៧៤ ទំព័រ ៣៨)

- **១១.អានិសង្សកសាងព្រះចេតិយខ្សាច់**

- បានទៅកើតក្នុងទេវលោក ១៨ កប្ប[៣២]
- បានកើតជាស្តេចចក្រពត្តិ ៥០០ ដង
- មិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។
(ចាកៈ បិដកលេខ ៧៤ ទំព័រ ១៨២)

---

៣២ **កប្ប** (កល្ប) កាលដែលតាំងនៅយូរអង្វែង : មួយកប្ប, ភ្លើងប្រល័យកប្ប ។

### ➢ ១២.អានិសង្សដំបូលស្មៅ លើព្រះចេតិយ

- បាននូវវិមានក្នុងឋានតាវតឹង្សនោះ មានសម្បុរភ្លឺដូចមាស មានកម្ពស់ ៦០ យោជន៍ មានទំហំ ៣០ យោជន៍
- បានសោយទេវរាជ ៣០០ ដង
- បានជាស្តេចចក្រពត្តិ ២៥ ដង
- បាននូវភោគៈច្រើន មិនមានការខ្វះនូវភោគៈ
- កាលចូលទៅក្នុងព្រៃធំ តែងទៅដោយគ្រែស្នែង ឬ ជិះលើ កដំរី
- មិនដែលឃើញដង្គត់ ឬ បន្លាដោយចក្ខុឡើយ (មិនមានបន្លាពីមុខ)
- មិនកើតរោគឃ្លង់ ពក ស្រែង ឆ្កួតជ្រូក កមរមាស់
- តែងអន្ទោលកើតក្នុងភពពីរគឺ មនុស្ស និងទេវតា
- មានសម្បុរដូចមាស មានរស្មីរុងរឿងក្នុងទីទាំងពួង
- មានសេចក្តីគាប់ចិត្តប្រកដឡើងខ្ជាប់ខ្ជួន
- ចិត្តល្អស្អាត ជាចិត្តមានអារម្មណ៍តែមួយ
- បាននូវ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

### ➢ ១៣.អានិសង្សដាំសួន

- មិនទៅកាន់ទុគ្គតិអស់ ៩៤ កប្ប
- បានជាស្តេចចក្រពត្តិ ៧ ជាតិ
- បាននូវ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

## ➢ ១៤.អានិសង្សកសាងខឿននៃដើមពោធិព្រឹក្ស

- បានទៅកើតឋានតុសិតនៅក្នុងផ្ទះកែវ សម្ពស្សទាំងឡាយ ក្ដៅក្ដី ត្រជាក់ក្ដី ខ្យល់ក្ដី មិនដែលពាល់ត្រូវឡើយ ។
- បានជាស្ដេចចក្រពត្តិ ប្រាសាទឈ្មោះមង្គលដែលវេស្សកម្មទេវបុត្តនិម្មិតថ្វាយ មានទទឹង ១ យោជន៍ មានទំហំ ១ យោជន៍កន្លះ មានសសរ ៨៦០០០ សឹងជាវិការៈនៃមាស និងប្រាក់ ប្រាសាទកំពូលជាវិការៈនៃកែវមណី ដំបូលជាវិការៈនៃប្រាក់។
- ប្រាសាទជាវិការៈនៃមាស វិស្សកម្មទេវបុត្តនិម្មិតថ្វាយ ។
- មិនទៅកាន់ទុគ្គតិអស់ ៣ ម៉ឺនកប្ប ។
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដក លេខ ៧៩ ទំព័រ ១០៤)

## ➢ ១៥.អានិសង្សបូជាសរីរៈព្រះពុទ្ធ

- បានជាទេវតា ។
- មិនទៅកាន់ទុគ្គតិអស់ ៩១ កប្ប
- កាលកើតជាទេវតា ឬ មនុស្សតែងបំពេញបំណងបាន
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

## ➢ ១៦.អានិសង្សថ្វាយបង្គំព្រះពុទ្ធ

- កើតជាស្ដេចចក្រពត្តិ
- មិនទៅកាន់ទុគ្គតិ ៩២ កប្ប
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដក លេខ ៧២ ទំព័រ ២៨៨)

## ➢ ១៧.អានិសង្សបូជាប្រទីបចំពោះព្រះពុទ្ធ

- បានសោយរាជ្យក្នុងទេវលោកអស់ ៣៦ ដង
- គេនឹងទ្រទ្រង់ប្រទីបឲ្យទាំងយប់ ទាំងថ្ងៃ
- បានសោយរាជ្យដ៏ធំទូលាយលើផែនដីបាន ៧០០ ដង
- មិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប
- បានសោយបទេសរាជ្យដ៏ធំទូលាយបាន ១ អសង្ខេយ្យកប្ប
- បាននូវទិព្វចក្ខុនឹងឃើញទីជុំវិញ ២៥០ ជួរធ្នូសព្វកាល
- កើតកំណើតណាៗទោះជាមនុស្ស ឬ ទេវតាតែងមានគេបម្រើ
- ត្រេកអរក្នុងទេវលោកអស់ ៦ ម៉ឺនកប្ប ហើយមានប្រទីបចំនួន ១០០ ភ្លឺរុងរឿង អស់កាលជានិច្ចក្នុងទីនោះ
- រស្មីចេញពីសរីរៈផ្សាយទៅទេវលោក និង មនុស្សលោក
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដក លេខ ៧៤ ទំព័រ ២១០)

## ➢ ១៨.អានិសង្សប្រទីប

- នឹងបាននូវទិព្វចក្ខុ
- ជាអ្នកមានជាតិខ្ពង់ខ្ពស់
- បរិបូណ៌ដោយអវយវៈ
- បានទៅកើតក្នុងឋានតាវតឹង្ស
- មានប្រាជ្ញាដែលព្រះពុទ្ធសន្មតិឲ្យ ។

## ➢ ១៩.អានិសង្សផ្កាឈូក

- បានទៅកើតក្នុងឋានតាវតឹង្ស
- បានកើតជាព្រះឥន្ទ្រសោយរាជ្យ ១០០០ ដង
- មានវិមានក្នុងឋានតាវតឹង្សកម្ពស់៦០យោជន៍ និងទំហំ ៣០យោជន៍
- បានកើតជាស្តេចចក្រពត្តិ ៧៥ ដង
- បានសោយបទេសរាជ្យដ៏ធំទូលាយបាន ១ អសង្ខេយ្យកប្ប
- បានសោយនូវសម្បត្តិទាំងឡាយ
- មិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប
- បានធ្វើឲ្យជាក់ច្បាស់នូវព្រះធម៌
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដក លេខ ៧៤ ទំព័រ ៦៦)

## ➢ ២០.អានិសង្សយកទឹកអប់ក្រអូបបូជាព្រះសម្ពុទ្ធ

- បានសោយជាទេវរាជ ២៥០០ ដង
- បានកើតជាស្តេចចក្រពត្តិ ២៥០០ ដង
- គ្រាប់ភ្លៀងតែងបង្អុរចុះ ១ ព្យាម ជុំវិញរាងកាយមានក្លិនក្រអូប
- ក្លិនដែលជាប់សរីរៈផ្សាយទៅបានកន្លះគីឡូ (៥០០ ម៉ែត្រ)
- មិនទៅកាន់ទុគ្គតិ ១ សែនកប្ប
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

- **២១.អានិសង្សលោកិយសរណគមន៍ ១០ យ៉ាង**

១.មានអាយុទិព្វយូរជាងទេវតាដទៃ

២.មានរស្មីជាទិព្វចេញអំពីកាយ ភ្លឺជាងទេវតាដទៃ

៣.មានសេចក្តីសុខក្នុងឥរិយាបថ ច្រើនជាងទេវតាដទៃ

៤.មានយសធំជាងទេវតាដទៃ

៥.មានតំណែងធំជាងទេវតាដទៃ

៦.មានរូបទិព្វដ៏លើសជាងទេវតាដទៃ

៧.នឹងមានសម្លេងពិរោះជាងទេវតាដទៃ

៨.មានក្លិនក្រអូបទិព្វភាយជាងទេវតាដទៃ

៩.នឹងបានរសជាតិដែលប្រណិតជាងទេវតាដទៃ

១០.នឹងមានសម្ផស្សចម្រើនពេញចិត្តជាងទេវតាដទៃ ជាអ្នកមានព្រះរតនៈត្រៃជាទីពឹង កាលចុតិទៅកើតសុគតិភព បរិបូណ៌ដោយសក្តានុភាព មានសម្លេងទិព្វ ។

- **២២.អានិសង្សដល់នូវត្រៃសរណគមន៍**

- បានទៅកើតក្នុងឋានតាវតឹង្ស
- មានសម្បុរដូចមាស
- ជាអ្នកមានប្រាជ្ញាមោះមុត
- ជាអ្នកមានយសខ្ពង់ខ្ពស់
- ជាអ្នកមានបញ្ញាវាងវៃ
- គេតែងបូជាក្នុងទិសទាំងឡាយ
- តែងបានភោគៈរាប់ចំនួនមិនបាន
- មិនកម្រើកចាកមិត្តទាំងឡាយ

- ពួកទេវតាទាំងអស់តែងប្រព្រឹត្តទៅតាមបុគ្គលនោះ
- នឹងបានសោយរាជ្យជាទេវរាជធំជាងទេវតាទាំងអស់ ៨០ ដង
- បានកើតជាស្តេចចក្រពត្តិ ៧៥ ដង
- កើតជាស្តេចសោយរាជ្យក្នុងប្រទេសធំ ១ អសង្ខេយ្យជាតិ
- បានកើតក្នុងត្រកូលមហាសាលដ៏ស្តុកស្តម្ភ
- មិនទៅកាន់ទុគ្គតិក្នុងកប្បប្រមាណមិនបាន
- បានដល់ព្រះអរហន្តក្នុងអាយុ ៧ ឆ្នាំ
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដក លេខ ៧២ ទំព័រ ១៦៩)

- **២៣.អានិសង្សថ្វាយបង្គំព្រះរតនត្រ័យ ១០ យ៉ាងគឺ:**

- ការពារអន្តរាយទាំងពួង
- តែងបករណ៍សម្រេចដោយល្អ
- ការសិក្សារៀនសូត្រសម្រេចបានល្អ
- ធ្វើឲ្យឧស្សាហ៍ដល់អ្នកសិក្សាកើតឡើង
- ស្រួលដល់ការរៀនព្រះគម្ពីរ
- ដឹងនាមរូបដោយសរុបជាដើម
- ដឹងនាមរូបតាមសភាពពិត
- កើតការនឿយណាយក្នុងនាមរូប
- ដឹងនូវផ្លូវប្រតិបត្តិដើម្បីប្រាសចាកទោស
- បានផលញាណ (បដិបត្តិបានផល) ។

## ➢ ២៤.អានិសង្សសីល ៥

- មានទ្រព្យច្រើន
- ជាអ្នកមានប្រាជ្ញាមោះមុត
- កើតជាស្តេចចក្រពត្តិ ៧៥ ដង
- បានទៅកើតឋានតាវតឹង្ស
- នឹងបានសោយរាជ្យជាទេវរាជធំជាងទេវតាអស់ ៣០ ដង
- កើតជាស្តេចសោយរាជ្យប្រទេសធំទូលាយ ១ អសង្ខេយ្យជាតិ
- បានកើតក្នុងត្រកូលមហាសាលដ៏ស្តុកស្តម្ភ
- បានដល់ព្រះអរហន្តក្នុងអាយុ ៧ ឆ្នាំ មានអាយុវែង
- មិនទៅកាន់ទុគ្គតិក្នុងកប្បប្រមាណមិនបាន
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាកបិដក ៧២ ទំព័រ ១៧៤)

## ➢ ២៥.អានិសង្សឧបោសថ (ឯកុបោសថិកាថេរី)

- បានទៅកើតក្នុងឋានតាវតឹង្ស ។
- ស្រីអប្សរ ១ សែនតែងបម្រើសព្វៗកាល និងរុងរឿងណាស់ ។
- វិមានកំពស់ ១ យោជន៍ មានកំពូលខ្ពស់ដ៏ប្រសើរនិង មាននូវអាសនៈស្អិតស្អាងហើយ ។
- មិនទៅកាន់ទុគ្គតិ ៩១ កប្ប ។
- បានកើតជាមហេសីនៃស្តេចទេវរាជ ៦៤ ដង ។
- បានកើតជាមហេសីស្តេចចក្រពត្តិ ៣៦ ដង ។
- មានពណ៌ដូចមាសតែងអន្ទោលទៅក្នុងភពទាំងពួង ។
- អាយុ ៧ ឆ្នាំ សម្រេចព្រះអរហត្ត ។

- បាននូវវត្ថុទាំងពួងជាវិការៈនៃមាសប្រាក់កែវផលិក
- បាននូវវត្ថុទាំងពួង គឺសំពត់កោសេយ្យពស្ត្រផង សំពត់កម្ពលផង សំពត់សម្បកឈើផង សំពត់ទិព្វផង និងសំពត់តម្លៃច្រើនផង
- បាននូវវត្ថុទាំងពួងគឺ បាយ ទឹក ខាទនីយៈ សេនាសនៈ ។
- បាននូវវត្ថុទាំងពួង គឺគ្រឿងក្រអូបដ៏ប្រសើរ និង កម្រងផ្កាលំអិតសម្រាប់លាប ។
- បាននូវវត្ថុទាំងពួងគឺ ផ្ទះមានកំពូល ប្រាសាទ មណ្ឌបប្រាសាទ មានដំបូលរលើង និង គុហា ។
- តែងបាននូវវត្ថុទាំងពួង គឺយានដំរី យានសេះ និងយានរថ ។
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

## ➢ ២៦.អានិសង្សអ្នកបួស ៧ ថ្ងៃ

- មិនទៅកើតក្នុងទុគ្គតិ តិរច្ឆាន ប្រេត ជាដើម អស់ ៩១ កប្ប
- បានជាស្ដេចចក្រពត្តិ ៧ ជាតិ
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាកបិដក ៧៣ ទំព័រ ២២៦)

## ➢ ២៧.អានិសង្សនៃបព្វជ្ជា(សាមណេរ) និងឧបសម្បទា (ភិក្ខុ)

- បុគ្គលណាបានបំបួសទាសាទាសី ឲ្យជាសាមណេរ បាននូវអានិសង្ស ៤ កប្ប
- បុគ្គលណាបានឲ្យនូវបុត្តរបស់ខ្លួនបួសជាសាមណេរ រមែងបាននូវអានិសង្ស ៨ កប្ប, បើកុលបុត្រនោះឧបសម្បទាជាភិក្ខុរមែងបាននូវអានិសង្ស ១៦ កប្ប

- បើស្វាមី ឬ ភរិយាណា បានព្រមព្រៀងគ្នាឲ្យបួសជាសាមណេរ រមែងបាននូវអានិសង្ស ១៦ កប្ប, បើបានអនុញ្ញាតិឲ្យបួសជាភិក្ខុ រមែងបាននូវអានិសង្ស ៣២ កប្ប
- បុគ្គលណាចេញបួសដោយខ្លួនឯង ជាសាមណេរ រមែងបាននូវអានិសង្ស ២៣ កប្ប, បើបួសជាភិក្ខុ បាននូវអានិសង្ស ៦៤ កប្ប ។ (ដកស្រង់ចេញពី សាស្ត្រាស៊ីការឹត)

➢ **២៨.អានិសង្សបូជាផ្កាម្លិះ**

- មិនទៅកាន់ទុគ្គតិអស់ ៩៤ កប្ប
- កើតជាស្តេចចក្រពត្តិ ១៣ ជាតិ
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។ (ចាក បិដកលេខ ៧៣ ទំព័រ ៤)

➢ **២៩.អានិសង្សថ្វាយផ្កាជាវិការៈនៃមាស**

- បានទៅកើតក្នុងឋានតុសិត
- បានកើតជាស្តេច ១៦ ជាតិ
- មិនទៅកាន់ទុគ្គតិអស់ ៩១ កប្ប
- កើតជាស្តេចចក្រពត្តិមានកម្លាំងច្រើន
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។ (ចាក បិដកលេខ ៧៣ ទំព័រ ២២)

- **៣០.អានិសង្សថ្វាយផ្កាឈូក**

- បានសោយសម្បត្តិទាំងឡាយ
- បានកើតជាស្ដេចចក្រពត្តិ
- មិនទៅកាន់ទុគ្គតិអស់ ១ សែនកប្ប
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ជាតក បិដកលេខ ៧៣ ទំព័រ ៤៤)

- **៣១.អានិសង្សអ្នកទំនុកបម្រុងអារាម** (**ញោមវត្ត**)

- មិនទៅកាន់កំណើតតិរច្ឆាន ប្រេត អសុរកាយ នរក អស់៣១ កប្ប
- បានជាស្ដេច ៧ ជាតិ បរិបូណ៌ដោយកែវ ៧ប្រការ មានកម្លាំងច្រើន
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ជាតក បិដកលេខ ៧៣ ទំព័រ ១១០)

- **៣១.អានិសង្ស ឧបដ្ឋាក** (**អ្នកបម្រើ**)

- មិនទៅកាន់ទុគ្គតិអស់ ៩៤ កប្ប
- បានជាស្ដេចចក្រពត្តិ
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ជាតក បិដកលេខ ៧៣ ទំព័រ ២២៤)

- **៣២.អានិសង្សវេយ្យាវច្ច:***(ការខ្វល់ខ្វាយ, ការខ្នះខ្នែង)*

- មិនទៅកាន់ទុគ្គតិអស់ ៩១ កប្ប
- បានជាស្ដេចចក្រពត្តិ
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ជាតក បិដកលេខ ៧២ ទំព័រ ៣០៩)

- **៣៣.អានិសង្សសំពត់**

- កាលអន្ទោលទៅក្នុងភពតូចភពធំ សំពត់ ១ សែន សំពត់ពណ៌ស ពណ៌លឿង ពណ៌ក្រហម រមែងបាំងលើក្បាល
- មានសម្បុរដូចមាស
- ប្រាសចាកធូលី
- ប្រកបដោយពន្លឺ
- មានតេជៈ
- រមែងបានសំពត់កោសេយ្យពស្ត្រ និង សំពត់កម្ពល
- បានសំពត់ធ្វើពីសម្បកឈើ ធ្វើពីកប្បាសក្នុងទីទាំងពួង

(ចាក បិដកលេខ ៧៤ ទំព័រ ១៤៤)

- **៣៤.អានិសង្សធ្វើផ្លូវ**

- មិនទៅកាន់កំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ៩៤ កប្ប
- បានជាស្តេចឥស្សរៈលើជនទាំងពួង
- បាននូវបដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដកលេខ ៧៣ទំព័រ ៧១)

- **៣៥.អានិសង្សស្ពាន**

- មិនទៅកាន់ទុគ្គតិអស់ ៩៤ កប្ប
- បាននូវវិជ្ជា ៣ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ ។

(ចាក បិដកលេខ ៧៩ទំព័រ ១២៤)

## ➢ ៣៦.អានិសង្សផលរបស់ទានមាន ១៨ យ៉ាង

១.ទានជាជណ្ដើរឡើងឋានសួគ៌

២.ទានរមែងឲ្យនូវឥស្សរិយយសផង

៣.ទានជាទីចូលទៅកាន់ឋានសួគ៌

៤.ទានទុកជាច្រកទ្វារនៃឋានសួគ៌

៥.ទានជាទីលះបង់នូវសេចក្ដីទាល់ក្រ

៦.ទានជាទីពឹងដល់មនុស្សទាំងឡាយ

៧.ទានជាទីរួចផុតចាកនរក

៨.ទានប្រព្រឹត្តទៅដើម្បីភោគសម្បត្តិ

៩.ទានរមែងរក្សាជីវិតរុងរឿង

១០.ទានញុំាងទ្រព្យឲ្យកើតឡើង

១១.ទានជាទីឲ្យសម្រេចនូវសេចក្ដីប្រាថ្នាទាំងពួងបាន

១២.ទានមានឧបមាដូចដើមកប្បព្រឹក្ស

(ដើមឈើអាចឲ្យសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង)

១៣.ទានជាទីញុំាងសម្លាញ់ល្អឲ្យកើតឡើង

១៤.ទានជាភាជន៍សម្រាប់ទ្រនូវសម្បត្តិ

១៥.អ្នកឲ្យទានរមែងជួបនូវអ្នកមានចិត្តល្អ មានចិត្តស្មោះត្រង់ ។

១៦.ទានជាផ្លូវនៃព្រះនិព្វានដ៏ប្រសើរ

១៧.ទានជាទីបិទបាំងនូវអបាយភូមិ

១៨.ទានជាទីគោចរនៃព្រះពុទ្ធទាំងឡាយ ។

*(ចាកគម្ពីរជាតកដ្ឋកថាៈ)*

## ➢ ៣៧.អានិសង្សផលរបស់បុណ្យ ៤៧ ប្រការ

១.នរណានឹងមកដណ្តើមមិនបាន
២.ជាប់តាមខ្លួនទៅគ្រប់ជំហាន
៣.រមែងជាប់ទៅតាម (ទីកើត)
៤.មិនទូទៅដល់ពួកជនដទៃ
៥.ចោរលួចទៅមិនបាន
៦.ឲ្យសម្បត្តិដល់យើងតាមត្រូវការ
៧.ប្រាថ្នាយ៉ាងណាបានយ៉ាងនោះ
៨.មានសម្បុរផូរផង់ល្អព្រោះបុណ្យ
៩.មានសម្លេងពិរោះព្រោះបុណ្យ
១០.មានទ្រង់ទ្រាយល្អព្រោះបុណ្យ
១១.មានរូបល្អព្រោះបុណ្យ
១២.បានជាអធិបតីធំ ក៏ព្រោះបុណ្យ
១៣.មានយសបរិវារ
១៤.ភាពជាស្តេចប្រទេសរាជ្យ
១៥.បានឥស្សរិយយសក៏ព្រោះបុណ្យ
១៦.បានស្តេចចក្រពត្តិក៏ព្រោះបុណ្យ
១៧.ភាពជាស្តេចនៃទេវតាក៏ព្រោះបុណ្យ
១៨.បានសម្បត្តិជាមនុស្សក៏ព្រោះបុណ្យ
១៩.បានទេវលោកសម្បត្តិក៏ព្រោះបុណ្យ
២០.បានព្រះនិព្វានសម្បត្តិក៏ព្រោះបុណ្យ

២១.បានមិត្តសម្បទាល្អក៏ព្រោះបុណ្យ
